ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន

ASSETS MANAGEMENT OF KB DAEHAN SPECIALIAZED BANK

## ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន

ASSETS MANAGEMENT OF KB DAEHAN SPECIALIAZED BANK

គ្រូណែនាំៈ សុខ ឡៃហុក

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទ៖ ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

សុខ ឡៃហុក

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំបានយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការគណនេយ្យដូចគ្នា។ ដោយឡែក ដើម្បីឱ្យការសិក្សារបស់និស្សិត កាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗ ដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យបានយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យ ពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតប ឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណាមួយនេះឡើង និងបានចូលរួមចំណែកមួយក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានគោលបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**យ៉ា ជីវជីវ**
ID: B22/101



**ហេម សុរីណា**
ID: B22/045



**អឿត នីតា**
ID: B22/079



**យី ពុំ**
ID: B22/083



**ស៊ិន វិឆ្ន័យយ៉ារ៉ុវ**
ID: B22/001

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតដល់អ្នកមានគុណដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្ឌាសាស្ត្រាចារ្យ  លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ  សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ  ដល់ឯកឧត្តមបណ្ឌិត  **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះលោកគ្រូ **សុខ ឡៃហុក** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ  និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់  ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតដល់ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ  ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រជំនាញគណនេយ្យ នៃសាកលវិទ្យាល័យវ៉ាន់ដាវ៉ាន់ដា ជំនាន់ទី២២៖

សូមធានាអះអាងថាខ្លឹមសារសារណាក្រោមប្រធានបទស្តីអំពី"ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន" នេះគឺពិតជាស្នាដៃមួយរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានមានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលដែលទាក់ទងទៅនឹងការស្រាវជ្រាវដែលបានលើកឡើងនេះគឺជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកក្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



យ៉ា ជីងជីង

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ដោយសារនាពេលបច្ចុប្បន្ន ផ្នែកវិស័យធនាគារកំពុងតែមានការរីកចម្រើនយ៉ាងខ្លាំងក្លា គួរឱ្យកត់សម្គាល់នាទស្សវត្សចុងក្រោយនេះ ហើយក៏បានចូលរួមចំណែកយ៉ាងធំធេង ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យកាន់តែមានភាពរីកចម្រើន។ ក្នុងនោះដែរស្ថាប័នហិរញ្ញវត្ថុនីមួយៗ តែងតែមានគោលនយោបាយនិងនីតិវិធីផ្សេងៗក្នុងការគ្រប់គ្រប់ទៅលើអង្គភាពរបស់ខ្លួនទាំងផ្នែកធនធានមនុស្ស ផ្នែកបច្ចេកទេស ឬបច្ចេកវិទ្យាផ្សេងៗទៀត សម្រាប់ដឹកនាំអង្គភាពរបស់ខ្លួនឱ្យកាន់តែមានភាពទាក់ទាញ និងរីកចម្រើន។ យ៉ាងណាមិញ ធនាគារឯកទេស ខេប៊ី ដេហាន ក៏ជាស្ថាប័នហិរញ្ញវត្ថុមួយដែលបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយជម្រុញដល់វិស័យសេដ្ឋកិច្ចជាតិតាមរយៈការផ្តល់នូវសេវា ដល់ប្រជាពលរដ្ឋ។ ម៉្យាងវិញទៀតដើម្បីយល់ដឹងឱ្យកាន់តែច្បាស់ពីគោលនយោបាយ ឬនិតីវិធីក្នុងការគ្រប់គ្រងនានារបស់ធនាគារ មានស្ថានភាពបែបណាយើងខ្ញុំនឹងធ្វើការលើកឡើងដូចខាងក្រោម។

ជាក់ស្តែងក្រុមយើងខ្ញុំ ក៏បានសិក្សាស្រាវជ្រាវទាក់ទងទៅនឹងការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន រួចមកយើងសង្កេតឃើញថារាល់ទ្រព្យសកម្មរបស់ធនាគារគឺត្រូវតែមានការកំណត់យ៉ាងជាក់លាក់ ទៅលើរបាយការណ៍ដូចជានីតិវិធីក្នុងការកំណត់តម្លៃ ជាពិសេសទៅលើបំណុលនានារបស់ធនាគារមុននឹងបញ្ចេញ គឺមានការសិក្សាយ៉ាងល្អិតល្អន់ទៅលើកម្ចីនោះមុននឹងធនាគារធ្វើការជួញដូរទៅលើឧបករណ៍ហិរញ្ញវត្ថុ គឺបានសិក្សាទៅលើរយៈពេល និងស្ថានភាពរបស់ទីផ្សារយ៉ាងយកចិត្តទុកដាក់ លើការជួញដូរឧបករណ៍ហិរញ្ញវត្ថុ មានការខាតបង់នោះធនាគារកាត់ទឹកប្រាក់ ដែលខាតនោះទៅក្នុងការិយនៃឆ្នាំនីមួយៗ ដើម្បីឱ្យតួលេខនៃប្រាក់ចំណេញខាតថយចុះមានចំនួនតិច ឬថេរ។ រាល់បញ្ហាដែលកើតមាន គឺគណៈកម្មាធិការនៃទ្រព្យសកម្មតែងតែព្យាយាមស្វែងរកវិធីសាស្ត្រ ដើម្បីដោះស្រាយយ៉ាងមានប្រសិទ្ធភាពទ្រព្យសម្បត្តិ និងគ្រឿងបរិក្ខារដែលមានចែកចំណាត់ថ្នាក់យ៉ាងច្បាស់ទៅលើរាល់ទ្រព្យសម្បត្តិនីមួយៗ។ រាល់ការកត់ត្រានៅក្នុងរបាយការណ៍សុទ្ធតែបានកត់ត្រាតាមស្តង់ដារបស់ប្រទេសកម្ពុជាដើម្បីមានងាយស្រួលដល់អ្នកប្រើប្រាស់ផ្នែខាងក្រៅទាំងឡាយ។

ក្នុងនោះដែរបញ្ហាប្រឈម ដែលអាចកើតមាននូវហានិភ័យរួមមានហានិភ័យប្រតិបត្តិការការគ្រប់គ្រងការអនុលោមតាមបទបញ្ញត្តិ និងនីតិវិធីស្តីពីការប្រឆាំងក៏រួមទាំងគោលនយោបាយនានា ប៉ុន្តែ យុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន គឺភ្ជាប់ជាមួយការគ្រប់គ្រងហានិភ័យ ហេតុដូច្នេះហើយ ធនាគារឯកទេស ខេប៊ី ដេហាន ទទួលស្គាល់ថាការគ្រប់គ្រងហានិភ័យដ៏មានប្រសិទ្ធភាព ដែលផ្តល់សារៈសំខាន់យ៉ាងខ្លាំង ចំពោះភាពជោគជ័យលើអាជីវកម្មរបស់ខ្លួន។

ជាចុងក្រោយ ក្រុមយើងខ្ញុំអាចសន្និដ្ឋានបានថា ការគ្រប់គ្រងទ្រព្យសកម្មធនាគារឯកទេស ខេប៊ី ដេហាន គឺពិតជាបានគិតគូរយ៉ាងល្អិតល្អន់ពិតប្រាកដមែន ទៅលើការគ្រប់គ្រង និងការប្រើប្រាស់ទ្រសកម្មអង្គភាពរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់បើធៀបទៅនឹងដៃគូប្រកួតប្រជែងដទៃទៀត មិនត្រឹមតែប៉ុណ្ណោះនោះទេធនាគា រតែងតែមានដំណោះស្រាយរាល់ហានិភ័យដែលកើតមានឡើង ចំពោះស្ថាប័នដោយផ្អែកទៅលើធន្ធៈនៃការគ្រប់គ្រងហានិភ័យគឺជាសារៈសំខាន់ចំពោះភាពជោគជ័យលើអាជីវកម្ម។

# មាតិកា

ទំព័រ

អារម្ភកថា ..... i

រចនាសម្ព័ន្ធក្រុម..... ii

សេចក្ដីថ្លែងអំណរគុណ ..... iii

អំណះអំណាង ..... iv

សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ..... v

មាតិកា..... vi

## ជំពូកទី១
## សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ .....១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ.....២

១.៣ គោលបំណងនៃការស្រាវជ្រាវ.....២

១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ .....២

១.៤.១ ទំហំដែនកំណត់.....២

១.៤.២ វិសាលភាពនៃការស្រាវជ្រាវ.....២

១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ.....២

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ.....៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.....៣

## ជំពូកទី២
## ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស

២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ..... ៥

២.១.១ និយមន័យការគ្រប់គ្រង ..... ៥

២.១.២ ប្រវត្តិនៃការគ្រប់គ្រង ..... ៥

២.១.៣ មុខងារនៃការគ្រប់គ្រង..... ៦

២.១.៤ សារៈសំខាន់នៃការគ្រប់គ្រង ..... ៧

២.២ នីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេបី ដេហាន ..... ៨

២.២.១ និយមន័យ ..... ៨

២.២.២ ប្រេកពនីតិ ..... ៨

២.២.៣ តួនាទីរបស់នីតិ..... ៩

២.២.៤ ប្រភេទនៃនិតិ..... ៩

២.៣ ផលប្រយោជន៍នៃការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេសខេបី ដេហាន .....១១

២.៣.១ និយមន័យនៃទ្រព្យសកម្ម ........................................................................១១
២.៣.២ ប្រវត្តិនៃទ្រព្យសកម្ម ..............................................................................១១
២.៣.៣ ប្រភេទនៃទ្រព្យសកម្ម.............................................................................. ១២

## ជំពូកទី៣
## ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន

៣.១ ស្ថានភាពទូទៅរបស់ធនាគារឯកទេស ខេប៊ី ដេហាន..........................................................១៤
៣.១.១ ប្រវត្តិរបស់ធនាគារឯកទេស ខេប៊ី ដេហាន ...................................................១៥
៣.១.២ គោលនយោបាយរបស់ធនាគារឯកទេស ខេប៊ី ដេហាន ......................................១៦
ក. ទស្សនៈវិស័យ ......................................................................................១៦
ខ. បេសកម្ម ...........................................................................................១៦
គ. រចនាសម្ព័ន្ធរបស់ធនាគារឯកទេស ខេប៊ី ដេហាន ...................................... ១៧
ឃ. ភាគហ៊ុនរបស់ធនាគារឯកទេស ខេប៊ី ដេហាន........................................... ១៧
៣.១.៣ ប្រភេទនៃទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន ................................ ១៧
ក.សាច់ប្រាក់ក្នុងដៃ.....................................................................................១៨
ខ.ប្រាក់បញ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា-សុទ្ធ .................................................១៨
គ. ប្រាក់តម្កល់តាមច្បាប់...............................................................................១៨
ឃ. ឥណទាននិងបុរេប្រទានផ្តល់ដល់អតិថិជន-សុទ្ធ............................................១៨
ង. ទ្រព្យសកម្មផ្សេងៗ ..................................................................................១៨
ច. ទ្រព្យសកម្មអរូបី......................................................................................១៨
ឆ. ទ្រព្យសម្បត្តិ និងបរិក្ខារ ...........................................................................១៩
ជ. សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម...........................................................................១៩
ឈ. តម្លៃកេរ្តិ៍ឈ្មោះ.........................................................................................១៩
៣.១.៤ ប្រភេទនៃឥណទានរបស់ធនាគារឯកទេស ខេប៊ី ដេហាន ....................................១៩
ក.ឥណទានរថយន្ត.......................................................................................... ២០
ខ.កម្ចីទូទៅ ................................................................................................ ២០
គ. កម្ចីគ្រឿងយន្តកសិកម្ម ............................................................................ ២១
៣.២ នីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសកម្មធរបស់ធនាគារឯកទេស ខេប៊ី ដេហាន.........................២២
៣.២.១ លក្ខណៈនៃការគ្រប់គ្រងទ្រព្យសកម្ម...........................................................២៣
ក. ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល(Liquidity management) ..............................២៣
ខ. ការគ្រប់គ្រងលើទ្រព្យសកម្ម (Assets Management)..........................................២៣
គ. ការគ្រប់គ្រងលើបំណុល (Liabilities Management)..........................................២៣
ឃ.ការគ្រប់គ្រងកម្ចី (Loan Management).........................................................២៣
ង. ការវិនិយោគមូលបត្រចំណូល (Income securities investment)......................... ២៤

ច. ការគ្រប់គ្រងដើមទុនគ្រប់គ្រាន់ (Capital Adequacy Management) ..................... ២៤
ឆ. ការគ្រប់គ្រងហានិភ័យ (Risk Management) ..................... ២៥
ជ. រក្សាសាច់ប្រាក់បម្រុង ..................... ២៥
៣.២.២ វិធីសាស្ត្របែងចែកទ្រព្យសកម្មឱ្យមានប្រសិទ្ធភាព ..................... ២៥
ក.វិធីសាស្ត្រកំណត់តម្លៃ ..................... ២៥
ខ.បំណុលយថាហេតុ និងបំណុលផ្សេងៗ ..................... ២៥
៣.២.៣ ការបែងចែកទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន ..................... ២៥
១. ទ្រព្យសកម្មហិរញ្ញវត្ថុ ..................... ២៥
ក. ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ ..................... ២៦
ខ. ការទទួលស្គាល់ និងការឈប់ទទួលស្គាល់ ..................... ២៦
គ. ការវាស់វែង ..................... ២៧
ឃ. ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ ..................... ២៧
ង. ការថយចុះតម្លៃ ..................... ២៧
ច. ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាព ..................... ២៧
ឆ. ការប្រែប្រួល និងការលែងទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ..................... ២៩
ជ. បំណុលហិរញ្ញវត្ថុ និងមូលធន ..................... ២៩
ឈ. ការរៀបចំកាត់កង ..................... ២៩
ញ. មូលដ្ឋាននៃការគ្រប់គ្រងទ្រព្យសកម្ម ..................... ២៩
៣.២.៤ ការគ្រប់គ្រងរបាយការណ៍តុល្យការ ..................... ៣០
៣.៣ ផលប្រយោជន៍នៃការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន ..................... ៣៤
ក. ចំពោះស្ថាប័ន ..................... ៣៤
ខ. ចំពោះសង្គម ..................... ៣៤

## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ..................... ៣៦
៤.២ ការវិភាគលើចំណុចខ្សោយ ..................... ៣៦

## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ..................... ៣៧
៥.២ ការផ្តល់អនុសាសន៍ ..................... ៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះប្រទេសកម្ពុជា គឺជាប្រទេសមួយដែលគេចាត់ទុកថា ជាប្រទេសដែលកំពុងរីកចម្រើនស្ថិតក្នុងចំណោមបណ្តាប្រទេសផ្សេងៗទៀតនៅលើសកលលោក។ បច្ចុប្បន្នគេសង្កេតឃើញថានៅក្នុងប្រទេសកម្ពុជាវិស័យហិរញ្ញវត្ថុ គឺជាសរសៃឈាមមួយសម្រាប់ ជម្រុញការអភិវឌ្ឍកំណើនសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។ គេអាចនិយាយបានថា នៅពេលដែលប្រទេសជាតិមួយមានកំណើនវិស័យហិរញ្ញវត្ថុ ប្រទេសជាតិនោះក៏មានកំណើនផ្នែកសេដ្ឋកិច្ចផងដែរ។ ការរីកចម្រើនផ្នែកហិរញ្ញវត្ថុនេះ ក៏បានបង្កើតឱ្យមានការលេចជារូបរាងឡើងនូវស្ថាប័នហិរញ្ញវត្ថុជាច្រើនដូចជាធនាគារ ព្រមទាំងគ្រឹះស្ថានហិរញ្ញវត្ថុនានាដែលកំពុងបម្រើសេវាកម្ម តាមតម្រូវការដល់ប្រជាជនក៏ដូចជាការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសជាតិ។

ជាមួយនឹងការរីកចម្រើននេះ វាបានឆ្លុះបញ្ចាំងអោយយើងឃើញថាសាធារណៈជនបានបង្កើននូវជំនឿទុកចិត្តរបស់ខ្លួនចំពោះវិស័យធនាគារ និងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្នគួបផ្សំជាមួយគ្នានោះដែរ ក៏មានធនាគារឯកទេសជាច្រើនដែលកំពុងដើរតួនាទីជម្រុញឱ្យមានការផ្តល់ឥណទាន និងសេវាកម្មដទៃទៀត ទៅដល់សាធារណៈជនសម្រាប់ផ្គត់ផ្គង់ដល់អាជីវកម្មរបស់គេ។ ជាក់ស្តែងធនាគារឯកទេស ខេប៊ី ដេហាន ក៏ជាស្ថាប័នដែលបានផ្តល់នូវឥណទានជាច្រើនប្រភេទ សម្រាប់បម្រើសេវាកម្មជូនទៅកាន់សាធារណៈជន ដែលជាអតិថិជនរបស់ពួកគេបានយ៉ាងល្អប្រសើរ គួបផ្សំជាមួយការខិតខំប្រឹងប្រែងផ្តល់នូវទំនុកចិត្តសេវាកម្មដើម្បីបង្កើនភាពងាយស្រួល មានទាំងយុទ្ធសាស្ត្រដែលជួយបង្កើននូវឱកាស និងបានរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ អាចផ្តល់ជាដើមទុនសម្រាប់ប្រជាជន ក្នុងការយកទៅប្រើប្រាស់តាមស្ថានភាពជាក់ស្តែងក៏ដូចជាការពង្រីកអាជីវកម្មគ្រប់ប្រភេទ ផលិតផល កសិកម្ម ឧស្សាហកម្មផ្សេងៗដែលអាចធ្វើឱ្យប្រជាជនមានចំណូលកើនឡើង ក្នុងសកម្មភាពដែលអាចធ្វើឱ្យមានភាពងាយស្រួលដល់ជីវភាពមានភាពល្អប្រសើរ និងទុកជាដើមទុនមួយក្នុងការបង្វិល និងមានភាពរហ័ស។ ជាពិសេសជួយបង្កើននូវឱកាសការងារជាច្រើន ទៅដល់ប្រជាជន និងអាចកាត់បន្ថយនូវហានិភ័យផ្សេងៗដែលបានពីការទទួលឥណទានមិនមានភាពច្បាស់លាស់។

សរុបសេចក្តីមក ធនាគារជាច្រើននៅក្នុងប្រទេសកម្ពុជា ជាពិសេសឯកទេស ខេប៊ីដេហាន ដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ឥណទាន និងបានចូលរួមចំណែកក្នុងការរីកចម្រើនផ្នែកហិរញ្ញវត្ថុ នៅប្រទេសកម្ពុជាយើង។ ហេតុដូចនេះហើយ ដោយឃើញពីការរីកដុះដាលយ៉ាងឆាប់រហ័សនៃវិស័យធនាគារមិនថា ក្នុងប្រទេស ឬក្រៅប្រទេស ថែមទាំងមានការពង្រីក សាខាជាច្រើនកន្លែង និងមានទំនាក់ទំនងក្រៅប្រទេសផងដែរនោះ ទើបធ្វើឱ្យក្រុមយើងខ្ញុំចង់ស្វែងយល់អំពី**“ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន”** លើកយកមកធ្វើការសិក្សាស្វែងយល់ និងស្រាវជ្រាវឡើងដើម្បីជាឯកសារ រក្សាទុកសម្រាប់ជាជំនួយមួយផ្នែកដល់ការសិក្សារបស់ និស្សិតជំនាន់ក្រោយដែលចង់ស្វែងយល់បន្ថែមពាក់ព័ន្ធវិស័យធនាគារ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាការពិតណាស់ ធនាគារឯកទេស គឺជាធនាគារដែលមានការចុះបញ្ជីទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា និងក្រសួងស្ថាប័នពាក់ព័ន្ធជាច្រើនទៀត។ម្យ៉ាងវិញទៀត គ្រប់ធនាគារឯកទេស គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុដទៃផ្សេងទៀត មានការតម្រូវឱ្យគោរពតាមច្បាប់បទបញ្ញត្តិនានា របស់ធនាគារជាតិនៃកម្ពុជា រួមមាន គោលនយោបាយរូបិយវត្ថុ សេវាប្រាក់បញ្ញើ សេវាឥណទាន សេវាទូទាត់និងផាត់ទាត់ សេវាផ្ទេរប្រាក់ សេវាប្តូរប្រាក់ជាដើម។ ជាមួយគ្នានេះផងដែរ ធនាគារឯកទេស ខេប៊ីដេហាន ជាធនាគារក្រៅប្រទេសដែលបានមកធ្វើការវិនិយោគក្នុងប្រទេសកម្ពុជា។

ដូចនេះក្រុមយើងខ្ញុំបានលើកយក គោលបំណងពីរយកមកសិក្សាស្រាវជ្រាវ ៖

១.តើធនាគារឯកទេស ខេប៊ី ដេហាន មាននីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសកម្មយ៉ាងដូចម្តេច?

២.តើការគ្រប់គ្រងទ្រព្យសកម្មបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ធនាគារឯកទេស ខេប៊ី ដេហាន?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើនីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសកម្ម និងផលប្រយោជន៍ចំពោះការគ្រប់គ្រងទ្រព្យសកម្ម ថាតើធនាគារឯកទេស ខេប៊ី ដេហាន មានគោលនយោបាយយ៉ាងណា ចំពោះការគ្រប់គ្រងទ្រព្យសកម្មដើម្បីទទួលបានការទុកចិត្តពីអតិថិជន។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

សម្រាប់ធនាគារឯកទេស ខេប៊ី ដេហាន មានសាខាជាច្រើននៅក្នុងទីក្រុងភ្នំពេញ។ ហេតុដូចនេះហើយទើបក្រុមយើងខ្ញុំធ្វើការសម្រេចចិត្តលើកយកការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន ដែលស្ថិតនៅទីតាំងទីស្នាក់ការកណ្តាល អគារលេខ១ ជាន់ទី២០ ទី២១&ទី២២ ផ្លូវលេខ៣៦០ ភូមិ០៨ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ប្រទេសកម្ពុជាមកធ្វើការបកស្រាយ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ មានវិសាលភាពទៅលើ ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន ក្នុងឆ្នាំ២០២៣ មកសិក្សា។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវបានប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យ ដោយផ្តោតចម្បងទៅលើការវិភាគទិន្នន័យ និងឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់អំពីដំណើរការសវនកម្មលើអចលកម្មបី និងការរៀបចំនីតិវិធីគ្រប់គ្រងលើអចលកម្មបីរបស់ធនាគារ។

សម្រាប់សំណួរស្រាវជ្រាវទី១៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដូចជាការវិភាគ លើរបាយការណ៍កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្តាញសង្គមរបស់ធនាគារផ្ទាល់ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗ បានមកពីបណ្ណាល័យរបស់វិទ្យាស្ថានវ៉ាន់ដា ការដកស្រង់ឯកសារមេរៀន ទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ របាយការណ៍ចាស់ៗ ដែលនិស្សិតរៀមច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

សម្រាប់សំណួរស្រាវជ្រាវទី២៖ ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដូចជាការវិភាគលើរបាយការណ៍កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈការចុះទៅទីតាំងធនាគារផ្ទាល់ តាមរយៈគេហទំព័របណ្តាញសង្គមរបស់ធនាគារផ្ទាល់ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗ បានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យ វ៉ាន់ដា ការដកស្រង់ឯកសារមេរៀន ទាំងឡាយណាដែលពាក់ព័ន្ធនឹងប្រធានបទ ការអានកម្រងឯកសារផ្សេងៗ របាយការណ៍ចាស់ៗ ដែលនិស្សិតរៀមច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅលោកគ្រូណែនាំបន្ថែម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះអាចជាជំនួយ ដល់សិស្សនិស្សិតជំនាន់ក្រោយទុកជាឯកសារ ដើម្បីធ្វើការសិក្សាស្រាវជ្រាវស្វែងយល់បន្ថែមទៀត និងជាផលប្រយោជន៍ផ្សេងទៀត សម្រាប់អ្នកដែលមានបំណងចង់ស្វែងយល់ពីការគ្រប់គ្រងទ្រព្យសកម្មឱ្យមានប្រសិទ្ធភាពខ្ពស់ និងធ្វើការបង្កើននូវទំនុកចិត្តរបស់ខ្លួនក្នុងការវិនិយោគបន្ថែមទៀតផងដែរ ។ ចំពោះប្រធានបទនៃសារណានេះ នឹងបានផ្តល់ជាប្រយោជន៍ជាច្រើនដូចខាងក្រោម៖

- **សម្រាប់ធនាគារឯកទេស ខេប៊ី ដេហាន**

ជាការជួយផ្សព្វផ្សាយពាណិជ្ជកម្មសេវាកម្មជូនដល់អតិថិជន និងសាធារណជន។ លើកឡើងនូវគុណសម្បត្តិដំណើរការប្រតិបត្តិការ បង្កើននូវភាពជឿជាក់ដល់អតិថិជនលើសេវាកម្មរបស់ស្ថាប័នហិរញ្ញវត្ថុចូលរួមផ្តល់អនុសាសន៍មួយចំនួនដែលពាក់ព័ន្ធនឹងចំណុចខ្វះខាត។ ជាឯកសារសម្រាប់ផ្សព្វផ្សាយពាណិជ្ជកម្មសេវាកម្ម។

- **សម្រាប់អតិថិជន**

ជាឯកសារជំនួយដល់អតិថិជនឱ្យបានយល់ដឹងច្បាស់ពីទ្រព្យសកម្ម និងសេវាកម្មរបស់ធនាគារ ។

- **សម្រាប់អ្នកស្រាវជ្រាវ**

ជួយពង្រឹងដល់សមត្ថភាពលើផ្នែកទ្រឹស្តីនិងបទពិសោធន៍លើវិស័យហិរញ្ញវត្ថុ និងធនាគារបានបង្ហាញនូវសាមគ្គីភាព និងសហការគ្នាសម្រាប់សមាជិកស្រាវជ្រាវបានផ្តល់ជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយៗ យល់ដឹងការគ្រប់គ្រងទ្រព្យសកម្មទៅលើវិស័យធនាគារឯកទេស។

- **សារៈសំខាន់សង្គមជាតិ**

ប្រសិនបើមានការស្រាវជ្រាវកាន់តែច្រើន នោះនឹងមានអ្នកមានចំណេះដឹងខ្ពង់ខ្ពស់កាន់តែច្រើនផងដែរ ពីព្រោះអ្នកដែលបានធ្វើការស្រាវជ្រាវបានបន្សល់ទុកនូវឯកសារជាច្រើន សម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយ ។ធនាគារមានការរីកចម្រើនធ្វើឱ្យប្រភពទុនមានការកើនឡើង ដែលជម្រុញឱ្យមានការវិនិយោគកាន់តែច្រើនផងដែរ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជំពូកទី១៖ សេចក្តីផ្តើម បង្ហាញអំពីគំនិតផ្តួចផ្តើមដែលទាក់ទងនឹងទិដ្ឋភាពទូទៅព្រមទាំង បុព្វហេតុវត្ថុបំណង និងការង្ហាញអំពីការសិក្សាតែទៅលើផ្នែកទ្រឹស្តី ដែលបានបង្ហាញពីនិយមន័យ ប្រវត្តិ វិធីសាស្ត្រវិធានការផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងទ្រព្យសកម្មក្នុងវិស័យធនាគារឯកទេស និងបកស្រាយអំពីវត្ថុបំណងចោទសួរ។

ជំពូកទី២៖ រំលឹកទ្រឹស្តី នៅក្នុងជំពូកនេះ យើងសិក្សាទៅលើផ្នែកទ្រឹស្តីដែលបានបង្ហាញពីនិយមន័យ ប្រវត្តិ វិធីសាស្ត្រវិធានការផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងទ្រព្យសកម្ម ក្នុងវិស័យធនាគារឯកទេស និងបកស្រាយអំពីវត្ថុបំណងចោទសួរ។

ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ ក្នុងជំពូកនេះ ជាជំពូកមួយដែលសិក្សាអំពីវិធីសាស្ត្រនៃការស្រាវជ្រាវដែលបានលើកបង្ហាញពីក្របខណ្ឌវិធីសាស្ត្រក្នុងការចុះប្រមូលព័ត៌មាន ទិន្នន័យ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវទាក់ទងទៅនឹងប្រធានបទ។

ជំពូកទី៤៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ ក្នុងជំពូកនេះជាការវិភាគទៅលើចំណុចដែលមានសក្តានុពលជាវិជ្ជមាន និងផលប៉ះពាល់ជាអវិជ្ជមានដល់ប្រព័ន្ធគ្រប់គ្រងរបស់ស្ថាប័ន។ ក្នុងន័យនេះ គឺចង់បង្ហាញថាតើ៖

- នីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសកម្ម
- គុណប្រយោជន៍នៃការគ្រប់គ្រងទ្រព្យសកម្ម

ចំណុចខ្សោយ គឺជាដំណើរការនៃប្រព័ន្ធគ្រប់គ្រងដែលងាយនិងមានផលប៉ះពាល់ ហើយនិងមានភាពស្មុគស្មាញក្នុងការគ្រប់គ្រង។

ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ ក្នុងជំពូកនេះ គឺជាការសន្និដ្ឋានសរុបសេចក្តីទាំងអស់ទៅលើគ្រប់ចំនុចនៅក្នុងអត្ថបទ ព្រមទាំងធ្វើការផ្តល់យោបល់ និងអនុសាសន៍ផងដែរ ដែលទាក់ទងទៅ នឹងចំណុចខ្វះខាតដើម្បីជាការកែលម្អឡើងវិញនូវភាពខ្វះខាត។

# ជំពូកទី២

# ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស

## ២.១ លក្ខណៈទូទៅនៃការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ

### ២.១.១ និយមន័យការគ្រប់គ្រង

ការគ្រប់គ្រង គឺជាដំណើរការរៀបចំចាត់ចែងដឹកនាំនិងត្រួតពិនិត្យ ដោយប្រើធនធានផ្សេងៗទៀតដើម្បីសម្រេចគោលដៅ[1] ។

ការគ្រប់គ្រង(Management) គឺជាដំណើរការនៃការប្រើប្រាស់ធនធាននៅក្នុងអង្គភាពឱ្យទទួលបានជោគជ័យដល់អង្គភាពដោយមានការរៀបចំ ការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យ[2] ។

ការគ្រប់គ្រង គឺដំណើរការធ្វើផែនការ ការចាត់ចែង ការដឹកនាំ និងការត្រួតពិនិត្យ ទៅលើការប្រើប្រាស់ធនធានមនុស្ស និងធនធានដទៃទៀតដើម្បីសម្រេច គោលដៅរបស់អង្គភាព [3]។

ការគ្រប់គ្រង គឺជាដំណើរការនៃការធ្វើការជាមួយនឹងមនុស្សនិងធនធានដទៃទៀតដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព[4]។

ការគ្រប់គ្រង គឺជាដំណើរការធ្វើ ការធ្វើផែនការ ការចាត់តាំង ការដឹកនាំ និងការត្រួតពិនិត្យលើការប្រើប្រាស់ធនធានមនុស្ស និងធនធានដទៃទៀតដើម្បីសម្រេចនូវគោលដៅអង្គភាព ដោយមានប្រសិទ្ធភាពខ្ពស់បំផុត [5]។

ការគ្រប់គ្រង គឺជាដំណើរការលើការទាក់ទង ទៅលើបណ្តាញការងារយ៉ាងស្មុគស្មាញរវាង មនុស្សនិងមនុស្សជាមួយធនធានផ្សេងៗទៀត[6]។

### ២.១.២ ប្រវត្តិនៃការគ្រប់គ្រង

គំនិតនៃការគ្រប់គ្រង មានតាំងពីរាប់ពាន់ឆ្នាំមកហើយ។ យោងតាម Pindur, Rogers, and Kim(១៩៩៥) វិធីសាស្រ្តសំខាន់ៗក្នុងការគ្រប់គ្រងបានត្រឡប់មកវិញយ៉ាងហោចណាស់ ៣០០០ ឆ្នាំមុនពេល កំណើតរបស់ព្រះគ្រីស្ទ ដែលជាពេលវេលាមួយដែលកំណត់ត្រានៃការធ្វើជំនួញត្រូវបានកត់ត្រាជាលើកដំបូង ដោយពួកបូជាចារ្យនៅមជ្ឈិមបូព៌ា។ សូក្រាតនៅប្រហែលឆ្នាំ ៤០០ មុនគ្រិស្តសករាជបាននិយាយថា ការគ្រប់គ្រងគឺជាសមត្ថភាពដាច់ដោយឡែកពីជំនាញបច្ចេកទេស និងចំណេះដឹង (Higgins, ១៩៩១)។ ជនជាតិរ៉ូមដែលល្បីល្បាញដោយសារកងទាហានរបស់ពួកគេដែលដឹកនាំដោយ Centurion បានផ្តល់ការទទួលខុសត្រូវតាមរយៈឋានានុក្រមនៃសិទ្ធិអំណាច។ ព្រះវិហាររ៉ូម៉ាំងកាតូលិកគឺត្រូវបានគេរៀបចំឡើងទៅតាមបន្ទាត់ទឹកដីជាក់លាក់ខ្សែសង្វាក់នៃពាក្យបញ្ជា និងការពិពណ៌នាការងារ។ នៅក្នុងកំឡុងយុគ្គសម័យកណ្តាលមានរយៈពេល ១០០០ ឆ្នាំប្រហែលពីឆ្នាំ ៤៧៦ នៃគ.ស ដល់ឆ្នាំ ១៤៥០ គ.ស. Guilds ដែលជាបណ្តុំនៃសិប្បករនិងពាណិជ្ជករបានផ្តល់ទំនិញដែលផលិតដោយដៃ ចាប់ពីនំប៉័ងរហូតដល់ពាសដែកនិងដាវសម្រាប់បូជនីយកិច្ច។ ឋានានុក្រមនៃការគ្រប់គ្រង និងអំណាចស្រដៀងទៅនឹងព្រះវិហារកាតូលិក ដែលអាជ្ញាធរបានសម្រាក

---

[1] KHSearch. ហ៊ួ សមួស្ស. (2018, September 21). *ដូចម្តេចដែលហៅថាការគ្រប់គ្រង ?* Retrieved from https://www.khsearch.com/qna/7930

[2] ដដែល

[3] Sokankeng. SOK AN-SMILE. (2013, December 03). *ការគ្រប់គ្រង*. Retrieved from https://url-shortener.me/4AVK

[4] មិត្តនិស្សិត. (2011, May 31). *និយមន័យនៃការគ្រប់គ្រង*. Retrieved from https://url-shortener.me/4ATJ+

[5] TVETកម្ពុជា. (2021, November 11). *មេរៀនទី១លំនាំដើមនៃការគ្រប់គ្រង*. Retrieved from https://url-shortener.me/4AV4

[6] ដដែល

ជាមួយចៅហ្វាយនាយ ហើយបោកបញ្ឆោតទៅកាន់អ្នកធ្វើដំណើរ និងកូនជាង។ ជាទូទៅសិប្បករទាំងនេះ គឺជាអាជីវកម្មខ្នាតតូច ដែលផលិតផលបានមានកម្រិតគុណភាពខុសៗគ្នា អត្រាផលិតទាប និងតម្រូវការតិចតួចសម្រាប់ការគ្រប់គ្រងលើសពីម្ចាស់ ឬសិប្បកម្ម បដិវត្តន៍ឧស្សាហកម្ម ដែលជាពេលវេលាមួយពីចុងទសវត្សរ៍ឆ្នាំ១៧០០ ដល់ទសវត្សរ៍ឆ្នាំ១៨០០ គឺជារយៈពេលនៃភាពចលាចល និងការផ្លាស់ប្តូរដ៏ធំនៅក្នុងរបៀបរស់នៅ និងការងារ។ មុននេះប្រជាជនភាគច្រើនប្រកបរបរធ្វើស្រែចំការ ឬធ្វើការ និងរស់នៅក្នុងសហគមន៍ជនបទ។ ជាមួយនឹងការបង្កើតម៉ាស៊ីនចំហាយទឹក ការច្នៃប្រឌិតជាច្រើនបានកើតឡើង រួមទាំងចលនាដោយស្វ័យប្រវត្តិនៃធ្យូងថ្មពីអណ្តូងរ៉ែក្រោមដី រោងចក្រថាមពល ឥឡូវនេះមានទំនិញផលិតយ៉ាងច្រើនដែលផលិតដោយដៃ និងក្បាលរថភ្លើងផ្លូវដែកដែលអាចផ្លាស់ទីផលិតផល និងសម្ភារៈឆ្លងកាត់ប្រទេសនានាបានទាន់ពេលវេលា និងវិធីសាស្ត្រមានប្រសិទ្ធភាព។ នៅរោងចក្រត្រូវការកម្មករដែលទាមទារទិសដៅ និងអង្គការ។ ដោយសារគ្រឿងបរិក្ខារទាំងនេះហើយធ្វើឱ្យកាន់តែមានសារៈសំខាន់ និងផលិតភាពតាមតម្រូវការសម្រាប់ការគ្រប់គ្រង និងការសម្របសម្រួលបានក្លាយជាកត្តាសំខាន់។ បើគិតអំពី Henry Ford, បុរសម្នាក់ ដែលបង្កើតខ្សែការជំឡើងចល័ត ដើម្បីផលិតរថយន្តរបស់គាត់។ នៅដើមទសវត្សរ៍នៅឆ្នាំ១៩០០ ដែលរថយន្តជាមួយនឹងត្រូវដាក់បញ្ចូលគ្នា ដោយសិប្បករដែលនឹងកែប្រែសមាសធាតុឱ្យសមនឹងផលិតផលរបស់ពួកគេ។ មកដល់នៃផ្នែកស្តង់ដានៅក្នុងឆ្នាំ១៩០៨ បានបន្តដោយខ្សែបដិវត្តន៍របស់ហ្វូដដែលបានណែនាំនៅឆ្នាំ១៩១៣ ពេលវេលាដែលត្រូវការក្នុងការសាងសង់គំរូ T បានធ្លាក់ចុះពីប៉ុន្មានថ្ងៃ មកត្រឹមប៉ុន្មានម៉ោងប៉ុណ្ណោះ (Klaess, ២០២០)។ តាមទស្សនៈរបស់អ្នកគ្រប់គ្រងសិប្បករដែលមានជំនាញ គឺមិនចាំបាច់ក្នុងការផលិតរថយន្តទៀតទេ។ តាមរយៈការប្រើប្រាស់នូវកម្លាំងពលកម្មដែលមានតម្លៃទាបនឹងការកើនឡើងនៃផលិតកម្ម ដែលទទួលបានដោយការផ្លាស់ប្តូរខ្សែផលិតកម្មបានអំពាវនាវឱ្យមានតម្រូវការណែនាំ និងគ្រប់គ្រងប្រតិបត្តិការដ៏ធំទាំងនេះ (Wilson, ២០១៥)។ ដើម្បីទាញយកអត្ថប្រយោជន៍ជាច្រើនពីបច្ចេកវិទ្យាថ្មីៗ ពីវិធីសាស្ត្រផ្សេងៗគ្នា ចំពោះរចនាសម្ព័ន្ធរបស់ស្ថាប័ន និងការគ្រប់គ្រងត្រូវបានទាមទារ។ រថយន្តត្រូវបានដាក់បញ្ចូលគ្នា ដោយសិប្បករដែលនឹងត្រូវកែប្រែសមាសធាតុឱ្យសមនឹងផលិតផលរបស់ពួកគេ[7]។

**២.១.៣ មុខងារនៃការគ្រប់គ្រង**

ការគ្រប់គ្រងមានមុខងារ ៤ គឺ ៖

- ផែនការសកម្មភាពការងារច្បាស់លាស់ស្របតាមធនធានដែលអង្គភាព។
- ការចាត់តាំង ឬចាត់ចែងការងារជូនបុគ្គលិកអោយត្រូវតាមជំនាញឯកទេសរបស់គេ។
- ការដឹកនាំល្អ-ត្រឹមត្រូវ និងស្របទៅនឹងវប្បធម៌របស់អង្គភាព និងតំបន់។
- ត្រួតពិនិត្យទៅលើរាល់លទ្ធផលការងារដែលបុគ្គលិកអនុវត្តកន្លងមក។

ទាំងអស់នេះ ប្រើសម្រាប់សម្រេចគោលបំណងរបស់អង្គភាព [8]។

[7] FHSU DIGITAL PRESS. (2020). *The History of Management.* Retrieved from https://fhsu.pressbooks.pub/management

[8] KHSearch. គ្រប់គ្រង. (2020, September 01). *តើមុខងារនៃការគ្រប់គ្រងមានប៉ុន្មានប្រភេទ?* Retrieved from https://www.khsearch.com/qna/28177

### ២.១.៤ សារៈសំខាន់នៃការគ្រប់គ្រង

ការគ្រប់គ្រងគឺជាប្រធានបទដ៏គួរឱ្យចាប់អារម្មណ៍មួយ ព្រោះវាទាក់ទងនឹងការកំណត់ ការស្វែងរក និងការឈានដល់គោលដៅ។ យើងទាំងអស់គ្នាគឺជាអ្នកគ្រប់គ្រងនៃជីវិតរបស់យើងផ្ទាល់ ហើយការអនុវត្តនៃការគ្រប់គ្រងមាននៅគ្រប់ផ្នែកទាំងអស់នៃសកម្មភាពរបស់មនុស្ស សាលារៀន អាជីវកម្ម ព្រះវិហារ រដ្ឋាភិបាល សហជីព កងកម្លាំងប្រដាប់អាវុធ និងក្រុមគ្រួសារ។ ការបង្កើត និងការសម្រេចបាននូវគោលបំណងគឺជាបេសកកម្មដ៏លំបាក និងផ្តល់រង្វាន់សម្រាប់សហគ្រាសណាមួយ ហើយយើងនឹងរកឃើញថាឧបសគ្គក្នុងការគ្រប់គ្រងដែលត្រូវជម្នះដើម្បីភាពជោគជ័យមានភាពប្រហាក់ប្រហែលគ្នាគួរឱ្យភ្ញាក់ផ្អើល សម្រាប់ស្ថាប័នទាំងអស់។ តួនាទីរបស់អ្នកគ្រប់គ្រង គឺដើម្បីកំណត់គោលដៅ និងប្រមូលផ្តុំ និងប្រមូលធនធានមនុស្ស សម្ភារៈ ម៉ាស៊ីន វិធីសាស្ត្រ លុយ និងទីផ្សារ ដើម្បីសម្រេចបានលទ្ធផលដែលចង់បានក្នុងដែនកំណត់ដែលបានកំណត់ទុកជាមុននៃពេលវេលា ការខិតខំប្រឹងប្រែង និងការចំណាយ។ មាននិយមន័យជាច្រើននៃការគ្រប់គ្រងមានភាពប្រហាក់ប្រហែលដែលជាទីពេញនិយមបំផុតបានលើកឡើងជាញឹកញាប់នោះគឺ "ការធ្វើអ្វីៗតាមរយៈអ្នកដទៃ"។ និយមន័យនេះ និងនិយមន័យផ្សេងទៀតភាគច្រើនមានគុណសម្បត្តិ និងបញ្ជាក់ពីទិដ្ឋភាពសំខាន់ៗនៃការគ្រប់គ្រង។ សម្រាប់គោលបំណងក្នុងការសរសេរនេះ បានដកស្រង់និយមន័យដូចខាងក្រោម៖

"ការគ្រប់គ្រង គឺជាដំណើរការដាច់ដោយឡែកមួយ ដែលក្នុងនោះរួមមានសកម្មភាពនៃការរៀបចំផែនការ ការរៀបចំ ការអនុវត្ត និងការគ្រប់គ្រង ដែលធ្វើឡើងដើម្បីកំណត់ និងសម្រេចគោលបំណងដែលបានចែងជាមួយនឹងការប្រើប្រាស់មនុស្ស និងធនធានផ្សេងទៀត"[9]។

"ការគ្រប់គ្រងគឺអរូបីវាត្រូវបានគេហៅថាកម្លាំងដែលមើលមិនឃើញ វត្តមានរបស់វាបង្ហាញឱ្យឃើញដោយលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែង សណ្តាប់ធ្នាប់ បុគ្គលិកសាទរ ស្មារតីស្វាហាប់ និងលទ្ធផលការងារគ្រប់គ្រង។ ពេលខ្លះ(ការគ្រប់គ្រងគឺអរូបី)ភាពខ្វះចន្លោះនៃការគ្រប់គ្រងត្រូវបានបង្ហាញលទ្ធផលផ្ទុយគ្នាយ៉ាងច្បាស់" ។ ដើម្បីឱ្យការគ្រប់គ្រងនេះបង្ហាញលទ្ធផលមួយល្អប្រសើរ ។ ការគ្រប់គ្រងមានមុខងារមួយចំនួនផ្សារភ្ជាប់គោលការណ៍ ៤យ៉ាងដូចខាងក្រោម៖

#### ក. ការធ្វើផែនការ

ការធ្វើផែនការគឺជាដំណើរការនៃការកំណត់គោលបំណងរបស់អ្នកគ្រប់គ្រង ដើម្បីឱ្យមានប្រសិទ្ធភាពក្នុងការគ្រប់គ្រង នឹងសម្រេចបាននូវគោលដៅរបស់ក្រុមហ៊ុន។ ការធ្វើផែនការត្រូវបានបែងចែកជា ផែនការប្រចាំថ្ងៃ និងផែនការប្រចាំសប្តាហ៍ ផែនការប្រចាំខែ និងផែនការប្រចាំឆ្នាំ ឬក្រុមហ៊ុនខ្លះអាចមានផែនការរយៈពេលវែងរហូតដល់ទៅ៥ឆ្នាំ ឬ ១០ឆ្នាំ[10]។

#### ខ. ការចាត់ចែង

ការចាត់ចែង ឬការចាត់តាំងគឺជាដំណើរការក្នុងការចាត់ចែងធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងពេលវេលាដើម្បីអនុវត្តន៍ផែនការដែលយើងបានធ្វើដើម្បីឱ្យសម្រេចបានគោលដៅដែលយើងគ្រោងទុក។

[9] រៀបរៀងដោយនិស្សិត ស៊ាង ស្រីមី, ផល ចិន្តា, ថេង ម៉ាល័យ. (ឆ្នាំ2023). *ការគ្រប់គ្រងទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យនិស្សិតជំនាន់ទី20. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៧ ៣៣ទំព័រ. ភ្នំពេញ។

[10] វិទ្យាស្ថាន វ៉ាន់ដា. (ឆ្នាំ2017). *សៀវភៅមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង*. បោះពុម្ពលើកទី០៦. ទំព័រទី០២ ៦៥ទំព័រ.

ផែនការគ្រាន់តែជា គោលការណ៍មួយដែលយើងធ្វើការគ្រោងទុកជាមុន នូវគោលបំណងរបស់ក្រុមហ៊ុន និងជាទិសដៅដែលក្រុមហ៊ុនឆ្ពោះទៅមុខ ដោយការអនុវត្តន៍តាមការគ្រោងទុក[11]។

**គ. ការដឹកនាំ**

ការដឹកនាំគឺ សំដៅដល់ការចូលរួម ការបង្ហាត់បង្រៀន ការជម្រុញលើកទឹកចិត្ត។ ផែនការទាំងឡាយនឹង មិនអាចសម្រេចទៅបាននោះទេប្រសិនបើគ្មានការដឹកនាំត្រឹមត្រូវ។ អ្នកដឹកនាំដែលមានឥទ្ធិពល និងធ្វើឱ្យផែនការសម្រេចបានទាន់ពេលវេលាហើយមានប្រសិទ្ធភាពខ្ពស់។ ការដឹកនាំគឺមានការពាក់ព័ន្ធទៅនឹងស្មារតីសីលធម៌ វិន័យរបស់និយោជិកក្នុងការបំពេញការងារ។ បញ្ហាទាំងនេះទាមទារឱ្យចេះប្រើប្រាស់គ្រប់វិធីដើម្បីទាក់ទាញនិយោជិតឱ្យពេញចិត្ត និងមានការលះបង់កម្លាំងកាយនិងកម្លាំងចិត្តប្រាជ្ញាស្មារតីលើការងារទោះបីជានៅក្នុងកាលៈទេសៈណាក៏ដោយនោះ ទើបយើងទទួលបាននូវលទ្ធផលល្អប្រសើរ និងជាអ្នកគ្រប់គ្រងដែលមានសមត្ថភាព និងប្រសិទ្ធភាពខ្ពស់[12]។

**ឃ. ការត្រួតពិនិត្យ**

រាល់ផែនការសម្រេចបានជោគជ័យឬមិនជោគជ័យ សុទ្ធតែត្រូវបានធ្វើការត្រួតពិនិត្យឡើងវិញដើម្បីផ្ទៀងផ្ទាត់នូវការអនុវត្ត បានតាមការអនុម័តទៅតាមផែនការ ការគ្រោងទុកនោះបានទាន់ពេលវេលាដែរ ឬយ៉ាងណាដើម្បីធ្វើការកែលម្អនូវភាពខ្វះខាត ខាងផ្នែកបរិមាណ គុណភាព ពេលវេលាការចំណាយផ្សេងៗ[13]។

## ២.២ នីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន

### ២.២.១ និយមន័យ

នីតិ គឺជាបណ្តុំវិធានគតិយុត្តដែលមានចំណងសិទ្ធិ និងកាតព្វកិច្ចមានអានុភាពឱ្យចាប់បង្ខំមានលក្ខណៈទូទៅមិនចំពោះនិងមានគោលដៅរៀបចំសណ្តាប់ធ្នាប់ឱ្យមានរបៀបរៀបរយក្នុងសង្គម[14]។

នីតិ គឺជាបណ្តុំវិធានគតិយុត្តទាំងឡាយដែលបង្កើតឡើងដើម្បី រក្សាសណ្តាប់ធ្នាប់សង្គម[15]។

នីតិ មានន័យថា ច្បាប់ឧបាយជាគ្រឿងណែនាំ បែបផែន ទំនៀមទម្លាប់ ប្រពៃណី [16]។

### ២.២.២ ប្រភពនីតិ

- តាមការវិវត្តរបស់សង្គមនិងសហគមន៍
- ការរស់នៅហួសព្រំដែននៃសេរីភាពរបស់មនុស្ស
- មនុស្សចង់មាន ចង់បានហួសហេតុ
- មនុស្សមានជម្លោះរវាងគ្នានិងគ្នា
- នៅក្នុងសង្គមនោះមានសមាជិកច្រើន ការផ្គត់ផ្គង់មិនគ្រប់គ្រាន់តាមតម្រូវការ
- ការប្រើប្រាស់អំណាចផ្តាច់ការឈានទៅដល់ការបង្កើតបទដ្ឋានដែលមានលក្ខណៈទំនើប

[11] វិទ្យាស្ថាន វ៉ាន់ដាបោះ. (ឆ្នាំ2017). *សៀវភៅមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង*. ពុម្ពលើកទី០៦.ទំព័រទី០២

[12] ដដែល

[13] ដដែល

[14] KH INFO. (2022, March 13). *នីតិ ? ?* Retrieved from https://url-shortener.me/4AXY

[15] ដដែល

[16] KHSearch. (2019, February 02). *តើអ្វីទៅជានីតិ?* Retrieved from https://www.khsearch.com/qna/25599

- បទដ្ឋានទំនើប គឺជាការថែរក្សាសណ្តាប់ធ្នាប់ សេចក្តីថ្លៃថ្នូរ របៀបរៀបរយ និងសន្តិភាពជម្រុញឱ្យមានការកកើតនៃនីតិ
- ការកកើតនីតិ គឺមិនមានលក្ខណៈវណ្ណៈ និងជាឧបករណ៍របស់វណ្ណៈខ្លាំង ឬខ្សោយណាមួយឡើយ
- ស្មារតីទូទៅច្បាប់តែងតែលើកតម្កើងដល់តម្លៃសីលធម៌ សេដ្ឋកិច្ច និងនយោបាយរបស់សង្គម
- ច្បាប់ពីប្រទេសមួយទៅប្រទេសមួយទៀតតែងតែមានលក្ខណៈខុសគ្នា
- ទោះបីជាយ៉ាងណាក៏ដោយ ក្នុងករណីដែលសង្គមមានលក្ខណៈផ្លាស់ប្តូរពេលគឺច្បាប់ក៏មានការផ្លាស់ប្តូរដែរ
- តាមផ្លូវច្បាប់ និងតាមការស្រាវជ្រាវកន្លងមក នីតិមានប្រភពសំខាន់ៗ ចំនួនពីរយ៉ាងគឺ
  ១. ប្រភពសរសេរជាលាយលក្ខណ៍អក្សរ
  ២. ប្រភពមិនសរសេរជាលាយលក្ខណ៍អក្សរ[17] ។

**២.២.៣ តួនាទីរបស់នីតិ**

នីតិមានតួនាទីជាច្រើនដូចជាៈ

- មានរបៀបរៀបរយល្អក្នុងសង្គមជៀសវាងជម្លោះដោះស្រាយដោយសន្តិវិធី
- ការប្រាស្រ័យទាក់ទងគ្នារវាងមនុស្ស និងមនុស្ស
- កំណត់នូវព្រំដែនអំណាចនិងអំពើរបស់អ្នកដឹកនាំ និងសម្រួលផ្នែកតម្លៃសីលធម៌
- មិនឱ្យអ្នកដឹកនាំធ្វើអ្វីតាមអំពើចិត្ត
- ការពារចំពោះអ្នកទន់ខ្សោយ និងលើកស្ទួយយុត្តិធម៌
- ជួយសម្រួលឱ្យមានការចូលរួមពីប្រជាជនឱ្យបានច្រើន
- ការពារ និងផ្តល់សេរីភាពដល់បុគ្គលម្នាក់ៗ[18] ។

**២.២.៤ ប្រភេទនៃនីតិ**

បច្ចុប្បន្នប្រទេសកម្ពុជា គឺជាប្រទេសមួយកាន់ប្រព័ន្ធច្បាប់ស៊ីវិល តែដោយសារការវិវត្តខ្លួនកន្លងមកឆ្លងកាត់នូវដំណាក់កាលលំបាកៗ និងមានមនោគមវិជ្ជាខុសៗគ្នា ដូចជានៅសម័យមុនឆ្នាំ១៩៧៥។ ក្រោយមកឆ្នាំ១៩៧៥ រហូតមកដល់ឆ្នាំ១៩៧៩ និងក្រោយឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៨ ក៏ទទួលឥទ្ធិពលខ្លះពីប្រព័ន្ធច្បាប់ផ្សេងៗ ។

**ច្បាប់ ៖** គឺជាឆន្ទៈរួមរបស់ប្រជាពលរដ្ឋ និយមន័យនេះត្រូវបានផ្តល់ដោយរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ហេតុនេះហើយបានជាគេសន្មតថា បើចេះច្បាប់ ឬមិនចេះច្បាប់ក៏គេចាត់ទុកថាចេះច្បាប់ទាំងអស់គ្នាដែរ។

- នីតិត្រូវបានបែងចែកជា២គឺ នីតិអន្តរជាតិ និងនីតិជាតិ។
- នីតិអន្តរជាតិត្រូវបានបែងចែកជា២ទៀតគឺនីតិអន្តរជាតិសាធារណៈ និងនីតិអន្តរជាតិឯកជន។

ចំពោះនីតិជាតិវិញបែងចែកជា២ផងដែរគឺ នីតិជាតិសាធារណៈ និងនីតិជាតិឯកជន។

[17] រៀបរៀងដោយនិស្សិត សេង នាង, ធន ផាន់នី, អ៊ឹម ម៉ីលិ, ឈឹម មួយហ៊ាង, ងួន វណ្ណដារី, អ៊ែល លីណា. (ឆ្នាំ២០២៣). *ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. និស្សិតជំនាន់ទី២០ ទំព័រទី៥. ៣៣ទំព័រ. ភ្នំពេញ។

[18] រៀបរៀងដោយនិស្សិត សេង នាង, ធន ផាន់នី, អ៊ឹម ម៉ីលិ, ឈឹម មួយហ៊ាង, ងួន វណ្ណដារី, អ៊ែល លីណា. (ឆ្នាំ២០២៣). *ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. និស្សិតជំនាន់ទី២០ ទំព័រទី៦. ៣៣ទំព័រ. ភ្នំពេញ។

**នីតិជាតិសាធារណៈ** គឺជាវិធានទាំងឡាយណាដែលមាននៅក្នុងរដ្ឋមួយសំដៅរៀបចំ និងការប្រព្រឹត្តរបស់អង្គការស្ថាប័នសាធារណៈ ព្រមទាំងសម្រាប់គ្រប់គ្រងទំនាក់ទំនងរវាងអង្គការរដ្ឋ និងបុគ្គលិករដ្ឋជាមួយនិង ពលរដ្ឋរបស់ខ្លួន។ ឧទាហរណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ គឺជាច្បាប់រៀបចំអង្គការដែលមានចែងពីការអនុវត្តន៍អំណាច មុខងារ តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការអភិវឌ្ឍមូលដ្ឋានឱ្យមានការរីកចម្រើនប្រកបដោយចីរភាព និងមានគណនេយ្យភាពចំពោះការបំពេញតួនាទីរបស់ខ្លួន ជាមួយច្បាប់នេះ ក៏មានចែងផងដែរអំពីការចូលរួមរបស់ប្រជាពលរដ្ឋ ទៅក្នុងដំណើរនៃការកសាងផែនការនិងការងារផ្សេងទៀតក្នុងឃុំសង្កាត់ផងដែរ។

នីតិជាតិសាធារណៈមានជារួមដូចជា នីតិរដ្ឋធម្មនុញ្ញ នីតិរដ្ឋបាល នីតិព្រហ្មទណ្ឌ នីតិហិរញ្ញវត្ថុ។

- **នីតិរដ្ឋធម្មនុញ្ញ៖** គឺជាទូទៅគេបានអោយនិយមន័យរដ្ឋធម្មនុញ្ញថា ជាច្បាប់គ្រឹះនិងជាច្បាប់កំពូលនៃរដ្ឋដែលជាទូទៅតែងកំណត់នូវរចនាសម្ព័ន្ធមុខងារជាមូលដ្ឋាននៃរដ្ឋកំណត់នូវសិទ្ធិនិងកាតព្វកិច្ចជាមូលដ្ឋានរបស់ប្រជាពលរដ្ឋចំពោះរដ្ឋ។
- **នីតិរដ្ឋបាល៖** គឺជាវិធានទាំងឡាយណាសម្រាប់រៀបចំការកំណត់នូវទំនាក់ទំនងរវាងអាជ្ញាធរនិងប្រជាពលរដ្ឋរបស់ខ្លួន។
- **នីតិព្រហ្មទណ្ឌ៖**គឺជាវិធានទាំងឡាយណាសំដៅលើការផ្តន្ទាទោសដែលប្រព្រឹត្ត ឬមានចេតនាប្រព្រឹត្តអំពើទុច្ចរិតសំដៅធ្វើឱ្យសង្គមគ្មានសុវត្ថិភាពនិងគ្មានរបៀបរៀបរយនៅក្នុងសង្គម។
- **នីតិហិរញ្ញវត្ថុ៖** គឺជាវិធានទាំងឡាយNaដែលសំដៅ លើការធានាការគ្រប់គ្រងនិងរៀបចំប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងនីតិវិធីរបស់វា។ ចំណែកឯនីតិឯកជនវិញមានជារួមដូចជា នីតិរដ្ឋប្បវេណី នីតិការងារ នីតិនីរភ័យសង្គម នីតិពាណិជ្ជកម្ម។
- **នីតិរដ្ឋប្បវេណី ៖** គឺជាវិធាននានាសម្រាប់អនុវត្តរបស់ប្រជាពលរដ្ឋក្នុងគ្រប់ករណីទាំងអស់លើកលែងតែមានបទប្បញ្ញត្តិពិសេសផ្សេងទៀត។
- **នីតិការងារ៖** គឺជានីតិពិសេសដែលជាមែកធាងដែលកើតចេញពីនីតិរដ្ឋប្បវេណី ដើម្បីគ្រប់គ្រងទំនាក់ទំនងរវាងម្ចាស់សហគ្រាសនិងកម្មករ។
- **នីតិនីរភ័យសង្គម៖** គឺជាវិធានទាំងឡាយណាដែលបានទាក់ទិនទៅនឹងការធានារ៉ាប់រងដល់អ្នកធ្វើការងារជាម្ចាស់និងកម្មករនៅពេលមានជំងឺ ការសម្រាលកូន ការចិញ្ចឹមកូននៅពេលមានគ្រោះថ្នាក់ការងារនៅពេលបាត់បង់ការងារជាដើម។
- **នីតិពាណិជ្ជកម្ម៖** នៅក្នុងនីតិឯកជន មាននីតិរដ្ឋប្បវេណី នីតិព្រហ្មទណ្ឌ នីតិកិច្ចការជំនួញ។ នីតិកិច្ចការជំនួញនេះមាននីតិពាណិជ្ជកម្ម ហើយដែលនៅក្នុងនីតិពាណិជ្ជកម្មមាននីតិក្រុមហ៊ុនជាដើម[19]។

## ២.៣ ផលប្រយោជន៍នៃការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន

### ២.៣.១ និយមន័យនៃទ្រព្យសកម្ម

ទ្រព្យសកម្ម គឺជាទ្រព្យដែលត្រូវបានប្រើដោយអាជីវកម្មនៅក្នុងប្រតិបត្តិការងារប្រចាំថ្ងៃរបស់ខ្លួន។

[19] TNAOT. (2019, September 17). *អ្វីទៅដែលហៅថា "នីតិ" ហើយ "នីតិ" មានអ្វីខ្លះ ?* Retrieved from https://www.tnaot.com/km/m/detail/article/2127308

ទ្រព្យសកម្ម អាចមានលក្ខណៈជាក់ស្តែងដូចជាអគារឬគ្រឿងបរិក្ខារដូចជាប៉ាតង់ឬសិទ្ធិអ្នកនិពន្ធ[20] ។

ទ្រព្យសកម្ម គឺជាការកត់ត្រាក្នុងផ្នែកគណនេយ្យសំដៅទៅលើទ្រព្យសម្បត្តិនានាជាកម្មសិទ្ធិរបស់ក្រុមប្រឹក្សាដែលមានតម្លៃមួយពិតប្រាកដរួមទាំងប្រាក់កាសផង[21]។

ទ្រព្យសកម្ម មានន័យថាប្រាក់និងអ្វីៗផ្សេងទៀត ដែលជាកម្មសិទ្ធិរបស់រូបវន្តបុគ្គលឬនីតិបុគ្គលហើយដែលអាចទូទាត់បំណុល ប្រើប្រាស់ទទួលអត្ថប្រយោជន៍ និងបង្កើនប្រាក់ចំណូលបាន។

ទ្រព្យសកម្ម គឺជារបស់មានតម្លៃដែលអាចប្តូរទៅជាសាច់ប្រាក់បាន។

ទ្រព្យសកម្មគឺជាធនធានដែលគេអាចប្រើប្រាស់ដើម្បីបង្កើតប្រាក់ចំណូលឬកាត់បន្ថយប្រាក់ចំណាយ និងអាចនៅតែរក្សាបាននូវតម្លៃរបស់វាដដែល[22]។

ទ្រព្យសកម្ម គឺជាធាតុផ្សំដ៏សំខាន់សម្រាប់សហគ្រាសជោគជ័យណាមួយ ដោយសារទ្រព្យនេះបានបម្រើជាធនធានដ៏មានតម្លៃដែលក្រុមហ៊ុនប្រើប្រាស់ដើម្បីជម្រុញកំណើន បង្កើតតម្លៃ និងនិរន្តរភាពប្រតិបត្តិការរបស់ពួកគេ ។

ទ្រព្យសកម្ម គឺជាធនធានដែល មានតម្លៃសេដ្ឋកិច្ច ដែលបុគ្គលក្រុមហ៊ុន ឬប្រទេសមួយកាន់កាប់ ឬគ្រប់គ្រងដោយរំពឹងថាវានឹងផ្តល់អត្ថប្រយោជន៍នាពេលអនាគត[23]។

**២.៣.២ ប្រវត្តិនៃទ្រព្យសកម្ម**

មុនពេលដែលគោលការណ៍ទ្រឹស្តីគណនេយ្យនឹងបំពេញគណនេយ្យទទួលយកបាន ជាទូទៅមិនបានបង្កើតឡើងនៅឡើយទេ និយមន័យនៃទ្រព្យសកម្មជាញឹកញាប់ភ្ជាប់ជាមួយនឹងអ្នកសេដ្ឋកិច្ច ដូចជាអ្នកវិទ្យាសាស្ត្រអាមេរិកគណនេយ្យ Sprague (CES prague ) ដែលបានបោះពុម្ពនៅឆ្នាំ១៩០៧ «គោលការណ៍គណនី( ទស្សនវិជ្ជានៃគណនី ) សៀវភៅទ្រព្យសកម្មមួយត្រូវបានកំណត់ប្រមូលផ្តុំសេវាកម្មដែលផ្តល់ និងសេវាកម្មដែលត្រូវបានទិញកាលពីមុន»។ នៅក្នុងឆ្នាំ១៩២៩ បានចេញផ្សាយ “ គណនេយ្យសេដ្ឋកិច្ច ”។ ដើម្បីជាប្រយោជន៍ដល់បុគ្គលម្នាក់ ឬបុគ្គលដែលអាចមើលឃើញ បានគេមើលឃើញនិយមន័យទាំងនេះ និងអ្នកប្រាជ្ញផ្នែកសេដ្ឋកិច្ចទូទៅដែលបានតភ្ជាប់ជាប់មក នៅក្នុង៤០-៥០ ឆ្នាំនៃសំណុំបែបបទមូលដ្ឋាន GAAP និយមន័យនៃទ្រព្យសម្បត្តិនេះផលិតបាននូវការផ្លាស់ប្តូរជាមូលដ្ឋាន។ ហើយត្រូវបានបោះពុម្ពផ្សាយនូវលក្ខខណ្ឌដំបូង ដែលមាននាមជាគណៈកម្មាធិការគណនេយ្យ សមាគមន៍ គណនេយ្យ AICPA កម្មសិទ្ធិចេញផ្សាយនៅក្នុងឆ្នាំ១៩៥៣ បានប្រែក្លាយទៅជានិយមន័យនៃទ្រព្យសម្បត្តិពី ចំណុចគណនេយ្យនៃច្បាប់ទិដ្ឋភាព។ ការប្រកាសយកគោលការណ៍ទ្រព្យសម្បត្តិដែលត្រូវបានផ្អែកលើក្បួនច្បាប់ ឬគោលការណ៍គណនេយ្យនឹងនៅក្នុងសៀវភៅនៃតុល្យភាពឥណពន្ធគណនីដែលបានធ្វើឡើងដើម្បី ឆ្ពោះទៅមុខហើយធ្វើជាតំណាងអ្វីមួយ។ ក្រុមប្រឹក្សាភិបាលសហរដ្ឋអាមេរិក នៅក្នុងគោលការណ៍គណនេយ្យ លើកទីបួនឆ្នាំ ១៩៧០ ដែលបានចេញផ្សាយនូវរបាយការណ៍ជឿថា ធនធានសេដ្ឋកិច្ចនៃទ្រព្យសកម្មរបស់សហគ្រាស ដែលមានការទទួលស្គាល់ ដោយអនុលោមតាមគោលការណ៍គណនេយ្យទូទៅនឹងការវាស់វែង។ ទ្រព្យសម្បត្តិនេះ គឺជាប្រធានបទដ៏ជាក់លាក់មួយ ដោយសារតែប្រតិបត្តិការពីអតីត

[20] Math and Money. (2018, September 18). តើអ្វីទៅជា ទ្រព្យសកម្ម ឬ Active Asset? Retrieved from https://mathnmoney.blogspot.com/2018/09/active-asset.html#:~%F0%9F%93%9D

[21] អភិបាលកិច្ចល្អ. (2018, July 16). អ្វី *ទៅហៅថា "ទ្រព្យសកម្ម "*? Retrieved from https://url-shortener.me/4B0U

[22] HeartBook Business. (2024, July 28). *ទ្រព្យសកម្ម*. Retrieved from https://url-shortener.me/4B1Q

[23] Investorpedia. (2024, June 27). What Is an Assets? Retrieved from https://www.investopedia.com/terms/a/asset.asp

កាល ឬព្រឹត្តិការណ៍និង សំណុំបែបបទនឹងជារាងកាយសំខាន់ជាកម្មសិទ្ធិ ដែលអាចជាប្រយោជន៍ទៅដល់សេដ្ឋកិច្ច។ នៅពេលដែលប្រទេសផ្សេងៗទៀត និងអង្គការអន្តរជាតិមានការស្រាវជ្រាវទៅនឹងការអភិវឌ្ឍនៃ វចនាសម្ព័ន្ធទស្សនៈគណនេយ្យហិរញ្ញវត្ថុមានការខុសប្លែកគ្នាដីក្រៃដែលបានអនុម័ត និយមន័យនេះ និយមន័យនៃលក្ខណៈជាមូលដ្ឋាននៃទ្រព្យសកម្មសម្រាប់ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត[24]។

**២.៣.៣ ប្រភេទនៃទ្រព្យសកម្ម**

សហគ្រាសគ្រប់ប្រភេទតែងតែមានទ្រព្យសកម្មផ្សេងៗពីគ្នា ហើយមិនអាចដំណើរការបានត្រឹមត្រូវនោះទេ។ ទ្រព្យសកម្ម ត្រូវបានកំណត់ជាប្រពៃណីថាជាវត្ថុមានតម្លៃគ្រប់គ្រាន់ ឬគ្រប់គ្រងដោយអង្គភាពបុគ្គល ឬរដ្ឋាភិបាល ហើយវាត្រូវបានគេរំពឹងថានឹងផ្តល់អត្ថប្រយោជន៍ ដែលអាចវាយតម្លៃបាននាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ វាក៏អាចជាអ្វីមួយដែលមិនមានរូបរាងកាយ ឧទាហរណ៍ ធនធាន ឬយុទ្ធសាស្ត្រ។ នោះហើយជាមូលហេតុដែលទ្រព្យសកម្មទាំងអស់ ត្រូវបានបែងចែកទៅជាពីរប្រភេទធំៗ៖ទ្រព្យសកម្មរូបី និងទ្រព្យសកម្មអរូបី។

**ទ្រព្យសកម្មរូបី៖** គឺជាបំណែកនៃទ្រព្យសម្បត្តិដែលមានឥទ្ធិពលទៅលើតម្លៃរបស់ក្រុមហ៊ុន។ ទ្រព្យសម្បត្តិជាក់ស្តែងអាចរួមមាន៖

- ទ្រព្យសម្បត្តិដី
- អគារសាជីវកម្ម
- គ្រឿងចក្រ សារពើភ័ណ្ឌ និងឧបករណ៍
- សាច់ប្រាក់ និងសមមូលរបស់វា។
- មូលបត្រនៅលើភាគហ៊ុនសាធារណៈ/ការដោះដូរសញ្ញាប័ណ្ណ។

ទ្រព្យសកម្មជាក់ស្តែងត្រូវបានរំលស់ជាធម្មតា។ ការរំលស់ គឺជាពាក្យដែលបង្កើតឡើងដើម្បីកំណត់ដំណើរការនៅពេលដែលតម្លៃនៃទ្រព្យសកម្មរូបីត្រូវបានបែងចែកពេញមួយជីវិតដែលមានប្រយោជន៍របស់វា។ ទ្រព្យសកម្មមានទំនោរបាត់បង់តម្លៃរបស់ពួកគេ ក្នុងរយៈពេលដ៏ខ្លីជាធម្មតាក្នុងមួយឆ្នាំ។ ដោយផ្អែកលើការបំប្លែងរបស់ពួកគេ ទ្រព្យសកម្មរូបីត្រូវបានបែងចែកទៅជាពីរប្រភេទ៖ទ្រព្យសកម្មជាក់ស្តែងបច្ចុប្បន្ន និងទ្រព្យសកម្មរូបីថេរ។

ផ្ទុយទៅវិញ ទ្រព្យសកម្មថេរឬរយៈពេលវែង មិនមែនជាការងាយស្រួលក្នុងការបំប្លែងទៅជាលុយនោះទេ។ ដំណើរការបម្លែងមានរយៈពេលច្រើនជាងមួយឆ្នាំ។ ឧទាហរណ៍ ដែលគួរឱ្យកត់សម្គាល់បំផុតនៃទ្រព្យសកម្មរយៈពេលវែងគឺអគារសាជីវកម្ម ការិយាល័យ ទ្រព្យសម្បត្តិដី និងឧបករណ៍ជាក់លាក់។ ទ្រព្យសកម្មថេរអនុញ្ញាតឱ្យអាជីវកម្មដំណើរការដោយគ្មានការពន្យាពេល។

**ទ្រព្យសកម្មអរូបី** គឺមានដូចខាងក្រោម ៖

- សុច្ឆន្ទៈ (កេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន)
- ប៉ាតង់
- ម៉ាក

[24] រៀបរៀងដោយនិស្សិត ស៊ាង ស្រីមី, ផល ចិន្តា, ថេង ម៉ាល័យ. (ឆ្នាំ2023). *ការគ្រប់គ្រងទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យនិស្សិតជំនាន់ទី20. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៧ ៣៣ទំព័រ. ភ្នំពេញ។

- កម្មសិទ្ធិបញ្ញាសាជីវកម្ម
- អាថ៌កំបាំងពាណិជ្ជកម្ម
- រក្សាសិទ្ធិ
- ពាណិជ្ជសញ្ញា
- អាជ្ញាប័ណ្ណ [25]។

[25]LiteFinance. Jana Kane. (2024, November 08). ទ្រព្យសកម្មរូបីទល់នឹងទ្រព្យអរូបី៖តើវាខុសគ្នាដូចម្តេច? Retrieved from https://litefinance-kh.com/blog/for-beginners/tropyosambotte-roubei-ning-aroubei/

# ជំពូកទី៣
# ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន
## ៣.១ ស្ថានភាពទូទៅរបស់ធនាគារឯកទេស ខេប៊ី ដេហាន




ធនាគារឯកទេស ខេប៊ី ដេហាន បានចាប់ផ្តើមដំណើរការអាជីវកម្មរបស់ខ្លួនចាប់តាំង ពីខែមីនាឆ្នាំ 2018 ជាមួយនឹងការវិនិយោគដើមទុនដំបូងបំផុតចំនួន 74.2 លានដុល្លារអាមេរិកតែប៉ុណ្ណោះ។ ចាប់តាំងពីពេលនោះមក យើងបានលះបង់ខ្លួនរបស់យើង ក្នុងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនកម្ពុជា តាមរយៈការផ្តល់ហិរញ្ញប្បទានរថយន្តថ្មី និងរថយន្តប្រើប្រាស់រួច(មួយទឹក) កម្ចីគ្រឿងយន្តកសិកម្ម កម្ចីទិញផ្ទះ និងអចលនទ្រព្យជាដើម។ ជាលទ្ធផលនៃធន្ទៈដ៏មុតមាំរបស់យើង ឥឡូវនេះធនាគារឯកទេស ខេប៊ី ដេហាន បានរីកចម្រើនទៅជាស្ថាប័នហិរញ្ញវត្ថុមួយដ៏រឹងមាំ ដែលមានទ្រព្យសកម្មសរុបឈានរហូតដល់ 232.4 លានដុល្លារអាមេរិក។ ធនាគារឯកទេស ខេប៊ី ដេហាន គឺជាធនាគារដែលមានឯកទេសក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុដល់អតិថិជននៅកម្ពុជា។ ធនាគារបានប្តេជ្ញាចិត្តក្នុងការផ្តល់សេវាកម្មឥណទានរថយន្ត អាជីវកម្មប័ណ្ណ និងកម្ចីគេហដ្ឋាន ដើម្បីបំពេញតម្រូវការរបស់អតិថិជន។ ជាមួយនឹងការបញ្ចេញផលិតផលហិរញ្ញវត្ថុ ដែលមានភាពច្នៃប្រឌិតខ្ពស់ និងអាចគ្រប់គ្រងបានយ៉ាងស្រួល។ ផ្តល់ជូនជម្រើសនានារួមមានឥណទានអាជីវកម្មឥណទានកសិកម្ម ឥណទានសម្រាប់ការកែលម្អផ្ទះ និងឥណទានសម្រាប់ក្រុមជានា។

ធនាគារមានចក្ខុវិស័យដឹកនាំដោយអ្នកជំនាញកម្រិតពិភពលោក និងរបបគំហើញថ្មីៗ ដើម្បីក្លាយខ្លួនជាដៃគូដ៏រីករាយ និងគួរជាទីទុកចិត្តរបស់អតិថិជន។ បេសកកម្មរបស់ធនាគារគឺផ្តល់សេវាកម្មហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់ និងបំពេញតម្រូវការរបស់អតិថិជន។ ធនាគារឯកទេស ខេប៊ី ដេហាន ធានាថាជំនួយហិរញ្ញវត្ថុរបស់ខ្លួននឹងឆ្ពោះទៅរកការអភិវឌ្ឍវិស័យអាជីវកម្ម និងការបង្កើនផលិតភាពសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា។

ធនាគារឯកទេស ខេប៊ី ដេហាន ជាធនាគារដែលមានឯកទេសខ្ពស់ និងបន្តពង្រីកកម្រិតសេវាកម្ម និងកែលម្អប្រព័ន្ធបច្ចេកទេសនៅក្នុងការប្រតិបត្តិការដែលមានសមត្ថភាព ដើម្បីធានាថាអតិថិជនទទួលបានសេវាកម្មប្រកបដោយប្រសិទ្ធភាពនិងភាពទំនួលខុសត្រូវ។

ការគ្រប់គ្រងឧបករណ៍ហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ធនាគារឯកទេស ខេប៊ី ដេហាន គឺជាភាគីសំខាន់មួយក្នុងវិស័យហិរញ្ញវត្ថុ។ ព្រមទាំងធនាគារនេះក៏ផ្តល់ការប្រឹក្សា និងជំនួយទៅកាន់អតិថិជនក្នុងការកំណត់ផែនការវិនិយោគ និងធានាថាការងារផ្សេងៗរបស់ពួកគេបានជោគជ័យ។

សេវាប្រតិបត្តិការធនាគារឯកទេស ខេប៊ី ដេហានមានដូចខាងក្រោម៖

- ឥណទានរថយន្ត
- ឥណទានទូទៅ
- ឥណទានគ្រឿងយន្តកសិកម្ម
- ភតិសន្យារថយន្ត
- ភតិសន្យាម៉ូតូ ។

**៣.១.១ ប្រវត្តិរបស់ធនាគារឯកទេស ខេប៊ី ដេហាន**

ធនាគារឯកទេស ខេប៊ី ដេហាន (KDSB) ត្រូវបានបង្កើតឡើងក្នុងខែកក្កដា ឆ្នាំ2008 ក្នុងនាមជាធនាគារឯកទេស តូម៉ាតូ។ បន្ទាប់មក ក្នុងខែមីនា ឆ្នាំ2018 ធនាគារនេះបានផ្លាស់ប្តូរទៅជាធនាគារឯកទេស ខេប៊ី ដេហាន ដោយទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា។

ធនាគារឯកទេស ខេប៊ី ដេហាន គឺជាអាជីវកម្មបណ្តាក់ទុនរួមគ្នារវាងក្រុមហ៊ុន KB Kookmin Card និងធនាគារ Indochina Bank។ KB Kookmin Card គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ KB Financial Group ដែលជាក្រុមហ៊ុនហិរញ្ញវត្ថុឈានមុខគេនៅប្រទេសកូរ៉េខាងត្បូង។ ធនាគារ Indochina Bank មានបទពិសោធន៍ជោគជ័យជាច្រើនឆ្នាំក្នុងការផ្តល់ឥណទានរថយន្តនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ធនាគារឯកទេស ខេប៊ី ដេហាន មានឯកទេសក្នុងការផ្តល់ឥណទានរថយន្ត ឥណទានអាជីវកម្ម និងកម្ចីគេហដ្ឋាន។ សម្រាប់ការិយាល័យកណ្តាលរបស់ធនាគារឯកទេស ខេប៊ី ដេហាន ស្ថិតនៅអគារលេខ ១ ជាន់ទី២០ ទី២១ និងទី២២ ផ្លូវលេខ៣៦០ ភូមិ៨ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ចក្ខុវិស័យរបស់ធនាគារឯកទេសខេប៊ី ដេហាន គឺក្លាយខ្លួនជាធនាគារឯកទេសតាមរយៈបទពិសោធន៍ជោគជ័យពីប្រទេសកូរ៉េខាងត្បូង។ បេសកកម្មរបស់ធនាគារនេះ គឺធ្វើឱ្យអតិថិជនមានអារម្មណ៍រំភើបរីករាយតាមរយៈការផ្តល់សេវាកម្មឆាប់រហ័ស និងមានភាពបត់បែន ដូចជាការបើកបររថយន្តទំនើបនៅលើផ្លូវហាយវេយ៉ាងដូច្នោះដែរ។ ក្នុងខែធ្នូ ឆ្នាំ 2024 ធនាគារឯកទេស ខេប៊ី ដេហាន បានបញ្ចប់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាជាមួយក្រុមហ៊ុន អាយ-ហ្វាយនែន លីស៊ីង ភីអិលស៊ី (IFL) ដែលជាក្រុមហ៊ុនឯកទេសខាងភតិសន្យាហិរញ្ញវត្ថុ។ ការបញ្ចូលគ្នានេះ បានធ្វើឱ្យ ធនាគារឯកទេស ខេប៊ី ដេហាន ក្លាយជាធនាគារឯកទេសឈានមុខគេនៅកម្ពុជា។

ដោយផ្អែកលើបទពិសោធន៍ និងការគាំទ្រពីក្រុមហ៊ុនមេ ធនាគារឯកទេស ខេប៊ី ដេហាន បានក្លាយជាធនាគារដែលអាចផ្តល់សេវាកម្មរហ័សទាន់ចិត្ត និងមានភាពបត់បែន ដើម្បីធ្វើឱ្យសង្គមហិរញ្ញវត្ថុនៃប្រទេសកម្ពុជាកាន់តែប្រសើរឡើង។

### ៣.១.២ គោលនយោបាយរបស់ធនាគារឯកទេស ខេប៊ី ដេហាន

ធនាគារឯកទេស ខេប៊ី ដេហាន មានគោលនយោបាយដែលផ្តោតលើការផ្តល់សេវាកម្មហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់ និងសមស្របទៅនឹងតម្រូវការរបស់អតិថិជននៅក្នុងប្រទេសកម្ពុជា។ ធនាគារនេះមានគោលបំណងចម្បងក្នុងការជួយពង្រីកវិស័យអាជីវកម្ម និងកសិកម្មនៅកម្ពុជាដោយផ្តល់ជូនសេវាកម្មឥណទាននានា និងផលិតផលហិរញ្ញវត្ថុផ្សេងៗ ដែលអាចជួយឱ្យអតិថិជនកសាង និងអភិវឌ្ឍន៍អាជីវកម្មរបស់ពួកគេ។

គោលនយោបាយសំខាន់ៗរបស់ធនាគារឯកទេស ខេប៊ី ដេហាន មានដូចខាងក្រោមៈ

**១. ការផ្តល់សេវាកម្មដែលមានគុណភាពខ្ពស់**

ធនាគារប្តេជ្ញាចិត្តក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុដែលមានស្ថិរភាព និងគុណភាពខ្ពស់ ដើម្បីធានាថាអតិថិជនទទួលបានបទពិសោធន៍ល្អបំផុតនៅពេលប្រើប្រាស់សេវាកម្មរបស់ធនាគារ។

**២.គោលបំណងសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម និងអាជីវកម្មតូច និងមធ្យម** (SMEs)

ធនាគារប្រាកដថាការផ្តល់សេវាកម្មឥណទាន និងជំនួយដទៃទៀតសម្រាប់អាជីវកម្មតូច និងមធ្យម និងកសិករបានជោគជ័យ។ ជាផ្នែកមួយនៃគោលនយោបាយ, ធនាគារឯកទេស ខេប៊ី ដេហាន កំពុងសម្រេចថាអាជីវកម្មនៅក្នុងវិស័យពាណិជ្ជកម្ម និងកសិកម្មបានមានឱកាសរីកចម្រើន។

**៣. ការប្រើប្រាស់បច្ចេកវិទ្យាពិសេស និងសមត្ថភាពកម្រិតពិភពលោក**

ធនាគារឯកទេស ខេប៊ី ដេហាន ជឿជាក់ថាការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងការបង្កើតប្រព័ន្ធប្រតិបត្តិការដែលមានសមត្ថភាព ធនាគារនឹងធានាបានសេវាកម្មរឹងមាំ និងមានប្រសិទ្ធភាពជាងមុន។

**៤. ការគាំទ្រអតិថិជន និងដៃគូយ៉ាងខ្ពស់**

ធនាគារដើរតួនាទីសំខាន់ក្នុងការផ្តល់ការប្រឹក្សា និងជំនួយដល់អតិថិជនក្នុងការកំណត់ផែនការហិរញ្ញវត្ថុរបស់ពួកគេ។ ការប្រើប្រាស់សេវាកម្មធនាគារដោយអតិថិជនគឺជាចំណុចមួយដែលធនាគារត្រូវចូលរួមក្នុងការសាងសង់ទំនាក់ទំនងល្អជាមួយអតិថិជននិងដៃគូដោយស្មោះដៃ។

**៥. ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុដែលមានសមត្ថភាព**

ធនាគារបានសាងសង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាការប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ ត្រូវបានគ្រប់គ្រងក្នុងកម្រិតខ្ពស់និងមានភាពសុវត្ថិភាព។

**ក. ទស្សនៈវិស័យ**

ជាក្រុមហ៊ុនហិរញ្ញវត្ថុយូរអង្វែងមួយតាមរយៈរបបគំហើញថ្មីៗឈានមុខគេដែលផ្លាស់ប្តូរគំរូហិរញ្ញវត្ថុដោយអ្នកជំនាញដែលមានវិជ្ជាជីវៈច្បាស់លាស់ដឹកនាំដោយអ្នកជំនាញកម្រិតពិភពលោកដើម្បីក្លាយខ្លួនជាដៃគូដ៏រីករាយ និងគួរជាទីទុកចិត្តរបស់អតិថិជន។

**ខ. បេសកកម្ម**

ការផ្តល់សេវាកម្មហិរញ្ញវត្ថុជាច្រើនប្រភេទដល់អតិថិជន និងសហគ្រាសខ្នាតតូច មធ្យម និងធំដែលមានតម្រូវការថវិការ ដោយធានាបានលទ្ធផលប្រតិបត្តិការកម្រិតខ្ពស់ធ្វើឱ្យមានការផ្លាស់ប្តូរនាំមកនូវសេចក្តីសុខ និងសុភមង្គលដល់អតិថិជន និងសង្គម។

### គ. រចនាសម្ព័ន្ធរបស់ធនាគារឯកទេស ខេប៊ី ដេហាន




### ឃ. ភាគហ៊ុនរបស់ធនាគារឯកទេស ខេប៊ី ដេហាន

ធនាគារឯកទេស ខេប៊ី ដេហាន គឺជាធនាគារដែលមានភាគហ៊ុនសាធារណៈ។ ភាគហ៊ុនរបស់ធនាគារឯកទេសខេប៊ីដេហានត្រូវបានចុះបញ្ជីនៅលើទីផ្សារភាគហ៊ុនកូរ៉េខាងត្បូង។

ភាគហ៊ុនធំរបស់ធនាគារនេះរួមមាន៖

- **ក្រុមហ៊ុន KB Kookmin Card Co.,Ltd:** ជាធនាគារធំមួយនៅកូរ៉េខាងត្បូង ដែលកាន់ភាគហ៊ុនចំនួន 95.7% ក្នុង KDSB។
- **ធនាគារ Indochina Bank Ltd.**: ក្រុមហ៊ុនវិនិយោគ និងភ្នាក់ងារហ៊ុន ដែលកាន់ភាគហ៊ុនចំនួន 4.3% ក្នុង KDSB។

ស្ថាប័នទាំងនេះបានចូលរួមក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនាគារឯកទេស ខេប៊ី ដេហាន ដោយផ្តល់ជូនសេវាកម្មហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់ដល់អតិថិជន។

#### ៣.១.៣ ប្រភេទនៃទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន

ធនាគារឯកទេស ខេប៊ី ដេហាន (KB Daehan Specialized Bank - KDSB) មានទ្រព្យសកម្មចម្បងដែលទាក់ទងនឹងសេវាកម្មហិរញ្ញវត្ថុដែលផ្តល់ជូនដល់អតិថិជន។ ទ្រព្យសកម្មទាំងនេះត្រូវបានបែងចែកចេញជាប្រភេទផ្សេងៗដូចខាងក្រោម៖

- សាច់ប្រាក់ក្នុងដៃ
- ប្រាក់បញ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា-សុទ្ធ

- ប្រាក់តម្កល់តាមច្បាប់
- ឥណទាននិងបុរេប្រទានផ្តល់អតិថិជន-សុទ្ធ
- ទ្រព្យសកម្មផ្សេងៗ
- ទ្រព្យសកម្មអរូបី
- ទ្រព្យនិងបរិក្ខារ
- សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម
- តម្លៃកេរ្តិ៍ឈ្មោះ ។

**ក. សាច់ប្រាក់ក្នុងដៃ**

គឺជាប្រាក់ដែលយើងបានមកពីដើមទុនខ្លះ ប្រាក់បញ្ញើរបស់អតិថិជនខ្លះ និងចំណូលផ្សេងៗទៀតដោយដកមួយចំណែកដើម្បីរក្សាទុកការពារក្នុងធនាគារ នៅពេលអតិថិជនមកដកប្រាក់វិញ ឬសម្រាប់ប្រើប្រាស់ក្នុងអង្គភាព ។

**ខ. ប្រាក់បញ្ញើនៅគ្រឹះស្ថានហិរញ្ញវត្ថុនានា-សុទ្ធ**

គឺការទទួលប្រាក់បញ្ញើពីគ្រឹះស្ថានផ្សេងៗ ប្រាក់បញ្ញើមានកាលកំណត់ គណនីសន្សំប្រាក់បញ្ញើតាមតម្រូវការ ។

**គ. ប្រាក់តម្កល់តាមច្បាប់**

គឺជាសម្ព័ន្ធរបស់ធនាគារ និងធនាគារតម្រូវឱ្យមានប្រាក់តម្កល់តាមច្បាប់ចំនួន 10% នៃដើមទុនរបស់ខ្លួន ។

**ឃ. ឥណទាននិងបុរេប្រទានផ្តល់ដល់អតិថិជន-សុទ្ធ**

គឺធនាគារឯកទេស ខេប៊ី ដេហាន អាចទទួលបានឥណទានដើម្បីបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួនជាច្រើនដូចជា៖

- ឥណទានគ្មានទ្រព្យធានា
- ឥណទានរថយន្ត
- ឥណទានគេហដ្ឋាន
- ឥណទានមិនមែនកសិកម្ម
- ឥណទានខ្នាតតូច និងមធ្យម ។
- ការធានាអំពីធនាគារ ។

**ង. ទ្រព្យសកម្មផ្សេងៗ**

សំដៅដល់ទ្រព្យសកម្មដទៃផ្សេងៗទៀតដែលមិនមានបញ្ជាក់លម្អិត ក្នុងតារាងតុល្យការសម្រាប់ទ្រព្យសកម្មនៃលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ។

**ច. ទ្រព្យសកម្មអរូបី**

សំដៅដល់ទ្រព្យទាំងឡាយណា ដែលមិនមែនជាទ្រព្យរូបវន្ត ឬទ្រព្យហិរញ្ញវត្ថុ។ ទ្រព្យអរូបីអាចត្រូវបានកាន់កាប់ ឬគ្រប់គ្រងសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពអាជីវកម្ម ។ បុគ្គលដែលមានលទ្ធភាពជាម្ចាស់ ឬអ្នកគ្រប់គ្រងឬអ្នកប្រើប្រាស់ឬទទួលសិទ្ធិប្រើប្រាស់នូវទ្រព្យអរូបីនោះនឹងត្រូវទទួលបានមកវិញនូវផលប្រយោជន៍សេដ្ឋកិច្ច ក្នុងលក្ខខណ្ឌដែលប្រតិបត្តិការត្រូវបានធ្វើឡើងរវាងសហគ្រាសឯករាជ្យ ក្នុងកាលៈទេសៈ ដែលអាចប្រៀបធៀបបាន។ ទ្រព្យអរូបី ជាអាទិ៍មាន ពាណិជ្ជសញ្ញា ពាណិជ្ជនាម សិទ្ធិចម្លង រចនាបថដែលបានចុះបញ្ជី

សិទ្ធិប្រើប្រាស់អាជ្ញាប័ណ្ណ ស្នាដៃអក្សរសាស្ត្រ និងសិល្បៈ និងទ្រព្យប្រហាក់ប្រហែលផ្សេងទៀត ដែលមានតម្លៃជាកម្មសិទ្ធិបញ្ញា ឬអរូបីផ្សេងៗមាន ដូចជា ពាណិជ្ជសញ្ញា និងពាណិជ្ជនាមជាដើម ដែលត្រូវបានកំណត់ថាជាទ្រព្យអរូបីទីផ្សារ។

**ឆ. ទ្រព្យសម្បត្តិ និងបរិក្ខារ**

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើមដំបូង ដករំលស់។ ថ្លៃដើមដំបូង រួមមានចំណាយដោយផ្ទាល់ផ្សេងៗ ក្នុងការទិញនូវទ្រព្យសកម្មនោះ។ ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃ យោងនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យសកម្មដាច់ដោយឡែកតាមការសមស្រប នៅពេលដែលវាអាចមានលទ្ធភាពផ្តល់ នូវផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងដោយភាពជឿជាក់បាន។ រាល់ចំណាយក្នុងការជួសជុល និងថែទាំប្រចាំថ្ងៃផ្សេងៗ ត្រូវបានត្រូវបានកត់ត្រាក្នុងរបាយការណ៍ចំណេញ ឬខាត ក្នុងការិយបរិច្ឆេទដែលបានកើតឡើង។ ទ្រព្យកំពុងសាងសង់ មិនត្រូវបានដករំលស់នោះទេ។ រំលស់ត្រូវបានគណនាតាមវិធីសាស្ត្រសមតុល្យថយចុះ លើកលែងតែការកែលម្អទ្រព្យជួលដែលត្រូវបានរំលស់តាមវិធីសាស្ត្ររំលស់ថេរ អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មនីមួយៗ ដូចខាងក្រោម៖

- ការកែលម្អទ្រព្យជួល ៥ឆ្នាំ
- បរិក្ខារការិយាល័យ ៤-៥ឆ្នាំ
- គ្រឿងសង្ហារឹម គ្រឿងដំឡើង និងគ្រឿងបំពាក់ ៤-៥ឆ្នាំ
- បរិក្ខារកុំព្យូទ័រ ២ឆ្នាំ
- យានយន្ត ៥ឆ្នាំ

**ជ. សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម**

គឺជាគោលគំនិតផ្លូវច្បាប់ដែលផ្តល់សិទ្ធិដល់បុគ្គល ឬអង្គភាពក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងទទួលបានអត្ថប្រយោជន៍នៃទ្រព្យសកម្ម ដែលជាកម្មសិទ្ធិរបស់ភាគីផ្សេង។ សិទ្ធិនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចប្រើប្រាស់ទ្រព្យសកម្មក្នុងរយៈពេលជាក់លាក់មួយ ប៉ុន្តែ ពួកគេមិនមានសិទ្ធិជាម្ចាស់លើទ្រព្យសកម្មទាំងនេះឡើយ។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មអាចផ្តល់នូវភាពបត់បែន និងមានលទ្ធភាពទទួលបាននូវធនធាន ដោយមិនមាននូវកម្មសិទ្ធិពេញលេញ ហើយវាគឺជាគំនិតសំខាន់មួយនៅក្នុងប្រតិបត្តិការផ្លូវច្បាប់និងពាណិជ្ជកម្មផ្សេងៗ។

**ឈ. តម្លៃកេរ្តិ៍ឈ្មោះ**

ជាអតិរេកដោយផ្អែកទៅលើតម្លៃតបស្នង នៃតម្លៃសមស្របនៃទ្រព្យសកម្ម ។

**៣.១.៤ ប្រភេទនៃឥណទានរបស់ធនាគារឯកទេស ខេប៊ី ដេហាន**

ធនាគារឯកទេស ខេប៊ី ដេហាន (KB Daehan Specialized Bank - KDSB) មានឥណទានចម្បងដែលទាក់ទងនឹងសេវាកម្មហិរញ្ញវត្ថុដែលផ្តល់ជូនដល់អតិថិជន។ ឥណទានទាំងនេះ ត្រូវបានបែងចែកចេញជាប្រភេទផ្សេងៗដូចខាងក្រោម៖

### ក. ឥណទានរថយន្ត

ក្នុងកិច្ចសហការជាមួយដៃគូក្រុមហ៊ុនចែកចាយរថយន្ត និងដៃគូឈ្មួញកណ្ដាលដែលមានអាជ្ញាប័ណ្ណនៅក្នុងប្រទេសកម្ពុជា និងបទពិសោធន៍ពិសេសរបស់យើងធនាគារឯកទេស ខេប៊ី ដេហាន ផ្ដល់ដំណោះស្រាយការផ្ដល់ឥណទានរថយន្តល្អផ្ដាច់គេជូនដល់អតិថិជននិងបានផ្ដល់ប្រាក់កម្ចីដល់អតិថិជនប្រកបដោយជោគជ័យដើម្បីអាចទិញរថយន្តក្នុងក្ដីស្រមៃរបស់ពួកគេ។ ទាំងកម្ចីរថយន្តថ្មី និងរថយន្តប្រើប្រាស់រួចអាចរកបាននៅធនាគារឯកទេស ខេប៊ី ដេហាន។

កញ្ចប់ហិរញ្ញប្បទានពិសេសសម្រាប់ឥណទានរថយន្តត្រូវបានកំណត់ដូចខាងក្រោម៖

**+ លក្ខណៈពិសេស និងអត្ថប្រយោជន៍**

- ទំហំទឹកប្រាក់កម្ចី៖ រហូតដល់ ៨០% នៃតម្លៃរថយន្ត
- ទំហំប្រាក់ចូលរួមទាបបំផុត៖ ចាប់ពី ២០% នៃតម្លៃរថយន្ត
- អត្រាការប្រាក់ប្រកួតប្រជែង
- រយៈពេលកម្ចី៖ រហូតដល់ ០៨ឆ្នាំ
- រូបិយប័ណ្ណ៖ ប្រាក់ដុល្លារអាមេរិក ឬ ប្រាក់រៀល
- ធានារ៉ាប់រងរថយន្ត៖ មាន
- មិនតម្រូវឱ្យមានទ្រព្យធានា
- ផ្ដល់ជូនឥណទានទិញរថយន្តដល់អតិថិជនទាំង២៥ខេត្តក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា
- អតិថិជនអាចទទួលបានរថយន្តក្នុងរយៈពេលត្រឹមតែមួយថ្ងៃក្រោយពីបានបញ្ជូនឯកសារគ្រប់គ្រាន់មកធនាគារ ដោយប្រើប្រាស់សេវា អនុម័តរហ័ស ។

**+ លក្ខខណ្ឌអតិថិជន**

- មានអាយុចាប់ពី ១៨ឆ្នាំ រហូតដល់ ៦០ឆ្នាំ
- ជាជនជាតិខ្មែរ ឬជនបរទេសដែលកំពុងរស់នៅឬមានអាស័យដ្ឋានច្បាស់លាស់ក្នុងប្រទេសកម្ពុជា
- មានចំណូលទាបបំផុត ១០០ដុល្លារ ក្នុងមួយខែ ។

**+ ឯកសារតម្រូវ**

- ឯកសារបញ្ជាក់អត្តសញ្ញាណ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ជនជាតិខ្មែរ) លិខិតឆ្លងដែន (ជនបរទេស) ដែលមានសុពលភាព
- ឯកសារបញ្ជាក់ទីលំនៅ៖ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ ឬ ឯកសារពាក់ព័ន្ធផ្សេងៗ
- ឯកសារបញ្ជាក់ប្រាក់ចំណូល៖ លិខិតបញ្ជាក់ប្រាក់បៀវត្សរ៍ របាយការណ៍ប្រាក់ចំណូល របាយការណ៍ធនាគារ លិខិតបញ្ជាក់ការបំរើការងារ វិក្កយបត្រលក់ឬ ឯកសារពាក់ព័ន្ធផ្សេងៗ
- កិច្ចព្រមព្រៀងទិញលក់រថយន្ត៖ សម្រង់តម្លៃ ក្រដាសពន្ធ ឬ ឯកសារពាក់ព័ន្ធផ្សេងៗ
- ឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

### ខ. កម្ចីទូទៅ

ដើម្បីផ្ដល់ដំណោះស្រាយជួយសម្រេចសេចក្ដីប្រាថ្នារបស់អតិថិជន ធនាគារឯកទេស ខេប៊ី ដេហាន ផ្ដល់ដំណោះស្រាយហិរញ្ញវត្ថុល្អបំផុតជាមួយនឹងកម្ចីទូទៅ ដែលអតិថិជនអាចប្រើដើម្បីទិញផ្ទះបើកអាជីវកម្ម/

ពង្រឹងអាជីវកម្ម ឬជួយក្រុមគ្រួសាររបស់ពួកគេនៅពេលណាក៏បាន ដែលអតិថិជនចង់ដាក់ពាក្យស្នើសុំកម្ចី ដោយប្រើប័ណ្ណកម្មសិទ្ធិដែលមានតម្លៃសមស្របធ្វើជាវត្ថុធានា។

កញ្ចប់ហិរញ្ញប្បទានពិសេសរបស់យើងសម្រាប់កម្ចីទូទៅត្រូវបានកំណត់ដូចខាងក្រោម៖

**+ លក្ខណៈពិសេស និងអត្ថប្រយោជន៍**

- ទំហំទឹកប្រាក់កម្ចី៖ រហូតដល់ ៨០% នៃតម្លៃទ្រព្យធានា
- ទំហំប្រាក់ចូលរួមទាបបំផុត៖ ចាប់ពី ២០% នៃតម្លៃទ្រព្យធានា
- ទ្រព្យធានា៖ ដី ឬដីដែលមានសំណង់អគារ
- រយៈពេលកម្ចី៖ រហូតដល់ ២៥ឆ្នាំ
- រូបិយប័ណ្ណ៖ ប្រាក់ដុល្លារអាមេរិក ឬ ប្រាក់រៀល ។

**+ លក្ខខណ្ឌអតិថិជន**

- មានអាយុចាប់ពី ១៨ឆ្នាំ រហូតដល់ ៦០ឆ្នាំ
- ជាជនជាតិខ្មែរ
- មានចំណូលទាបបំផុត ១០០ដុល្លារ ក្នុងមួយខែ ។

**+ ឯកសារតម្រូវ**

- ឯកសារបញ្ជាក់អត្តសញ្ញាណ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានសុពលភាព
- ឯកសារបញ្ជាក់ទីលំនៅ៖ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅនិង ឯកសារពាក់ព័ន្ធផ្សេងៗ
- ឯកសារបញ្ជាក់ប្រាក់ចំណូល៖ លិខិតបញ្ជាក់ប្រាក់បៀវត្ស របាយការណ៍ប្រាក់ចំណូល របាយការណ៍ធនាគារ លិខិតបញ្ជាក់ការបំរើការងារ វិក្កយបត្រលក់ និងឯកសារពាក់ព័ន្ធផ្សេងៗ
- ប័ណ្ណកម្មសិទ្ធិ
- ឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

**គ. កម្ចីគ្រឿងយន្តកសិកម្ម**

ធនាគារឯកទេស ខេប៊ី ដេហាន ផ្តល់កម្ចីគ្រឿងយន្តកសិកម្មដើម្បីជួយអតិថិជន ក្នុងការទទួលបានហិរញ្ញប្បទាន ដើម្បីទិញផលិតផលគ្រឿងយន្តកសិកម្មសម្រាប់គោលបំណងធ្វើកសិកម្ម ឬជួល។ បច្ចុប្បន្ននេះ យើងបានសហការជាមួយត្រាក់ទ័រ John Deere ដើម្បីផ្តល់ជូនអតិថិជននូវលក្ខខណ្ឌកម្ចីពិសេស។ កញ្ចប់ហិរញ្ញប្បទាន ពិសេសរបស់យើងសម្រាប់កម្ចីគ្រឿងយន្តកសិកម្មត្រូវបានកំណត់ដូចខាងក្រោម៖

**+ លក្ខណៈពិសេស និងអត្ថប្រយោជន៍**

- ទំហំទឹកប្រាក់កម្ចី៖ រហូតដល់ ៧០% នៃតម្លៃគ្រឿងយន្តកសិកម្ម
- ទំហំប្រាក់ចូលរួមទាបបំផុត៖ ចាប់ពី ៣០% នៃតម្លៃគ្រឿងយន្តកសិកម្ម
- អត្រាការប្រាក់ទាបបំផុត៖ ១០% ក្នុងមួយឆ្នាំ
- រយៈពេលកម្ចី៖ រហូតដល់ ០៥ឆ្នាំ
- រូបិយប័ណ្ណ៖ ប្រាក់ដុល្លារអាមេរិក ឬ ប្រាក់រៀល
- ធានារ៉ាប់រង៖ មាន
- មានសេវាអនុម័តរហ័ស ។

**+ លក្ខខណ្ឌអតិថិជន**

- មានអាយុចាប់ពី ១៨ឆ្នាំ រហូតដល់ ៦០ឆ្នាំ
- ជាជនជាតិខ្មែរ ឬជនបរទេសដែលកំពុងរស់នៅឬមានអាស័យដ្ឋានច្បាស់លាស់ក្នុងប្រទេសកម្ពុជា
- មានចំណូលទាបបំផុត ១០០ដុល្លារ ក្នុងមួយខែ ។

**+ ឯកសារតម្រូវ**

- ឯកសារបញ្ជាក់អត្តសញ្ញាណៈ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ជនជាតិខ្មែរ) ឬលិខិតឆ្លងដែន (ជនបរទេស) ដែលមានសុពលភាព
- ឯកសារបញ្ជាក់ទីលំនៅៈ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ និង/ឯកសារពាក់ព័ន្ធផ្សេងៗ
- ឯកសារបញ្ជាក់ប្រាក់ចំណូលៈ លិខិតបញ្ជាក់ប្រាក់បៀវត្ស របាយការណ៍ប្រាក់ចំណូល របាយការណ៍ធនាគារ លិខិតបញ្ជាក់ការបំរើការងារ វិក្កយបត្រលក់ និងឯកសារពាក់ព័ន្ធផ្សេងៗ
- ឯកសារការងារកសិកម្មៈ រួមបញ្ចូលអ្នកជំនួញប្រកបរបរជួលគ្រឿងយន្ត
- កិច្ចព្រមព្រៀងទិញលក់
- ច្បាប់ចម្លងក្រដាសពន្ធ
- កសិករៈ ប័ណ្ណកម្មសិទ្ធិដីស្រែចំការ
- ម្ចាស់អាជីវកម្មជួលៈ ការចុះឈ្មោះអាជីវកម្មជួលគ្រឿងយន្តកសិកម្ម
- ឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

## ៣.២ នីតិវិធីក្នុងការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេមី ដេហាន

ការគ្រប់គ្រង គឺមានសារៈសំខាន់ណាស់សម្រាប់គ្រប់គ្រងស្ថាប័នទាំងអស់ ដោយឡែកវិស័យធនាគារបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ច។ ដូច្នេះហើយ ការគ្រប់គ្រងធនាគារគឺជាកត្តាមួយដ៏សំខាន់ដែលអ្នកគ្រប់គ្រងត្រូវយកចិត្តទុកដាក់ខ្ពស់ ដើម្បីធ្វើឱ្យមានប្រសិទ្ធភាព ក្នុងការប្រើប្រាស់ធនធានដូចជាៈ ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស ធនធានរូបវន្ត...។ ដោយសារធនាគារដើរតួនាទីយ៉ាងសំខាន់ ក្នុងការកេណ្ឌប្រមូលនូវប្រភពធនធានពីសេដ្ឋកិច្ច ហើយផ្តល់ទៅឱ្យអ្នកត្រូវការ(អ្នកខ្ចី) ដែលអាចផ្តល់ឱកាសនៅក្នុងការវិនិយោគ ដែលសកម្មភាពហិរញ្ញវត្ថុវាមានសារៈសំខាន់ និងជានាដល់ប្រព័ន្ធហិរញ្ញវត្ថុ និងសេដ្ឋកិច្ចឱ្យមានដំណើរការយ៉ាងរលូន និងមានប្រសិទ្ធភាព។

ធនាគារ គឺជាអាជីវកម្មមួយដែលត្រូវបានគេបង្កើតឡើង ក្នុងគោលបំណងស្វែងរកប្រាក់ចំណេញដើម្បីឱ្យទទួលបានប្រាក់ចំណេញ អ្នកគ្រប់គ្រងធនាគារ ឬម្ចាស់អាជីវកម្មត្រូវមានគោលដៅពីរសំខាន់គឺៈ

- **ទី១** ព្យាយាមស្វែងរកអតិថិជនឱ្យយកប្រាក់មកផ្ញើ
- **ទី២** ព្យាយាមឱ្យអតិថិជនមកខ្ចីប្រាក់។

ចំណែកឯទ្រព្យសកម្ម ក៏ជាប្រភពធនធានរបស់អង្គភាពអាជីវកម្ម។ ដូច្នេះ វាគឺមានសមាសធាតុដ៏មានតម្លៃអាចប្រើប្រាស់បាននៅក្នុងការអនុវត្តសកម្មភាពជាច្រើនដូចជា កត្តាផលិតកម្ម ការប្រើប្រាស់ការដោះដូរ។ ទ្រព្យសកម្មមានតួនាទីសំខាន់ណាស់ ក្នុងការជម្រុញការបង្កើតសាច់ប្រាក់ ទ្រព្យសកម្មចែកចេញជាពីរប្រភេទធំៗគឺៈ

**ទី១** ទ្រព្យសកម្មចរន្ត(Current Assets) គឺសំដៅលើទ្រព្យទាំងឡាយណាដែលអាចបំលែងជាសាច់ប្រាក់ក្នុងរយៈពេលតិចជាង ឬស្មើ១ឆ្នាំ។ ទ្រព្យសកម្មចរន្តរួមមាន សាច់ប្រាក់ក្នុងដៃ(Cash on hand) សាច់ប្រាក់ក្នុង

ធនាគារ (Cash in Bank) ឥណទាននិងបុរេប្រទានអតិថិជន( Loan and Advance to Customer ) និង ទ្រព្យសកម្មចរន្តផ្សេងៗទៀត។

**ទី២** អចលនទ្រព្យ (Fixed Assets) សំដៅលើទ្រព្យទាំងឡាយណា ដែលមានអាយុកាលវែងជាង១ឆ្នាំ ដោយវាចូលរួមគាំទ្រ និងជម្រុញដំណើរការអាជីវកម្ម។ អចលនទ្រព្យ ត្រូវបានចែកចេញជាពីរ គឺទ្រព្យរូបី (Tangible Assets) ដែលមានដូចជា សម្បត្តិ និងបរិក្ខារ (Properties and Equipment) ពន្ធពន្យារទ្រព្យ (Deferred tax Assets)។ ចំណែកឯទ្រព្យអរូបី( Intangible Assets ) មានដូចជាផ្លាកសញ្ញាពាណិជ្ជកម្ម (Trade Mark) ប្រកាសនីយបត្រតក្កកម្ម ( Parent ) ជាដើម។

### ៣.២.១ លក្ខណៈនៃការគ្រប់គ្រងទ្រព្យសកម្ម

ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារមានលក្ខណៈដូចខាងក្រោម៖

**ក. ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល( Liquidity management )**គឺជាសកម្មភាពនៃការគ្រប់គ្រងសាច់ប្រាក់ក្នុងដៃ និងប្រាក់បម្រុង ដើម្បីធានាថា ធនាគារអាចមាន សាច់ប្រាក់គ្រប់គ្រាន់ និងទាន់ពេលវេលាក្នុងការឆ្លើយតបទៅនឹងតម្រូវការពេលដែលអតិថិជនមកដកប្រាក់ បញ្ញើក្នុងរយៈពេលខ្លី។

ទោះបីជាយ៉ាងណាក៏ដោយ ការគ្រប់គ្រងលើសាច់ប្រាក់ងាយស្រួល តែងតែមានហានិភ័យដោយចៀសមិនរួច ដែលគេហៅថាហានិភ័យសាច់ប្រាក់ងាយស្រួល (Liquidity Risk)។ ហើយដើម្បីដោះស្រាយហានិភ័យនោះបាន ធនាគារអាចមានជម្រើសជាមូលដ្ឋានបួន(Shortfall)។

- ទីមួយ (Interbank Loan) គឺដើម្បីទទួលបាននូវទុនបម្រុងមកបំពេញលំហូរប្រាក់បញ្ញើតាមរយៈការខ្ចីប្រាក់ពីធនាគារផ្សេងៗទៀតនៅក្នុងទីផ្សារមូលនិធិសហព័ន្ធឬខ្ចីពីសារជីវកម្ម។
- ទីពីរ (Sale on Securities) គឺសម្រាប់ធនាគារក្នុងការលក់មួយចំនួននៃមូលបត្ររបស់ខ្លួនដើម្បីជួយលើលំហូរប្រាក់កញ្ញានេះ។
- ទីបី (Overnight loan/Borrow from Fed) ដែលធនាគារអាចប្រើប្រាស់សម្រាប់បំពេញប្រាក់បម្រុងកាតព្វកិច្ចបានគឺការទទួលនូវទុនបម្រុងខ្ចីពីធនាគារកណ្តាល។
- ទីបួន (Reduce Loan) គឺធនាគារអាចទទួលបានចំនួនទឹកប្រាក់គ្រប់គ្រាន់ ក្នុងការបំពេញប្រាក់បម្រុងវិញបាននោះគឺតាមរយៈដោយការកាត់បន្ថយឬផ្អាក ចំពោះការផ្តល់កម្ចីរបស់ខ្លួនដើម្បីយកមកបំពេញកាតព្វកិច្ចប្រាក់បម្រុងនេះ។

**ខ. ការគ្រប់គ្រងលើទ្រព្យសកម្ម (Assets Management)** អ្នកគ្រប់គ្រងធនាគារត្រូវតែវិនិយោគនៅក្នុងទ្រព្យសកម្មទាំងឡាយណាដែលផ្តល់នូវប្រាក់ចំណេញខ្ពស់តាមរយៈអត្រាការប្រាក់ខ្ពស់ហើយមានហានិភ័យទាប។

**គ. ការគ្រប់គ្រងលើបំណុល (Liabilities Management)** ការគ្រប់គ្រងលើបំណុលគឺទៅលើការព្រួយបារម្ភទាក់ទងទៅនឹងលទ្ធភាព នៃការទូទាត់បំណុលសងទៅម្ចាស់បំណុលវិញឱ្យបានទាន់តាមកិច្ចសន្យា។

**ឃ. ការគ្រប់គ្រងកម្ចី (Loan Management)** ព្យាយាមស្វែងរកអតិថិជនទាំងឡាយណា ( អ្នកខ្ចី ) ដែលនឹងមានការចំណាយអត្រាការប្រាក់ខ្ពស់ ហើយមានឆន្ទៈខ្ពស់ក្នុងការសង។ អតិថិជនដែលដាក់ពាក្យស្នើសុំឥណទានត្រូវតែជាជនជាតិខ្មែរដែលមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦៥ឆ្នាំ ហើយពួកគេអាចស្នើសុំឥណទានជាលក្ខណៈបុគ្គលក៏បាន ឬជាលក្ខណៈរួមគ្នាក៏បាន។ មុននឹងសម្រេចអនុម័ត និងបដិសេធសំណើឥណទានរបស់អតិថិជន តើធនាគារសិក្សាលើកត្តាសំខាន់ៗអ្វីខ្លះ? សម្រាប់សំណើឥណទានបុគ្គល ឯកសារ និងលក្ខណៈមិនសូវច្រើន

ដូចឥណទានអាជីវកម្មឡើយប៉ុន្តែសម្រាប់ការសិក្សាគឺមិនជាខុសគ្នាប៉ុន្មានឡើយ។ ក្នុងនោះធនាគារនឹងសិក្សាលើចំណុចចម្បងៗរួមមាន៖

**ទី១**. ប្រភពចំណូលរបស់អតិថិជន តើប្រភពចំណូលអាចទូទាត់សងទៅធនាគារវិញបានដែរឬទេ? ហើយវាមាននិរន្តរភាពដែរឬទេ? សម្រាប់ឥណទានជាលក្ខណៈបុគ្គល ជាទូទៅធនាគារតម្រូវឱ្យមានទំហំចំណូលយ៉ាងតិច2ដងនៃចំនួនទឹប្រាក់ដែលអតិថិជនត្រូវសងទៅធនាគារវិញ។ ចំណែកឯឥណទានអាជីវកម្មវិញ អតិថិជនត្រូវមានចំណូលយ៉ាងតិច 1.3ដង ឬ1.5ដង។ មិនត្រឹមតែប៉ុណ្ណោះបើប្រភពចំណូលមានរយៈពេលខ្លីហើយឥណទានគឺរយៈវែងវាមិនទូទាត់គ្នាឡើយ ដូច្នេះធនាគារនឹងពិនិត្យថាទំហំប្រភពចំណូល និងរយៈពេលនៃចំណូលមាននិរន្តរ៍ភាព និងរីកចម្រើនទៅមុខដែរ ឬទេនោះធនាគារអាចផ្តល់ឥណទានជូនបាន។

**ទី២**. គោលបំណងនៃឥណទានត្រូវស្របច្បាប់ដែលជួយដល់អតិថិជនខ្លួន និងមិនប៉ះពាល់ដល់អ្នកដទៃ ។ មិនតែប៉ុណ្ណោះអតិថិជនត្រូវប្រើប្រាស់ឥណទាន ដែលធនាគារបានអនុម័តឱ្យស្របតាមគោលដៅ និងគោលបំណង ដែលបានស្នើសុំដំបូងព្រោះធនាគារអាចប្រាកដថា ឥណទានដែលផ្តល់ឱ្យអតិថិជននោះនឹងជួយឱ្យពួកគេរីកចម្រើនទៅលើអាជីវកម្ម និងជីវិត។

**ទី៣**. ទ្រព្យធានាសម្រាប់ការស្នើសុំឥណទាន ដែលអាចចាត់ជាទ្រព្យធានាបានមានដូចជាគេហដ្ឋាន ដី គណនីមានកាលកំណត់ រួមទាំងអចលនទ្រព្យផ្សេងទៀត។ ហើយធនាគារក៏អាចផ្តល់នូវអត្រាការប្រាក់ដ៏សមរម្យមួយសម្រាប់អតិថិជនផងដែរ។

**ង. ការវិនិយោគមូលបត្រចំណូល (Income securities investment)**

ព្យាយាមដើម្បីទិញមូលបត្រទាំងឡាយណា ដែលអាចផ្តល់នូវប្រាក់ចំណូលខ្ពស់ និងមានហានិភ័យទាប។ សញ្ញាបណ្ណ័(Bonds) បណ្ណ័(Notes) និង មូលបត្រ (Security) ផ្សេងៗ ដែលបានកាន់កាប់ដោយធនាគារ សម្រាប់រកចំណូល ដែលគេស្គាល់ថាជាការវិនិយោគលើមូលបត្រ ។ មូលបត្រចែកចេញជាពីរគឺ៖

**ទី១**.មូលបត្រជាប់ពន្ធ(Taxable securities)៖ មូលបត្រជាប់ពន្ធរួមមាន សញ្ញាប័ណ្ណ និង ប័ណ្ណរបស់រដ្ឋាភិបាល និង សញ្ញាប័ណ្ណ និងប័ណ្ណរបស់ក្រុមហ៊ុនសាជីវកម្ម ។

**ទី២**.មូលបត្រមិនជាប់ពន្ធ(Tax-exempt securities)៖មូលបត្រមិនជាប់ពន្ធរួមមានសញ្ញាបណ្ណ័របស់រដ្ឋាភិបាលតំបន់ឬមូលដ្ឋាន(USA) ហើយចំណូលដែលបានមកត្រូវរួចពន្ធសហព័ន្ធ។ មូលបត្រវិនិយោគត្រូវបានគេភាគច្រើនកត់ត្រាមូលបត្ររបស់ខ្លួនដែលខ្លួនបានទិញ ហើយទ្រព្យ និង បំណុលផ្សេងទៀតតាមតម្លៃដើម។

**ច. ការគ្រប់គ្រងដើមទុនគ្រប់គ្រាន់ (Capital Adequacy Management)** អ្នកគ្រប់គ្រងធនាគារត្រូវតែសម្រេចចិត្តថា តើបរិមាណនៃដើមទុនធនាគារគួររក្សានិងតម្កល់ប៉ុន្មាន ដើម្បីស្របតាមតម្រូវការនៃច្បាប់ និងបង្កើតនូវភាពរឹងមាំសម្រាប់អតិថិជនរបស់ខ្លួន។

**ឆ. ការគ្រប់គ្រងហានិភ័យ (Risk Management)** ព្យាយាមដើម្បីកាត់បន្ថយហានិភ័យ តាមរយៈការគ្រប់គ្រងទ្រព្យសកម្មឱ្យមានប្រសិទ្ធភាព ធនាគារត្រូវមាននិយ័តកម្មរបស់ប្រាក់បញ្ញើគ្រប់ប្រភេទទៅលើអត្រាការប្រាក់លើកម្ចី និងប្រភពមូលនិធិមិនមែនកម្ចី ហើយលើសពីនេះទៀតអ្នកគ្រប់គ្រងត្រូវតែបង្កើតប្រភពរបស់មូលនិធិឱ្យបានច្រើន។

ហានិភ័យក្នុងការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារមានពីរ ៖

**ទី១**.ហានិភ័យឥណទាន(Credit Risk) : ទាក់ទងទៅនិងការផ្តល់ប្រាក់កម្ចី និងការសងត្រឡប់វិញ ។

**ទី២**.ហានិភ័យអត្រាការប្រាក់(Interest Rate Risk) : ទាក់ទងទៅនិងបម្រែបម្រួលនៃអត្រាការប្រាក់នៅលើទីផ្សារឥណទាន និង ទីផ្សារប្រាក់សន្សំ ។

**ជ. រក្សាសាច់ប្រាក់បម្រុង**

រក្សាសាច់ប្រាក់បម្រុង ដោយធ្វើយ៉ាងណាឱ្យសមល្មមទៅនឹងតម្រូវការជាក់ស្តែង។សាច់ប្រាក់បម្រុងជាទ្រព្យសកម្មដែលធនាគារនៃប្រទេសមួយរក្សាទុកសាច់ប្រាក់បម្រុងទាំងនេះមានសារៈសំខាន់ណាស់ សម្រាប់ការរក្សាស្ថិរភាពសេដ្ឋកិច្ច និងសម្រាប់នយោបាយហិរញ្ញវត្ថុផ្សេងៗ ជាឧទាហរណ៍ ដើម្បីប្រើប្រាស់ក្នុងការរក្សាតម្លៃលុយជាតិ ឬដើម្បីប្រើប្រាស់ក្នុងការចាយវាយផ្សេងៗរបស់ស្ថាប័ននីមួយៗក្នុងពេលមានវិបត្តិ។

**៣.២.២ វិធីសាស្ត្របែងចែកទ្រព្យសកម្មឱ្យមានប្រសិទ្ធភាព**

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការយ៉ាងសមស្រប ដើម្បីឈានដល់ការអះអាងថានីតិវិធីពាក់ព័ន្ធ ជាមួយទ្រព្យសកម្មដែលទំនងជាមិនអាចទទួលស្គាល់ក្នុងតម្លៃដើម ក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដូចដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនត្រូវបានកាត់បន្ថយតម្លៃត្រឹមតម្លៃ ដែលគេរំពឹងទុកថាអាចលក់បាន។

**ក. វិធីសាស្ត្រកំណត់តម្លៃ**

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពី ហេតុការណ៍ណាមួយដែលបានកើតឡើងដែលធ្វើឱ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនាំឱ្យមានការយល់ច្រឡំ ឬមានភាពមិនសមស្របនោះទេ។

**ខ. បំណុលយថាហេតុ និងបំណុលផ្សេងៗ**

នាកាលបរិច្ឆេទនេះមានពីរដំណាក់កាលគឺ៖

- ពុំមានការដាក់បន្ទុកទៅលើទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន។ បានកើតមានឡើងចាប់តាំងពីចុងការិយបរិច្ឆេទនៃហិរញ្ញវត្ថុ សម្រាប់ការធានាបំណុលរបស់បុគ្គល លើកលែងត្រូវតែបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- ពុំមានបំណុលយថាហេតុណាមួយកើតមានឡើង ចំពោះក្រុមហ៊ុនហិរញ្ញវត្ថុក្រៅពីប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនគេ។ ផ្អែកតាមទស្សនៈរបស់ក្រុមប្រឹក្សាភិបាលពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗ របស់ក្រុមហ៊ុនដែលអាចទំនងក្លាយជា កាតព្វកិច្ចក្នុងកំឡុងការិយបរិច្ឆេទ១២ខែខាងមុខបន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលនឹងមានឬអាចមានឥទ្ធិពលជាសារវន្ត ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលបំណុលនោះដល់កាលកំណត់សង។

**៣.២.៣ ការបែងចែកទ្រព្យសកម្មរបស់ធនាគារឯកទេស ខេមី ដេហាន**

**១. ទ្រព្យសកម្មហិរញ្ញវត្ថុ**

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ គឺត្រូវបានទទួលស្គាល់ និងលើមូលដ្ឋានការបរិច្ឆេទនៃការធ្វើពាណិជ្ជកម្មដែលការទិញ ឬលក់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺស្ថិតនៅក្រោមកិច្ចសន្យាដែលលក្ខខណ្ឌតម្រូវឱ្យមានការបញ្ជូននៃទ្រព្យសកម្មក្នុងអំឡុងពេលកំណត់ដែលបានបង្កើតឡើងដោយទីផ្សារដែលពាក់ព័ន្ធ។ រាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានទទួលស្គាល់ហើយត្រូវបានវាស់វែងទាំងស្រុងជាបន្តបន្ទាប់ ដោយប្រើវិធីសាស្ត្រតម្លៃដករំលស់ ឬតម្លៃសមស្របអាស្រ័យលើការចាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ។

### ក. ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ

ធនាគារបែងចែកទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន ទៅតាមប្រភេទនៃការវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងនៅពេលបន្ទាប់តាមតម្លៃសមស្របក្នុង OCI
- ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមថ្លៃដើមដករំលស់

ចំពោះការវិនិយោគលើឧបករណ៍មូលធនដែលមិនត្រូវបានកាន់កាប់សម្រាប់ការជួញដូរ ធនាគារបានសម្រេចចិត្តធ្វើការជ្រើសរើសនៅពេលទទួលស្គាល់លើកដំបូង ក្នុងការកត់ត្រាការវិនិយោគមូលធនទៅតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ (FVOCI) ។

ធនាគារធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលវាស់វែងតាមថ្លៃដើមដករំលស់ រួមមាន សាច់ប្រាក់ក្នុងដៃប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល និងធនាគារផ្សេងៗ ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ។

ការធ្វើចំណាត់ថ្នាក់នេះ គឺអាស្រ័យទៅតាមគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្មចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនតាមថ្លៃដើមដករំលស់ តែក្នុងករណីដែលស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមប៉ុណ្ណោះ ៖

- ទ្រព្យសកម្មដែលត្រូវបានកាន់កាប់ក្នុងគំរូអាជីវកម្ម ដែលមានគោលបំណងដើម្បីប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា និងលក្ខខណ្ឌក្នុងកិច្ចសន្យាដែលនាំឱ្យមានកាលបរិច្ឆេទជាក់លាក់នានា ចំពោះលំហូរសាច់ប្រាក់ដែលសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ទៅលើចំនួនប្រាក់ដើមដែលនៅមិនទាន់ទូទាត់។

### ខ. ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធនាគារទទួលស្គាល់ នៅពេលដែលធនាគារក្លាយជាភាគីមួយ ក្នុងកិច្ចសន្យានៃឧបករណ៍ណាមួយ។ ការទិញ និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុតាមមធ្យោបាយធម្មតា ត្រូវបានទទួលស្គាល់នាកាលបរិច្ឆេទជួញដូរ ជាកាលបរិច្ឆេទដែលធនាគារធ្វើការទិញ ឬលក់ទ្រព្យសកម្ម។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលសិទ្ធិក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម នោះបានហួសកាលកំណត់ ឬត្រូវបានផ្ទេរ ហើយធនាគារបានផ្ទេរនូវរាល់ហានិភ័យជាសារវន្ត និងផលកម្មសិទ្ធិទាំងអស់។ ចំណេញ ឬខាតពីការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគេឈប់ទទួលស្គាល់។

### គ. ការវាស់វែង

នាពេលទទួលស្គាល់លើកដំបូង ធនាគារវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្របបូកបន្ថែមជាមួយ និងចំណាយប្រតិបត្តិការផ្សេងៗដែលបានចំណាយផ្ទាល់ក្នុងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុ មិនត្រូវបានវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ-ខាត ។ ចំណាយប្រតិបត្តិការនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកត់ត្រាតាម FVPL ត្រូវបានកត់ត្រាជាចំណាយក្នុងចំណេញ-ខាត បន្ទាប់ពីការទទួលស្គាល់លើកដំបូងភ្លាម សំវិធានធនសម្រាប់ការថយចុះតម្លៃឥណទានរំពឹងទុក (ECL) ត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្ម ដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដែលធ្វើឱ្យមានការខាត

តាមគណនេយ្យមួយ ដែលត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត នៅពេលទ្រព្យសកម្មមួយត្រូវបានបង្កើតឡើងថ្មី។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានដេរីវេទីវ ត្រូវបានគេគិតទៅលើចំនួនរបស់វាទាំងស្រុង នៅពេលធ្វើការកំណត់លំហូរសាច់ប្រាក់របស់វាសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់។

ការវាស់វែងឧបករណ៍បំណុលគឺអាស្រ័យទៅលើគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្ម និងលក្ខណៈនៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មនោះ ហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមដករំលស់។ ធនាគារធ្វើចំណាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួនជាទ្រព្យសកម្ម

ថ្លៃដើមដករំលស់៖ ទ្រព្យសកម្មដែលត្រូវបានកាន់កាប់សម្រាប់ការប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាដែល លំហូរសាច់ប្រាក់នោះគឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ (SPPI) ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ តម្លៃ យោងនៃទ្រព្យសកម្មទាំងនេះ ត្រូវបានកែតម្រូវទៅតាមសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុកដែលបានទទួល ស្គាល់។ ចំណូលការប្រាក់ដែលបានពីទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុងចំណូលការប្រាក់ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

ចំពោះឥណទាន ផ្តល់ឱ្យបុគ្គលិកសម្រាប់ទិញផ្ទះ ដែលមានអត្រាការប្រាក់ទាបជាងអត្រាទីផ្សារត្រូវបានទទួលស្គាល់លើកដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់សាច់ប្រាក់នាពេលអនាគត និងធ្វើអប្បហារតាមអត្រាការប្រាក់លើទីផ្សារនៃឥណទាន ដែលប្រហាក់ប្រហែលគ្នាចំនួនលម្អៀងរវាងសាច់ប្រាក់បានបង់ និងតម្លៃបច្ចុប្បន្ននៃសាច់ប្រាក់ត្រូវទទួលក្នុងពេលអនាគត ត្រូវបានទទួលស្គាល់ជាបុរេប្រទានអត្ថប្រយោជន៍បុគ្គលិក និងត្រូវបានរំលស់ទៅជាចំណាយអត្ថប្រយោជន៍បុគ្គលិកក្នុងចំណេញ-ខាតលើរយៈពេលឥណទាន។

**ឃ. ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ**

ធនាគារធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ នៅពេលដែលគំរូអាជីវកម្មសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មរបស់ខ្លួនមានការប្រែប្រួល។

**ង. ការថយចុះតម្លៃ**

ធនាគារវាយតម្លៃការខាតឥណទានរំពឹងទុក (ECL) តាមមូលដ្ឋានរំពឹងមើលទៅថ្ងៃអនាគត ដែលទាក់ទង ជាមួយនឹងឧបករណ៍បំណុលរបស់ខ្លួនដែលវាស់វែងតាមថ្លៃដើមដករំលស់ ព្រមទាំងហានិភ័យដែលកើតពីកិច្ចសន្យាផ្តល់ឥណទាន។ ធនាគារទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ចំពោះការខាតប្រភេទនេះ នាកាលបរិច្ឆេទរាយការណ៍។ ការវាស់វែង ECL ឆ្លុះបញ្ចាំងពី ៖

ចំនួនលម្អៀង និងចំនួនដែលបានថ្លឹងប្រូបាប ដែលត្រូវបានកំណត់ដោយធ្វើការវាយតម្លៃលើលទ្ធភាពដែលអាចកើតឡើងមួយចំនួនពេលវេលានៃតម្លៃទឹកប្រាក់ និងព័ត៌មានដែលមានភាពសមហេតុផល និងមានការគាំទ្រ ដែលអាចរកបានដោយពុំចាំបាច់មានការចំណាយ និងការខំប្រឹងប្រែងលើសលប់ នាកាលបរិច្ឆេទរាយការណ៍ អំពីព្រឹត្តិការណ៍នាពេលអតីតកាលពេលបច្ចុប្បន្ន និងការព្យាករណ៍អំពីលក្ខខណ្ឌនាពេលអនាគត។

**ច. ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាព**

ទ្រព្យសកម្មហិរញ្ញវត្ថុមួយ គឺជា "ឥណទានមានឱនភាព" នៅពេលព្រឹត្តិការណ៍មួយឬច្រើនដែលមានដែលប៉ះពាល់អាក្រក់ដល់លំហូរសាច់ប្រាក់ដែលបានប៉ាន់ប្រមាណ នាពេលអនាគតនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានកើតឡើង។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពត្រូវគេចាត់ទុកថាជាទ្រព្យសកម្មថ្នាក់ទី៣។

ភស្តុតាងនៃឥណទានខាតបង់រួមមានទិន្នន័យដែលអាចអង្កេតបានពីព្រឹត្តិការណ៍ដូចខាងក្រោមៈ

- ការលំបាកផ្នែកហិរញ្ញវត្ថុជាសារវន្តរបស់អ្នកខ្ចី ឬអ្នកចេញផ្សាយ
- ការរំលោភកិច្ចសន្យាដូចជាការខកខានបង់ ឬហួសកាលបរិច្ឆេទកំណត់
- សម្រាប់ហេតុផលសេដ្ឋកិច្ច ឬកិច្ចសន្យាទាក់ទងនឹងភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកខ្ចី អ្នកផ្តល់កម្ចីបានផ្តល់សម្បទានដល់អ្នកខ្ចីដែលអ្នកផ្តល់កម្ចីមិនពិចារណាក្នុងករណីផ្សេង
- ការបាត់បង់នៃទីផ្សារសកម្មមួយសម្រាប់មូលប័ត្រ ដោយសារការលំបាកផ្នែកហិរញ្ញវត្ថុ
- ការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងការបញ្ចុះតម្លៃយ៉ាងច្រើន ដែលឆ្លុះបញ្ចាំងពីការបាត់បង់ឥណទានដែលបានកើតឡើង។

វានឹងមិនទៅរួចក្នុងការកំណត់ព្រឹត្តិការណ៍ដាច់ពីគ្នាតែមួយ ផ្ទុយទៅវិញឥទ្ធិពលរួមគ្នានៃព្រឹត្តិការណ៍មួយចំនួនអាចបណ្តាលឱ្យទ្រព្យសកម្មហិរញ្ញវត្ថុក្លាយមានឱនភាព។ ក្រុមហ៊ុនវាយតម្លៃតើឧបករណ៍បំណុលដែលជាទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងដោយតម្លៃដករំលស់ ឬ FVTOCI ជាការខាតបង់ឥណទាននាចុងការិយបរិច្ឆេទនីមួយៗ ដើម្បីវាយតម្លៃថា ឧបករណ៍បំណុលសាជីវកម្មជាឥណទានមានឱនភាព ក្រុមហ៊ុនពិចារណាលើកត្តាដូចជាទិន្នផលសញ្ញាប័ណ្ណ ការវាយតម្លៃឥណទាន និងលទ្ធភាពរបស់អ្នកខ្ចីក្នុងការប្រមូលមូលនិធិ។ ឥណទានមួយត្រូវបានចាត់ទុកជាឥណទានឱនភាពមាននៅពេលដែលសម្បទានត្រូវបានផ្តល់ដល់អ្នកខ្ចី ដោយសារតែការខ្វះខាតខាងជីវភាពនៅក្នុងស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី លើកលែងតែមានភស្តុតាងបង្ហាញថា ជាលទ្ធផលនៃការផ្តល់សម្បទានហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់ តាមកិច្ចសន្យាបានថយចុះ និងមិនមានសូចនាករផ្សេងទៀតនៃឱនភាព។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុសម្បទាន ត្រូវបានពិចារណា ប៉ុន្តែមិនបានផ្តល់ឱ្យនោះទេ ទ្រព្យនោះត្រូវបានគេចាត់ទុកថាជាឥណទានមានឱនភាព នៅពេលមានភស្តុតាង ដែលអាចសង្កេតពីឱនភាពឥណទានរួមទាំងការខាតបង់ ដែលត្រូវតាមនិយមន័យនៃការខកខានសង។ និយមន័យនៃការខកខានសងរួមបញ្ចូលទាំងសូចនាករបង្ហាញពីភាពមិនអាចទៅរួច ក្នុងការបង់ប្រាក់ និងការហួសកាលកំណត់សងក្នុងរយៈពេល៩០ថ្ងៃ ឬច្រើនជាងនេះជាគោល។ ព័ត៌មានរំពឹងទុកទៅខាងមុខដោយអាចរកបានដោយមិនចាំបាច់ចំណាយ ឬការប្រឹងប្រែងលើសលប់ដោយផ្អែកលើបទពិសោធន៍ដែលធ្លាប់មានរបស់ក្រុមហ៊ុន និងការវាយតម្លៃឥណទានរបស់អ្នកជំនាញរួមទាំងព័ត៌មានរំពឹងទុកទៅខាងមុខ។

**ធ. ការប្រែប្រួល និងការលែងទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ**

ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុកើតឡើង នៅពេលមានលក្ខខណ្ឌកិច្ចសន្យាទាក់ទងនឹងលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានធ្វើការចរចារឡើងវិញ ឬផ្លាស់ប្តូរជាថ្មីរវាងការទទួលស្គាល់ដំបូង និងកាលកំណត់សងនៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ការកែប្រែមានឥទ្ធិពលទៅលើចំនួនទឹកប្រាក់ ឬពេលវេលានៃលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាដែលអាចធ្វើទៅបានភ្លាម ឬនៅពេលអនាគត។ លើសពីនេះទៀត ការណែនាំ ឬការកែសម្រួលកិច្ចព្រមព្រៀង ដែលមានស្រាប់នៃឥណទានអាចបង្កើតបានជាការកែប្រែ ទោះបីជាកិច្ចព្រមព្រៀងថ្មី ឬការកែតម្រូវទាំងនេះ មិនទាន់ប៉ះពាល់ដល់លំហូរសាច់ប្រាក់ភ្លាមៗក៏ដោយ ប៉ុន្តែ អាចប៉ះពាល់ដល់លំហូរសាច់ប្រាក់ ដែលអាស្រ័យលើកិច្ចព្រមព្រៀងត្រូវបានបំពេញ ឬអត់( ឧទាហរណ៍ការផ្លាស់ប្តូរនៃការកើនឡើងអត្រាការប្រាក់ដែលកើតឡើងនៅពេលមានការរំលោភកិច្ចព្រមព្រៀង)។ ក្រុមហ៊ុនបង្ហាញពីសំវិធានធនបាតបង់រួមគ្នាសម្រាប់សមាសធាតុទាំងពីរ ចំនួនទឹកប្រាក់រួមបញ្ចូលគ្នាត្រូវបានបង្ហាញ ជាការកាត់ចេញពីតម្លៃ

នៅសល់ដុលពីសមាសធាតុដែលបានដក រាល់សំវិធានធនខាតបង់ដែលលើសពីចំនួនដុលសរុបនៃសមាស ធាតុដែលបានដកត្រូវបានបង្ហាញជាសំវិធានធន។

**ជ. បំណុលហិរញ្ញវត្ថុ និងមូលធន**

ឧបករណ៍បំណុល និងមូលធនដែលបានចេញផ្សាយ ត្រូវបានចាត់ថ្នាក់ជាបំណុលហិរញ្ញវត្ថុ ឬមូលធនសមស្របតាមខ្លឹមសារនៃការរៀបចំកិច្ចសន្យា។ ដែលហៅថាបំណុលហិរញ្ញវត្ថុ គឺជាកាតព្វកិច្ចតាមកិច្ចសន្យាក្នុងការប្រគល់សាច់ប្រាក់ ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ឬដើម្បីប្តូរទ្រព្យសកម្មហិរញ្ញវត្ថុជាមួយអង្គភាពផ្សេងទៀតក្រោមលក្ខខណ្ឌដែលមិនអំណោយផលដល់ក្រុមហ៊ុន ឬកិច្ចសន្យាដែលនឹង ឬអាចទូទាត់ជាភាគហ៊ុនផ្ទាល់របស់ក្រុមហ៊ុន និងគឺជាកិច្ចសន្យាដែលមិនមែនជានិស្សន្ទដែលក្រុមហ៊ុនមាន ឬត្រូវមានកាតព្វកិច្ចផ្តល់នូវចំនួនអថេរនៃភាគហ៊ុនផ្ទាល់របស់ខ្លួន ឬកិច្ចសន្យាចម្លងពីភាគហ៊ុនផ្ទាល់ និងត្រូវបានទូទាត់ក្រៅពីការដោះដូរនៃចំនួនទឹកប្រាក់ថេរនៃសាច់ប្រាក់ សម្រាប់ចំនួនថេរនៃឧបករណ៍ទ្រព្យមូលធនខ្លួនរបស់ក្រុមហ៊ុន។ បំណុលហិរញ្ញវត្ថុទាំងអស់ ត្រូវបានវាស់វែងជាបន្តបន្ទាប់ តាមតម្លៃដករំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ រាល់បំណុលហិរញ្ញវត្ថុ ចំនួនទឹកប្រាក់ ដែលត្រូវបង្ហាញលើរបាយការណ៍ហិរញ្ញវត្ថុតំណាងឱ្យចំនួនទឹកប្រាក់ដែលត្រូវបង់រួមទាំងការប្រាក់បង្គរ។ បំណុលហិរញ្ញវត្ថុដទៃទៀតរាប់បញ្ចូលទាំងប្រាក់បញ្ញើ និងប្រាក់កម្ចីត្រូវបានកត់ត្រាដំបូង ដោយប្រើតម្លៃសមស្របដកតម្លៃដើមប្រតិបត្តិការ។ បំណុលហិរញ្ញវត្ថុដទៃទៀតត្រូវបានកត់ត្រាបន្តបន្ទាប់មកទៀតតាមតម្លៃដករំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ វិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព គឺជាវិធីសាស្ត្រគណនាតម្លៃដករំលស់នៃបំណុលហិរញ្ញវត្ថុ និងការបែងចែកចំណាយការប្រាក់ក្នុងកំឡុងពេលដែលពាក់ព័ន្ធ។ អត្រាការប្រាក់ប្រសិទ្ធភាពគឺជាអត្រាមួយដែលធ្វើអប្បហារការទូទាត់សាច់ប្រាក់ នាពេលអនាគតដែលរំពឹងទុកក្នុងអាយុកាលនៃបំណុលហិរញ្ញវត្ថុចំនួនទឹកប្រាក់ យោងសុទ្ធពេលទទួលស្គាល់ដំបូង ។

**ឈ. ការរៀបចំកាត់កង**

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនសុទ្ធត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានសិទ្ធិអនុវត្តតាមផ្លូវច្បាប់ ក្នុងការកាត់កងបរិមាណដែលបានទទួលស្គាល់ និងមានបំណងដើម្បីទូទាត់លើមូលដ្ឋានសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលតំណាលគ្នា។ សិទ្ធិក្នុងការកាត់កងត្រូវមាននៅថ្ងៃនេះ ជាជាងការពឹងផ្អែកលើព្រឹត្តិការណ៍នាពេលអនាគត ហើយត្រូវតែអនុវត្តបានដោយសមភាគីណាមួយទាំងក្នុងដំណើរជំនួញធម្មតា និងមិនមានលទ្ធភាពសងបំណុល ឬក្ស័យធនក្នុងករណីមានការខកខានសង។

**ញ. មូលដ្ឋាននៃការគ្រប់គ្រងទ្រព្យសកម្ម**

មូលដ្ឋាននៃការគ្រប់គ្រងទ្រព្យសកម្ម ការទទួលខុសត្រូវចម្បងរបស់គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុលគឺជាការគ្រប់គ្រងទាំងស្រុងទៅលើតារាងតុល្យការ និងត្រួតពិនិត្យលើផ្នែកហិរញ្ញវត្ថុធនាគារឯកទេស ខេប៊ី ដេហាន ។ គណៈកម្មាធិការនេះធានាលើអត្រាការប្រាក់ការកំណត់រូបិយវត្ថុសាច់ប្រាក់ និងហានិភ័យហិរញ្ញវត្ថុដទៃទៀត ដែលអាចកើតឡើងចំពោះភាពមិនស៊ីចង្វាក់គ្នារវាងទ្រព្យសកម្ម និងបំណុលរបស់ធនាគារឯកទេស ខេប៊ី ដេហាន ហើយត្រូវបានរាយការណ៍វិភាគ ព្រមទាំងគ្រប់យ៉ាងត្រឹមត្រូវ។ ទាំងនេះហើយដែលធ្វើឱ្យធនាគារឯកទេស ខេប៊ី ដេហាន នៅតែបន្តរីកចម្រើនប្រកបដោយនិរន្តរភាពទន្ទឹម និងការគ្រប់គ្រង

ហានិភ័យទាំងឡាយណា ដោយប្រសិទ្ធភាពមុនពេល ដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីឈានដល់ការអះអាងថា នីតិវិធីពាក់ព័ន្ធជាមួយទ្រព្យសកម្ម ដែលទំនងជាមិនអាចទទួលស្គាល់ ក្នុងតម្លៃដើមក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដូចដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុននោះ ត្រូវបានកាត់បន្ថយត្រឹមតម្លៃដែលគេរំពឹងទុកថាអាចលក់បាន។ នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយ ដែលអាចបណ្តាលឱ្យការកំណត់តម្លៃនៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុក្រុមហ៊ុនមានការយល់ច្រឡំ ឬមានភាពមិនសមស្របទេ ។ គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុលផ្តល់ការប្រឹក្សាពីយុទ្ធសាស្ត្រទាក់ទង និងការគ្រប់គ្រងរបាយការណ៍តុល្យការរបស់ធនាគារទាំងមូល និងអនុម័តទៅលើគោលនយោបាយស្តីពីការប្រឆាំងការសម្អាតសាច់ប្រាក់។ លើសពីនេះទៅទៀត គណៈកម្មាធិការនេះទទួលខុសត្រូវលើយុទ្ធសាស្ត្រនៃការគ្រប់គ្រងអត្រាការប្រាក់របស់ស្ថាប័ន ក្នុងគោលបំណងដើម្បីរក្សាបាននូវកំណើន និងប្រាក់ចំណេញប្រកប ដោយនិរន្តរភាព និងសម្រេចបាននូវតម្លៃម្ចាស់ភាគហ៊ុនកាន់តែប្រសើរបំផុត។

## ៣.២.៤ ការគ្រប់គ្រងហានិភ័យការណ៍តុល្យការ

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ៣៣៤,២៣៩ | ១,៣៦៥,៣៦៦ | ២៦៦,៧៧៩ | ១,០៩៨,៣២៩ |
| ប្រាក់បញ្ញើនិងការដាក់ប្រាក់នៅធនាគារកណ្តាល | ៩៨,០៩៣ | ៤០០,៧១០ | ៣០,០៤៦,២៨៥ | ១២៣,៧០០,៥៥៥ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ | ៦,១១១,៧៧៦ | ២៤,៩៦៦,៦០៥ | ១៧,៧១៦,០២៦ | ៧២,៩៣៦,៨៧៩ |
| ប្រាក់តម្កល់តាមច្បាប់នៅធនាគារកណ្តាល | ៣,៦៨២,៥០០ | ១៥,០៤៣,០១៣ | ២,១៨៧,៥០០ | ៩,០០៥,៩៣៨ |
| ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើម | | | | |
| ដករំលស់ | ២៨៣,៧១០,៨៤៨ | ១,១៥៨,៩៥៨,៨១៥ | ២៨៨,៥៦២,៤០០ | ១,១៨៨,០១១,៤០១ |
| ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃ | | | | |
| សមស្រប | | | | |
| ក្នុងចំណូលលម្អិតផ្សេងៗ (FVOCI) | ១២,៥០១ | ៥១,០៦៧ | ១២,៥០១ | ៥១,៤៦៧ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១,៧៩៦,៨៣៩ | ៧,៣៤០,០៨៧ | ២,០០៦,៤៣៧ | ៨,២៦០,៥០១ |
| ទ្រព្យសកម្មអរូបី | ៦៩៩,៤១២ | ២,៨៥៧,០៩៨ | ៣៧០,១១៤ | ១,៥២៣,៧៥៩ |
| ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ | ៣,៣៥១,១៥៨ | ១៣,៦៨៩,៤៨០ | ២,៥៧៨,៧០៧ | ១០,៦១៦,៥៣៧ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ៦២៧,៥៣៤ | ២,៥៦៣,៤៧៦ | ១,១៣៩,៧១៤ | ៤,៦៩២,២០៣ |
| ទ្រព្យសកម្មផ្សេងៗ | ៥,០២៩,៩៥៥ | ២០,៥៤៧,៣៦៦ | ៦,៥០៦,០១១ | ២៦,៧៨៥,២៤៧ |
| **ទ្រព្យសកម្មសរុប** | ៣០៥,៤៥៤,៨៥៥ | ១,២៤៧,៧៨៣,០៨៣ | ៣៥១,៣៩២,៤៧៤ | ១,៤៤៦,៦៨២,៨១៦ |
| | | | | |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| ប្រាក់កម្ចី | ២០៨,៤៦៥,៥៩០ | ៨៥១,៥៨១,៩៣៥ | ២៥៦,២៧៨,៦៣១ | ១,០៥៥,០៩៩,១២៤ |
| បំណុលភតិសន្យា | ៣,០៧៤,១៧១ | ១២,៥៥៧,៩៨៩ | ២,១៩១,៥៧២ | ៩,០២២,៧០២ |
| បំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | ២៩៩,៥៣០ | ១,២២៣,៥៨០ | ១,៦៩៩,៣៨៥ | ៦,៩៩៦,៣៦៨ |
| បំណុលផ្សេងៗ | ១,៩០១,៣៧៣ | ៧,៧៦៧,១០៩ | ២,៣៦០,៦៣៩ | ៩,៧១៨,៧៥១ |
| សំវិធានធនសម្រាប់កិច្ចសន្យាក្រៅតារាងតុល្យការ | ៧,៧៩៨ | ៣១,៨៥៥ | ០១៨,៧៥១ | ០៧៧,១៩៨ |
| **បំណុលសរុប** | ២១៣,៧៤៨,៤៦២ | ៨៧៣,១៦២,៤៦៨ | ២៦២,៥៤៨,៩៧៨ | ១,០៨០,៩១៤,១៤៣ |
| | | | | |
| **មូលធន** | | | | |
| ដើមទុន | ៧៣,៦៥០,០០០ | ៣០០,៨៦០,២៥០ | ៤៣,៧៥០,០០០ | ១៨០,១១៨,៧៥០ |
| ដើមទុនផ្សេងៗ | - | - | ២៩,៩០០,០០០ | ១១៩,៦០០,០០០ |
| ទុនបម្រុងតាមច្បាប់ | ២,៣៧៧,៤១៩ | ៩,៧១១,៧៥៧ | ៤៧៩,៩៦៥ | ១,៩៦០,៦៥៧ |
| ប្រាក់ចំណេញរក្សាទុក | ១៥,៦៧៨,៩៧៤ | ៦៣,៩៤៧,៦៥០ | ១៤,៧១៣,៥៣១ | ៥៩,៩៧៩,៦៨០ |
| ទុនបម្រុងផ្សេងៗ | - | ១០០,៩៥៨ | - | ៤,១០៩,៥៨៦ |
| **មូលធនសរុប** | ៩១,៧០៦,៣៩៣ | ៣៧៤,៦២០,៦១៥ | ៨៨,៨៤៣,៤៩៦ | ៣៦៥,៧៦៨,៦៧៣ |
| | | | | |
| **បំណុល និងមូលធនសរុប** | ៣០៥,៤៥៤,៨៥៥ | ១,២៤៧,៧៨៣,០៨៣ | ៣៥១,៣៩២,៤៧៤ | ១,៤៤៦,៦៨២,៨១៦ |

**មូលដ្ឋានគណនេយ្យ**

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជាហៅកាត់ថា(ស.រ.ទ.ហ.អ.ក)។ ព័ត៌មានលម្អិតទាក់ទងនឹងគោលនយោបាយគណនេយ្យសំខាន់ៗ របស់ធនាគារត្រូវបានលាតត្រដាងក្នុងកំណត់សម្គាល់ 5។

+ **ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល**

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកត្រូវជារូបិយប័ណ្ណមុខងាររបស់ធនាគារ។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះធ្វើឡើងដោយអនុលោមទៅតាម ស.គ.អ.ក 21៖ ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស។ ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងគណនីមូលធនផ្សេងៗត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្ត្រ។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ដែលអត្រានេះត្រូវបានចាត់ទុកថា មានកម្រិតប្រហាក់ទៅនឹងអត្រាប្តូររូបិយប័ណ្ណនាថ្ងៃប្រតិបត្តិការ ដោយសារតែអត្រានេះ មិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ភាពខុសគ្នាដែលកើតឡើងពីការ ប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "ទុនបម្រុងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

**+សាច់ប្រាក់ក្នុងដៃ**

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| *រយៈពេលខ្លី* | | | | |
| ប្រាក់ដុល្លាអាមេរិក | ៣១៨.៥៩១ | ១.៣០១.៤៤៤ | ២៣៩.២២៧ | ៩៤២.៨៩៧ |
| ប្រាក់រៀល | ១៥.៦៤៨ | ៦៣.៩២២ | ២៧.៥៥២ | ១១៣.៤៣២ |
| | ៣៣៤.២៣៩ | ១.៣៦៥.៣៦៦ | ២៦៦.៧៧៩ | ១.០៩៨.៣២៩ |

**+ប្រាក់បញ្ញើនិងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា**

គណនីចរន្ត ត្រូវបានតម្កល់នៅធនាគារជាតិនៃកម្ពុជា ដោយមិនទទួលបានការប្រាក់នោះទេ ។

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| *រយៈពេលខ្លី* | | | | |
| សរុបរយៈពេលខ្លី | ៩៨.០៩៣ | ៤០០.៧១ | ៣០.០៤៦.២៨៥ | ១២៣.៧០០.៥៥៥ |

## +ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ

### ក. វិភាគតាមស្ថានភាពវិសនដ្ឋាន

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| *រយៈពេលខ្លី* | | | | |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្នុងប្រទេស | ៦.០៧៤.៥៥៦ | ២៤.៨១៤.៥៦១ | ១៧.៦៩១.០៣១ | ៧២.៨៣៣.៩៧៥ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្រៅប្រទេស | ៤១.៦៣ | ១៧០.០៥៩ | ៦៧.៧៨៧ | ២៧៩.០៧៩ |
| | ៦.១១៦.១៨៦ | ២៤.៩៨៤.៦២០ | ១៧.៧៥៨.៨១៨ | ៧៣.១១៣.០៥៤ |
| *ដក៖*សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក | -៤.៤១ | -១៨.០១៥ | -៤២.៧៩២ | -១៧៦.១៧៥ |
| | ៦.១១១.៧៧៦ | ២៤.៩៦៦.៦០៥ | ១៧.៧១៦.០២៦ | ៧២.៩៣៦.៨៧៩ |

### ខ. វិភាគតាមប្រភេទគណនី

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| *រយៈពេលខ្លី* | | | | |
| គណនីចរន្ត | ៦.១១៥.៩៦២ | ២៤.៩៨៣.៧០៥ | ៦.៦១៧.៣៣៣ | ២៧.២៤៣.៥៦០ |
| គណនីសន្សំ | ២២៤ | ៩១៥ | ៤.១២៨.១៣៨ | ១៦.៩៩៥.៥៤៤ |
| ប្រាក់បញ្ញើមានកាលកំណត់ | - | - | ៧.០០០.០០០ | ២៨.៨១៩.០០០ |
| | ៦.១១១.៧៧៦ | ២៤.៩៦៦.៦០៥ | ១៧.៧៤៥.៤៧១ | ៧៣.០៥៨.១០៨ |
| *បូក៖*ការប្រាក់បង្គរត្រូវទទួល | - | - | ១៣.៣៤៧ | ៥៤.៩៥០ |
| *ដក៖*សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក | -៤.៤១ | -១៨.០១៥ | -៤២.៧៩២ | -១៧៦.១៧៥ |
| | ៦.១១១.៧៧៦ | ២៤.៩៦៦.៦០៥ | ១៧.៧១៦.០២៦ | ៧២.៩៣៦.៨៧៩ |

## ៣.៣ ផលប្រយោជន៍នៃការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន

ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន មានផលប្រយោជន៍ណាស់គឺធ្វើឱ្យធនាគារនេះកើនទុនជារៀងរាល់ឆ្នាំ។

ដូចនេះ ហើយបានជាការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន ផ្តល់សារៈសំខាន់ដល់ស្ថាប័ន និងសង្គមដូចជា៖

### ក. ចំពោះស្ថាប័ន

- ទ្រព្យសកម្មមានការកើនឡើងជាលំដាប់ដែលក្លាយទៅជាចំណូលដ៏ចម្បង ហើយក៏ជាផ្នែកមួយដ៏សំខាន់របស់អង្គភាពអាជីវកម្ម ។
- មានការកើនឡើងសម្រាប់ការវិនិយោគជាមួយដៃគូអាជីវកម្មនៅក្នុងស្រុក និងក្រៅស្រុកក៏មានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ដែលជាហេតុធ្វើឱ្យធនាគារអាចពង្រីកសាខាបន្ថែមជាច្រើនទៀត។
- បន្តលើកកម្ពស់ការអភិវឌ្ឍ ដើម្បីផ្តល់ភាពកាន់តែងាយស្រួលប្រើប្រាស់ដល់អតិថិជនក្នុងការផ្លាស់ប្តូរទៅតាមការប្រើប្រាស់សេវាធនាគារតាមបែបឌីជីថល (ស្វ័យសេវា) ។
- ពង្រឹងសមត្ថភាពទាំងក្នុងនិងក្រៅប្រទេស ដើម្បីអាចប្រកួតប្រជែងនៅលើទីផ្សារ ។
- បង្កើតឯកសារឌីជីថលនិងឯកសារផ្សេងៗបញ្ចូលគ្នាជាទម្រង់ឌីជីថល សម្រាប់ប្រើផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ។
- បង្កើតសុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គាំទ្រដល់ធនាគារឌីជីថល ។
- មានការសហការដៃគូជាមួយស្ថាប័ននានា ដើម្បីភាពរីកចម្រើនរបស់ធនាគារធ្វើឱ្យសេវាកម្មធនាគារឯកទេស ខេប៊ី ដេហាន កម្ពុជាក្លាយជាសេវាកម្មដែលអាចទូទាត់កាន់តែទូលំទូលាយដល់អតិថិជន និងដៃគូអាជីវកម្មក្នុងស្រុកនិងក្រៅស្រុកពេញចិត្ត និងកាន់តែមានទំនុកចិត្តទ្វេរដង។
- ការគ្រប់គ្រងទ្រព្យសកម្មបានល្អអាចធ្វើឱ្យធនាគារមានសេរីភាពខ្ពស់ក្នុងការផ្តល់ឥណទាន និងសេវាកម្មហិរញ្ញវត្ថុ។
- ការវិនិយោគទ្រព្យសកម្មអាចជួយធានាថាប្រាក់ទុនរបស់ធនាគារ ត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាព។
- ការគ្រប់គ្រងទ្រព្យសកម្មជួយកាត់បន្ថយហានិភ័យដែលអាចប៉ះពាល់ដល់ស្ថេរភាពរបស់ធនាគារ។
- ការគ្រប់គ្រងទ្រព្យសកម្មយ៉ាងមានប្រសិទ្ធភាពអាចធ្វើឱ្យអតិថិជននិងវិនិយោគិនមានទំនុកចិត្ត។

### ខ. ចំពោះសង្គម

- ឧទាហរណ៍ ធនាគារសម្រាប់កសិកម្ម ផ្តល់ប្រាក់កម្ចីសម្រាប់កសិករដើម្បីទិញម៉ាស៊ីនចម្ការគ្រឿងចក្រ ឬបច្ចេកវិជ្ជាទំនើប។ វាជួយបង្កើនផលិតភាព និងចំណូល។
- ធនាគារដែលផ្តោតលើ SMEs ជួយដល់សហគ្រិនក្នុងការចាប់ផ្តើម ឬពង្រីកអាជីវកម្ម។
- បង្កើនឱកាសការងារដល់ប្រជាពលរដ្ឋ ។
- ជម្រុញការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដូចជាសំណង់អគារ ការអប់រំ បរិក្ខារសុខាភិបាល..ធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនមួយកម្រិតថែមទៀត។

- ធ្វើឱ្យសាច់ប្រាក់មានចរាចរបានល្អនៅក្នុងសេដ្ឋកិច្ចជាតិ ។
- កាត់បន្ថយអសន្តិសុខសង្គម( ចោរលួច ចោរប្លន់ ) ។
- ការផ្គត់ផ្គង់ផលិតផលនៅក្នុងសេដ្ឋកិច្ចមានការកើនឡើង ។
- បង្កើនប្រាក់ចំណូលបន្ថែមពីអ្នកវិនិយោគក្រៅស្រុក ។
- ទទួលបានការលើកស្ទួយ និងការអភិវឌ្ឍនជីវភាពរស់នៅកាន់តែមានភាពប្រសើរឡើង និង បង្កើតនូវអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករ និយោជិត ព្រមទាំងសហគមន៍ទាំងអស់ ។
- អាជីករទាំងអស់ទទួលបានសេវាសុវត្ថិភាពរហ័សទាន់ចិត្ត សម្រេចបានទាំងអាជីវកម្មតូចនិង អាជីវកម្មធំរបស់ពួកគាត់ ។

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

ក្រោយពីយើងបានសិក្សាស្រាវជ្រាវរួចមក អំពីប្រធានបទគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន រួចមកពួកយើងក៏បានពិនិត្យឃើញនូវចំណុចខ្លាំងរបស់ធនាគារមួយចំនួនដែលគួរឱ្យកោតសរសើរ និងកត់សម្គាល់រួមមានដូចខាងក្រោម៖

- ធនាគារបានរៀបចំរចនាសម្ព័ន្ធបុគ្គលិក និងការទទួលខុសត្រូវមានលក្ខណៈច្បាស់លាស់ដែលនាយកដ្ឋាននីមួយៗ និងសាខាទាំងអស់បំពេញការងារទៅតាមតួនាទី និងភារកិច្ចរៀងៗខ្លួន ហើយបុគ្គលិកសុទ្ធតែមានជំនាញ និងសមត្ថភាពក្នុងការបំពេញការងារ ។
- ធនាគារមានគោលការណ៍គ្រប់គ្រងទ្រព្យ និងប្រើប្រាស់ទ្រព្យឱ្យមានប្រសិទ្ធភាព និងអាចផលិតប្រាក់ ចំណេញបានខ្ពស់ និងបំបែកតម្លៃទ្រព្យដែលនៅសល់ពីការប្រើប្រាស់ឱ្យទៅជាប្រាក់ចំណេញវិញ។
- ធនាគាររៀបចំបានយ៉ាងល្អទៅលើរបាយការណ៍របស់ស្ថាប័ន និងមានការរៀបរាប់យ៉ាងលម្អិតទៅលើសាច់រឿងនីមួយៗ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីជូនដល់ក្រុមប្រឹក្សាភិបាលក៏ដូចជាអ្នកប្រើប្រាស់ខាងក្រៅដើម្បីអាន វិភាគ និងធ្វើសេចក្តីសម្រេចចិត្តខាងផ្នែកសេដ្ឋកិច្ច ។
- ធនាគារមានផែនការយុទ្ធសាស្ត្រក្នុងការផ្តល់សេវាកម្មជូនអតិថិជនជាច្រើនជម្រើស ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ និងជ្រើសរើស ។
- មាននីតិវិធីក្នុងការកំណត់ និងវិធីសាស្ត្ររំលស់លើទ្រព្យសកម្មដែលមានបង្ហាញ ក្នុងរបាយការណ៍តុល្យការ និងមានការបកស្រាយរៀបរាប់ពីទ្រព្យសកម្មបានល្អ ដែលធ្វើឱ្យមានភាពងាយស្រួលក្នុងការស្វែងយល់បន្ថែមអំពីទ្រព្យសកម្មរបស់ធនាគារ។
- មានការលើកទឹកចិត្តដល់បុគ្គលិកទាំងផ្នែកស្មារតី និងតំណែងដើម្បីឱ្យបុគ្គលិកខិតខំប្រឹងប្រែង ក្នុងការបំពេញតួនាទីរបស់ខ្លួនឱ្យបានល្អប្រសើរ ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ក្រៅពីចំណុចខ្លាំងរបស់ស្ថាប័នក្នុងនោះក៏មានចំណុចខ្សោយក្នុងការអនុវត្តន៍ផងដែររួមមាន៖

- ប្រព័ន្ធផ្សព្វផ្សាយមិនទូលំទូលាយ ដើម្បីផ្សព្វផ្សាយពីផលិតផល ឬសេវាកម្មរបស់ខ្លួនដល់អតិថិជន។
- អត្រាការប្រាក់ក្នុងការផ្តលឥណទានមានកម្រិតខ្ពស់នៅឡើយបើធៀប និងស្ថាប័នដទៃទៀត ។
- លក្ខខណ្ឌនៃការផ្តល់ឥណទាននៅមានភាពសាំញ៉ាំនៅឡើយ ព្រោះតម្រូវឱ្យអ្នកខ្ចីមានលក្ខខណ្ឌច្រើនពេក ដែលជាហេតុធ្វើឱ្យអតិថិជនមានភាពស្មុគស្មាញក្នុងការបំពេញតាមលក្ខខណ្ឌ ដែលបានចងអាចធ្វើឱ្យអតិថិជនមានការផ្លាស់ប្តូរចិត្តងាកទៅរកស្ថាប័នដទៃទៀត ដែលមានលក្ខខណ្ឌងាយស្រួលជាងដែលនាំឱ្យស្ថាប័នបាត់បង់ប្រាក់ចំណូលអស់មួយផ្នែក។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាស្រាវជ្រាវទៅលើការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន រួចមកយើងសង្កេតឃើញថា ធនាគារមានការរីកចម្រើន និងទទួលបានប្រាក់ចំណេញកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារតែស្ថាប័នមាននីតិវិធីក្នុងការរៀបចំបែងចែកថ្នាក់ដឹកនាំទៅតាមផ្នែកនីមួយៗ ទៅតាមសមត្ថភាព និងចំណេះដឹងរបស់បុគ្គលិកនីមួយៗ។ បុគ្គលិកគ្រប់ជាន់ថ្នាក់មានភាពរួសរាយរាក់ទាក់ធ្វើការប្រកបទៅដោយ ក្រមសីលធម៌ សុជីវធម៌ និងវិជ្ជាជីវៈច្បាស់លាស់ បុគ្គលិកមានទំនាក់ទំនងការងារល្អពីផ្នែកមួយទៅផ្នែកមួយយ៉ាងស្អិតរមួត។ សព្វថ្ងៃយើងឃើញថាស្ថាប័ន ក៏ជាចំណែកមួយក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសតាមរយៈ ការផ្តល់នូវឥណទាន សេវាប្រាក់បញ្ញើ សេវាទូទាត់តាម ATM តាមទូរស័ព្ទដៃ សេវាដកប្រាក់ទូATM សេវាផ្ទេរប្រាក់ សេវាទូទាត់វិក្កយបត្រ សេវាប្តូរប្រាក់ សេវាបើកប្រាក់បៀវត្ស ថែមទាំងមានសេវាជាច្រើនទៀតដែលអាចផ្តល់ឱ្យអតិថិជនជ្រើសរើសតាមតម្រូវការ។ លើសពីនេះទៅទៀតធនាគារបានបង្កើនឱកាសការងារដល់ប្រជាពលរដ្ឋកម្ពុជា កាត់បន្ថយភាពក្រីក្រ និងពលករចំណាកស្រុក ទាក់ទាញអ្នកវិនិយោគទាំងខ្នាតតូច និងមធ្យមតាមរយៈការផ្តល់ឥណទានរបស់ស្ថាប័ន។

ម្យ៉ាងវិញទៀត ធនាគារឯកទេស ខេប៊ី ដេហាន មានគោលការណ៍ក្នុងការគ្រប់គ្រងទ្រព្យ និងការប្រើប្រាស់ទ្រព្យសកម្មនៅក្នុងស្ថាប័នរបស់ខ្លួនធ្វើយ៉ាងណាឱ្យមានប្រសិទ្ធភាពខ្ពស់គួរជាទីទុកចិត្ត។ មិនតែប៉ុណ្ណោះ ធនាគារឯកទេស ខេប៊ី ដេហាន មានការរៀបចំរបាយការណ៍ហិរញ្ញវត្ថុយ៉ាងលម្អិតដោយរៀបរាប់ទៅលើសាច់រឿងនីមួយៗ ដែលជាកត្តាមួយធ្វើឱ្យទាក់ទាញពីអ្នកប្រើប្រាស់ខាងក្រៅ និងអ្នកវិនិយោគផងដែរ។ ហេតុដូច្នេះហើយទើបធ្វើឱ្យ ធនាគារឯកទេស ខេប៊ី ដេហាន នៅតែបន្តប្រតិបត្តិការអាជីវកម្មរបស់ខ្លួនរហូតដល់សព្វថ្ងៃនេះ។

សរុបសេចក្តីមកយើងឃើញថា ការសិក្សាទៅលើការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន ពិតជាមានសារៈសំខាន់ណាស់សម្រាប់អង្គភាពផ្ទាល់ និងបានផ្តល់នូវសារៈសំខាន់ជាច្រើនដល់អ្នកសិក្សា ស្រាវជ្រាវឱ្យបានយល់ច្បាស់អំពីការគ្រប់គ្រងទ្រព្យថា តើគួរធ្វើយ៉ាងណាប្រើប្រាស់ និងគ្រប់គ្រងទ្រព្យបែបណាទើបមានប្រសិទ្ធភាព ដើម្បីទទួលបានលទ្ធផលមួយដែលជាទីគាប់ប្រសើរ។ បន្ថែមពីនេះ ទៅទៀតធនាគារផលិតបាននូវប្រាក់ចំណូល ថែមទាំងជួយឱ្យវិស័យសេដ្ឋកិច្ច ក្នុងប្រទេសរីកចម្រើនទៅមុខជាលំដាប់ ។

## ៥.២ ការផ្តល់អនុសាសន៍

តាមរយៈការស្វ័យសិក្សា ដ៏យកចិត្តទុកដាក់កន្លងមកលើការរំលឹកទ្រឹស្តី និងការអនុវត្តជាក់ស្តែងបានបង្ហាញឱ្យយើងឃើញថា ធនាគារឯកទេស ខេប៊ី ដេហាន បានខិតខំយ៉ាងស្វះស្វែងដើម្បីអភិវឌ្ឍន៍ស្ថាប័នរបស់ខ្លួនឱ្យកាន់តែមានភាពរីកចម្រើនតាមរយៈការពង្រីកសាខានានា ដូច្នេះហើយទើបធ្វើឱ្យធនាគារឯកទេស ខេប៊ី ដេហាន បានក្លាយជាធនាគារមួយដែលធ្វើប្រតិបត្តិការនៅគ្រប់ខេត្ត និងរាជធានី។ ហើយធនាគារក៏បានអភិវឌ្ឍន៍ស្ថាប័ន ដោយបានបង្កើនបច្ចេកទេសឱ្យកាន់តែទំនើបដូចទៅនឹងធនាគារនានាដែរ ដោយអតិថិជន

អាចបង្កើតគណនីដោយខ្លួនឯងបានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដោយមិនចាំត្រូវទៅដល់ទីតាំងធនាគារដោយផ្ទាល់នោះឡើយ ដោយគ្រាន់តែតម្រូវឱ្យអតិថិជនមានអត្តសញ្ញាណប័ណ្ណ ហើយបំពេញតាមលក្ខខណ្ឌ និងព័ត៌មានផ្ទាល់ខ្លួនបន្តិចបន្តួចតែប៉ុណ្ណោះ នោះអតិថិជនអាចប្រើប្រាស់សេវាកម្មរបស់ធនាគារ ដោយមានភាពងាយស្រួល តាមរយៈគណនីរបស់ខ្លួន និងប្រព័ន្ធបច្ចេកវិទ្យាទំនើបផ្សេងៗទៀត។ ក៏ប៉ុន្តែក្នុងនោះ មានលេចឡើងនូវចំណុចខ្វះខាតមួយចំនួនតូចដែរ ហេតុដូច្នេះហើយ ទើបយើងខ្ញុំសូមធ្វើការសំណូមពរ ក៏ដូចជាផ្តល់នូវមតិយោបល់ក្នុងន័យស្ថាបនា ដើម្បីកែលម្អសម្រាប់ធនាគារកាន់តែមានភាពជោគជ័យមួយកម្រិតទៀតលើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ខ្លួនដូចខាងក្រោម៖

- ធនាគារគួរតែគិតគូរឡើងវិញ អំពីការកំណត់អត្រាការប្រាក់ក្នុងកម្រិតទាបមួយដែលអាចឱ្យអតិថិជនទទួលយកបាន និងស្ថាប័នក៏អាចទទួលស្គាល់បាន។
- ធនាគារគួរពង្រីកនូវប្រព័ន្ធផ្សព្វផ្សាយឱ្យទូលំទូលាយជាងនេះ ដើម្បីផ្សព្វផ្សាយពីផលិតផល និងសេវាកម្មផ្សេងៗរបស់ខ្លួនទៅកាន់អ្នកប្រើប្រាស់។
- ធនាគារគួរកាត់បន្ថយនូវលក្ខខណ្ឌ នៃការផ្តល់កម្ចីមួយចំនួន ដើម្បីជួយសម្រួលធ្វើឱ្យមានភាពងាយស្រួលដល់អតិថិជនក្នុងការរៀបចំឯកសារសម្រាប់ក្នុងការស្នើសុំខ្ចីប្រាក់ពីធនាគារ។
- ធនាគារគួរតែពង្រឹងចក្ខុវិស័យទៅលើបញ្ហាសេដ្ឋកិច្ច ដែលអាចនឹងកើតឡើងនាពេលអនាគត និងត្រៀមខ្លួនរួចជាស្រេចនៅពេលដែលសេដ្ឋកិច្ចមានការប្រែប្រួលជាពិសេសលើអត្រាការប្រាក់។

# ឯកសារយោង


1. ទីតាំងទីស្នាក់ការកណ្តាល អគារលេខ១ ជាន់ទី២០ ទី២១&ទី២២ ផ្លូវលេខ ៣៦០ ភូមិ០៨ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
2. រៀបរៀងដោយនិស្សិត ស៊ាង ស្រីមី, ផល ចិន្តា , ថេង ម៉ាល័យ. ( ឆ្នាំ2023 ). *ការគ្រប់គ្រងទ្រព្យសកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យនិស្សិតជំនាន់ទី២. វិទ្យាស្ថាន វ៉ាន់ដា. ទំព័រទី៧ ៣៣ទំព័រ. ភ្នំពេញ។
3. រៀបរៀងដោយនិស្សិត សេង នាង, ធន ផាន់នី, អ៊ឹម ម៉ីលិ, ឈឹម មួយហ៊ាង, ងួន វណ្ណដារី, អ៊ែល លីណា. ( ឆ្នាំ២០២៣ ). *ការគ្រប់គ្រងទ្រព្យសកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ. វិទ្យាស្ថាន វ៉ាន់ដា. និស្សិតជំនាន់ទី២០ ទំព័រទី៥. ៣៣ទំព័រ. ភ្នំពេញ។
4. KH INFO. (2022, March 13). *នីតិ* ? Retrieved from https://url-shortener.me/4AXY
5. Math and Money. (2018, September 18). *តើអ្វីទៅជា "ទ្រព្យសកម្ម ឬ Active Asset* ? Retrieved from https://mathnmoney.blogspot.com/2018/09/active-asset.html#:~%F0%9F%93%9D
6. វិទ្យាស្ថាន វ៉ាន់ដា. ( ឆ្នាំ2017 ). *សៀវភៅមូលដ្ឋានគ្រឹះនៃការគ្រប់គ្រង*. បោះពុម្ពលើកទី០៦. ទំព័រទី០២ ៦៥ទំព័រ
7. LiteFinance. Jana Kane. (2024, November 08). *ទ្រព្យសកម្មរូបីទល់នឹងទ្រព្យអរូបី៖តើវាខុសគ្នាដូចម្តេច ?* Retrieved from https://litefinance-kh.com/blog/for-beginners/tropyosambotte-roubei-ning-aroubei/
8. KHSearch. ហ៊ូ សម្ផស្ស. (2018, September 21). ដូចម្តេចដែលហៅថាការគ្រប់គ្រង ? Retrieved from https://www.khsearch.com/qna/7930
9. KHSearch. គ្រប់គ្រង. (2020, September 01). *តើមុខងារនៃការគ្រប់គ្រងមានប៉ុន្មានប្រភេទ ?* Retrieved from https://www.khsearch.com/qna/28177
10. Investorpedia. David Kindness. (2024, June 27). *What Is an Asset?* Retrieved from https://www.investopedia.com/terms/a/asset.asp
11. FHSU DIGITAL PRESS. (2020). *The History of Management*. Retrieved from https://fhsu.pressbooks.pub/management
12. KDSB. (2023). Annual Report. Retrieved from https://drive.google.com/file/d/18LKG2iaOOAyKMnoPfShmS_37tGIqlllK/view

# ឧបសម្ព័ន្ធ


របាយការណ៍សង្ខេបហិរញ្ញវត្ថុប្រចាំឆ្នាំ 2023
ឆ្នាំ 2023 គឺជាឆ្នាំដ៏លំបាកបំផុតក្នុងប្រវត្តិសាស្ត្ររបស់ធនាគារ KDSB ពីព្រោះយើងបានប្រឈមមុខនឹងការលំបាកជាច្រើនពីផលប៉ះពាល់ដោយកត្តាខាងក្រៅ ដូចជាវិបត្តិសេដ្ឋកិច្ចពិភពលោកជាដើម។ ប៉ុន្តែ យើងនៅតែអាចគ្រប់គ្រងវិបត្តិនេះបានល្អ និងរក្សាបាននូវតួលេខហិរញ្ញវត្ថុដូចខាងក្រោម៖
ប្រាក់ចំណេញសុទ្ធ
4,362,897
ដុល្លារអាមេរិក
ទ្រព្យសកម្មសរុប
305,454,855
ដុល្លារអាមេរិក
ទ្រព្យកម្ចី
292,801,464
ដុល្លារអាមេរិក
ផលចំណេញពីទ្រព្យសកម្ម
(Return on Assets)
1.43%
ផលចំណេញមូលធន
(Return on Equity)
4.76%


ផលិតផល
ឥណទានរថយន្ត
ឥណទានរថយន្ត គឺជាផលិតផលកម្ចីដែលរចនាឡើងយ៉ាងល្អិតល្អន់ ដើម្បីផ្តល់ហិរញ្ញប្បទានដល់អតិថិជន ដើម្បីឱ្យពួកគេអាចទទួលបានរថយន្តដែលពួកគេប្រាថ្នាចង់បាន ដែលមានសេវាកម្មរហ័ស និងមានភាពបត់បែន អត្រាការប្រាក់ប្រកួតប្រជែង និងមានរយៈពេលវែង ដែលមានផ្តល់ជូនសម្រាប់រថយន្តថ្មី និងរថយន្តប្រើប្រាស់រួច។
SSANGYONG
ISUZU

# កម្ចីទូទៅ

កម្ចីទូទៅគឺជាផលិតផលប្រាក់កម្ចីដែលមានការធានាដែលត្រូវបានរចនាឡើងយ៉ាងល្អសម្រាប់ផ្តល់ហិរញ្ញប្បទានដល់អតិថិជនសម្រាប់ការទិញផ្ទះ ដី ដើម្បីចាប់ផ្តើម ឬពង្រីកអាជីវកម្ម ដោះបំណុល និង ជួយដល់គ្រួសារ។ បន្ថែមពីលើផ្តល់សេវាដល់បុគ្គល កម្ចីទូទៅក៏ផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុតាមតម្រូវការ តាមរយៈកម្មវិធីគ្រឹះស្ថានហិរញ្ញវត្ថុ (FI) ដល់អង្គភាពវិជ្ជាជីវៈផ្សេងទៀតផងដែរ។
















# ប័ណ្ណឥណទាននិងឥណពន្ធ

ប័ណ្ណសំណាង KDSB គឺជាប័ណ្ណដែលបានរចនាឡើងជាលក្ខណៈបញ្ឈរ ដែលបានលេចមុខឡើងដំបូងគេនៅក្នុងទីផ្សារកម្ពុជា រួមមានទាំងប័ណ្ណឥណពន្ធ និង ឥណទានដែលដំណើរការជា VISA និងមានប្រព័ន្ធសុវត្ថិភាពរឹងមាំដែលទទួលស្គាល់ដោយ The Payment Card Industry Data Security Standard (PCI DSS) ហើយត្រូវបានរចនាឡើងយ៉ាងពិសេស ដើម្បីនាំសំណាងទៅកាន់ម្ចាស់ប័ណ្ណ តាមរយៈអត្ថប្រយោជន៍ផ្សេងៗជាច្រើនរបស់ប័ណ្ណនេះ។

## កម្ចីទិញគ្រឿងយន្តកសិកម្ម

កម្ចីទិញគ្រឿងយន្តកសិកម្ម គឺជាផលិតផលកម្ចីដែលជួយដល់អ្នកដែលមានបំណងចង់ក្លាយជាកសិករ និងអ្នកដែលជាកសិករស្រាប់ក៏ដូចជាម្ចាស់អាជីវកម្មកសិកម្មឱ្យទទួលបានជោគជ័យដោយផ្តល់មូលនិធិដែលត្រូវការ ដើម្បីទទួលបានទ្រព្យសម្បត្តិកសិកម្មសំខាន់ៗ។





## ធនាគារឯកទេស ខេប៊ី ដេហាន ម.ក

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់ | ២០២៣ | | ២០២២ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ៣៣៤.២៣៩ | ១.៣៦៥.៣៦៦ | ២៦៦.៧៧៩ | ១.០៩៨.៣២៩ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល | ៥ | ៩៨.០៩៣ | ៤០០.៧១០ | ៣០.០៤៦.២៨៥ | ១២៣.៧០០.៥៥៥ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ | ៦ | ៦.១១១.៧៧៦ | ២៤.៩៦៦.៦០៥ | ១៧.៧១៦.០២៦ | ៧២.៩៣៦.៨៧៩ |
| ប្រាក់តម្កល់តាមច្បាប់នៅធនាគារកណ្តាល | ៧ | ៣.៦៨២.៥០០ | ១៥.០៤៣.០១៣ | ២.១៨៧.៥០០ | ៩.០០៥.៩៣៨ |
| ឥណទាន និងបុរេប្រទានវាស់វែងតាមថ្លៃដើមដករំលស់ | ៨ | ២៨៣.៧១០.៨៤៨ | ១.១៥៨.៩៥៨.៨១៥ | ២៨៨.៥៦២.៤០០ | ១.១៨៨.០១១.៤០១ |
| ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របក្នុងចំណូលលម្អិតផ្សេងៗ (FVOCI) | ៩ | ១២.៥០១ | ៥១.០៦៧ | ១២.៥០១ | ៥១.៤៦៧ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១០ | ១.៧៩៦.៨៣៩ | ៧.៣៤០.០៨៧ | ២.០០៦.៤៣៧ | ៨.២៦០.៥០១ |
| ទ្រព្យសកម្មអរូបី | ១១ | ៦៩៩.៤១២ | ២.៨៥៧.០៩៨ | ៣៧០.១១៤ | ១.៥២៣.៧៥៩ |
| ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ | ១២ | ៣.៣៥១.១៥៨ | ១៣.៦៨៩.៤៨០ | ២.៥៧៨.៧០៧ | ១០.៦១៦.៥៣៧ |
| ពន្ធពន្យារជាទ្រព្យសកម្ម | ១៣ | ៦២៧.៥៣៤ | ២.៥៦៣.៤៧៦ | ១.១៣៩.៧១៤ | ៤.៦៩២.២០៣ |
| ទ្រព្យសកម្មផ្សេងៗ | ១៤ | ៥.០២៩.៩៥៥ | ២០.៥៤៧.៣៦៦ | ៦.៥០៦.០១១ | ២៦.៧៨៥.២៤៧ |
| **ទ្រព្យសកម្មសរុប** | | ៣០៥.៤៥៤.៨៥៥ | ១.២៤៧.៧៨៣.០៨៣ | ៣៥១.៣៩២.៤៧៤ | ១.៤៤៦.៦៨២.៨១៦ |
| | | | | | |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់កម្ចី | ១៥ | ២០៨.៤៦៥.៥៩០ | ៨៥១.៥៨១.៩៣៥ | ២៥៦.២៧៨.៦៣១ | ១.០៥៥.០៩៩.១២៤ |
| បំណុលភតិសន្យា | ១២ | ៣.០៧៤.១៧១ | ១២.៥៥៧.៩៨៩ | ២.១៩១.៥៧២ | ៩.០២២.៧០២ |
| បំណុលពន្ធលើប្រាក់ចំណូលក្នុងឆ្នាំ | ១៦ | ២៩៩.៥៣០ | ១.២២៣.៥៨០ | ១.៦៩៩.៣៨៥ | ៦.៩៩៦.៣៦៨ |
| បំណុលផ្សេងៗ | ១៧ | ១.៩០១.៣៧៣ | ៧.៧៦៧.១០៩ | ២.៣៦០.៦៣៩ | ៩.៧១៨.៧៥១ |
| សំវិធានធនសម្រាប់កិច្ចសន្យាក្រៅតារាងតុល្យការ | ២៩ | ៧.៧៩៨ | ៣១.៨៥៥ | ១៨.៧៥១ | ៧៧.១៩៨ |
| **បំណុលសរុប** | | ២១៣.៧៤៨.៤៦២ | ៨៧៣.១៦២.៤៦៨ | ២៦២.៥៤៨.៩៧៨ | ១.០៨០.៩១៤.១៤៣ |
| | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៨ | ៧៣.៦៥០.០០០ | ៣០០.៨៦០.២៥០ | ៤៣.៧៥០.០០០ | ១៨០.១១៨.៧៥០ |
| ដើមទុនផ្សេងៗ | ១៨ | - | - | ២៩.៥០០.០០០ | ១១៩.៦០០.០០០ |
| ទុនបម្រុងតាមច្បាប់ | ១៩ | ២.៣៧៧.៤១៩ | ៩.៧១១.៧៥៧ | ៤៧៩.៩៦៥ | ១.៩៦០.៦៥៧ |
| ប្រាក់ចំណេញរក្សាទុក | | ១៥.៦៧៨.៩៧៤ | ៦៣.៩៤៧.៦៥០ | ១៤.៧១៣.៥៣១ | ៥៩.៩៧៩.៦៨០ |
| ទុនបម្រុងផ្សេងៗ | | - | ១០០.៩៥៨ | - | ៤.១០៩.៥៨៦ |
| **មូលធនសរុប** | | ៩១.៧០៦.៣៩៣ | ៣៧៤.៦២០.៦១៥ | ៨៨.៨៤៣.៤៩៦ | ៣៦៥.៧៦៨.៦៧៣ |
| | | | | | |
| **បំណុល និងមូលធនសរុប** | | ៣០៥.៤៥៤.៨៥៥ | ១.២៤៧.៧៨៣.០៨៣ | ៣៥១.៣៩២.៤៧៤ | ១.៤៤៦.៦៨២.៨១៦ |

**ធនាគារឯកទេស ខេប៊ី ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

**២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)**

**២.៥ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)**

(ក) ចំណាត់ថ្នាក់ (ត)

ការធ្វើចំណាត់ថ្នាក់នេះគឺអាស្រ័យទៅតាមគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខខណ្ឌក្នុងកិច្ចសន្យានៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

ធនាគារបានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន តាមថ្លៃដើមដករំលស់តែក្នុងករណីដែលស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមប៉ុណ្ណោះ ៖

- ទ្រព្យសកម្មដែលត្រូវបានកាន់កាប់ក្នុងគំរូអាជីវកម្ម ដែលមានគោលបំណងដើម្បីប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា និង
- លក្ខខណ្ឌក្នុងកិច្ចសន្យាដែលនាំឱ្យមានកាលបរិច្ឆេទជាក់លាក់នានា ចំពោះលំហូរសាច់ប្រាក់ ដែលសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ ទៅលើចំនួនប្រាក់ដើមដែលនៅមិនទាន់ទូទាត់។

(ខ) ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានទទួលស្គាល់ នៅពេលដែលធនាគារក្លាយជាភាគីមួយក្នុងកិច្ចសន្យានៃឧបករណ៍ណាមួយ។ ការទិញ និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុតាមមធ្យោបាយធម្មតា ត្រូវបានទទួលស្គាល់នាកាលបរិច្ឆេទជួញដូរ ជាកាលបរិច្ឆេទដែលធនាគារធ្វើការទិញ ឬលក់ទ្រព្យសកម្ម។

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានឈប់ទទួលស្គាល់ នៅពេលដែលសិទ្ធិក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មនោះបានហួសកាលកំណត់ ឬត្រូវបានផ្ទេរ ហើយធនាគារបានផ្ទេរនូវរាល់ហានិភ័យជាសារវន្ត និងផលកម្មសិទ្ធិទាំងអស់។ ចំណេញ ឬខាតពីការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ-ខាត នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគេឈប់ទទួលស្គាល់។

(គ) ការវាស់វែង

នាពេលទទួលស្គាល់លើកដំបូង ធនាគារវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប បូកបន្ថែមជាមួយនឹងចំណាយប្រតិបត្តិការផ្សេងៗដែលបានចំណាយផ្ទាល់ក្នុងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ-ខាត (FVPL) ។ ចំណាយប្រតិបត្តិការនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានកត់ត្រាតាម FVPL ត្រូវបានកត់ត្រាជាចំណាយក្នុងចំណេញ-ខាត។ បន្ទាប់ពីការទទួលស្គាល់លើកដំបូងភ្លាមសំវិធានធនសម្រាប់ការថយចុះតម្លៃឥណទានរំពឹងទុក (ECL) ត្រូវបានទទួលស្គាល់សម្រាប់ទ្រព្យសកម្មដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដែលធ្វើឱ្យមានការខាតតាមគណនេយ្យមួយ ដែលត្រូវបានទទួលស្គាល់ក្នុងចំណេញ-ខាត នៅពេលទ្រព្យសកម្មមួយត្រូវបានបង្កើតឡើងថ្មី។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានដេរីវេទីវ ត្រូវបានគេគិតទៅលើចំនួនរបស់វាទាំងស្រុង នៅពេលធ្វើការកំណត់លំហូរសាច់ប្រាក់របស់វាសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់។

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត (ត)

### ២.៥ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

(គ) ការវាស់វែង (ត)

*ឧបករណ៍បំណុល*

ការវាស់វែងឧបករណ៍បំណុលគឺអាស្រ័យទៅលើគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្ម និងលក្ខណៈនៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មនោះ។ ធនាគារធ្វើចំណាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួនជាទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមដករំលស់។

ថ្លៃដើមដករំលស់៖ ទ្រព្យសកម្មដែលត្រូវបានកាន់កាប់សម្រាប់ការប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា ដែលលំហូរសាច់ប្រាក់នោះគឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ (SPPI) ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។ តម្លៃយោងនៃទ្រព្យសកម្មទាំងនេះ ត្រូវបានកែតម្រូវទៅតាមសំវិធានធនសម្រាប់ការខាតបង់ឥណទានរំពឹងទុកដែលបានទទួលស្គាល់។ ចំណូលការប្រាក់ដែលបានពីទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុងចំណូលការប្រាក់ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

ចំពោះឥណទានផ្តល់ឱ្យបុគ្គលិកសម្រាប់ទិញផ្ទះ ដែលមានអត្រាការប្រាក់ទាបជាងអត្រាទីផ្សារ ត្រូវបានទទួលស្គាល់លើកដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់សាច់ប្រាក់នាពេលអនាគត និងធ្វើអប្បហារតាមអត្រាការប្រាក់លើទីផ្សារនៃឥណទានប្រហាក់ប្រហែលគ្នា។ ចំនួនលម្អៀងរវាងសាច់ប្រាក់បានបង់ និងតម្លៃបច្ចុប្បន្ននៃសាច់ប្រាក់ត្រូវទទួលក្នុងពេលអនាគត ត្រូវបានទទួលស្គាល់ជាបុរេប្រទានអត្ថប្រយោជន៍បុគ្គលិក ក្នុងខ្ទង់ទ្រព្យសកម្មផ្សេងៗ និងត្រូវបានរំលស់ទៅជាចំណាយអត្ថប្រយោជន៍បុគ្គលិកក្នុងចំណេញ-ខាតលើរយៈពេលឥណទាន។

(ឃ) ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ

ធនាគារធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ នៅពេលដែលគំរូអាជីវកម្មសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មរបស់ខ្លួនមានការប្រែប្រួល។

(ង) ការថយចុះតម្លៃ

ធនាគារវាយតម្លៃការខាតឥណទានរំពឹងទុក (ECL) តាមមូលដ្ឋានរំពឹងមើលទៅថ្ងៃអនាគត ដែលទាក់ទងជាមួយនឹងឧបករណ៍បំណុលរបស់ខ្លួនដែលវាស់វែងតាមថ្លៃដើមដករំលស់ ព្រមទាំងហានិភ័យដែលកើតពីកិច្ចសន្យាផ្តល់ឥណទាន។ ធនាគារទទួលស្គាល់សំវិធានធនសម្រាប់ការខាតបង់ចំពោះការខាតប្រភេទនេះ នាកាលបរិច្ឆេទរាយការណ៍។ ការវាស់វែង ECL ឆ្លុះបញ្ចាំងពី ៖

- ចំនួនលម្អៀង និងចំនួនដែលបានថ្លឹងប្រូបាប ដែលត្រូវបានកំណត់ដោយធ្វើការវាយតម្លៃលើលទ្ធភាពដែលអាចកើតឡើងមួយចំនួន
- ពេលវេលានៃតម្លៃទឹកប្រាក់ និង
- ព័ត៌មានដែលមានភាពសមហេតុផល និងមានការគាំទ្រ ដែលអាចរកបានដោយពុំចាំបាច់មានការចំណាយ និងការខំប្រឹងប្រែងលើសលប់ នាកាលបរិច្ឆេទរាយការណ៍ អំពីព្រឹត្តិការណ៍នាពេលអតីតកាល ពេលបច្ចុប្បន្ន និងការព្យាករអំពីលក្ខខណ្ឌនាពេលអនាគត

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣. ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ និងការវិនិច្ឆ័យ (ត)

### ii) លក្ខខណ្ឌកតិសន្យា

ក្នុងការកំណត់លក្ខខណ្ឌភតិសន្យា គណៈគ្រប់គ្រងពិចារណាទៅលើភាពជាក់ស្តែង និងលក្ខខណ្ឌទាំងអស់ដែលបង្កើតឱ្យមានការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច ដើម្បីអនុវត្តជម្រើសក្នុងការបន្តការជួល ឬជម្រើសមិនបន្តការជួល។ ជម្រើសក្នុងការបន្តការជួល (ឬ រយៈពេលបន្ទាប់ពីជម្រើសបញ្ឈប់ការជួល) ត្រូវបានរួមបញ្ចូលនៅក្នុងលក្ខខណ្ឌភតិសន្យា ប្រសិនបើភតិសន្យានោះមានភាពជាក់លាក់សមហេតុផល សម្រាប់ការបន្តការជួល (ឬ មិនបញ្ឈប់តែប៉ុណ្ណោះ)។

### iii) យថាហេតុ

អគ្គនាយកដ្ឋានពន្ធដារ (GDT) បានចេញលទ្ធផលសម្រាប់ការធ្វើសវនកម្មដល់ទីកន្លែង សម្រាប់ការិយបរិច្ឆេទ ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ ដែលធនាគារមានបំណុលពន្ធបន្ថែម ទាក់ទងនឹងពន្ធកាត់ទុកចំពោះភាគលាភបង់ឱ្យអនិវាសនជន។ គណៈគ្រប់គ្រងជឿជាក់ថា មិនមានភាពប្រាកដថាធនាគារត្រូវបង់ប្រាក់ពន្ធបន្ថែមដូចបានបញ្ជាក់នៅក្នុងការកំណត់ពន្ធនេះទេ ប៉ុន្តែក៏មិនអាចប៉ាន់ស្មានបំណុលគួរឱ្យទុកចិត្តបាន។ ដូចនេះ គណៈគ្រប់គ្រងមានយោបល់ថា ពន្ធដែលបានកំណត់ឡើងវិញនេះ មិនត្រូវទទួលស្គាល់ជាបំណុលទេ ប៉ុន្តែត្រូវបានលាតត្រដាងជាបំណុលយថាហេតុ (កំណត់សម្គាល់ ៣២)។

### ៤. សាច់ប្រាក់ក្នុងដៃ

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| *រយៈពេលខ្លី* | | | | |
| ប្រាក់ដុល្លារអាមេរិក | ៣១៨.៥៩១ | ១.៣០១.៤៤៤ | ២៣៩.២២៧ | ៩៨៤.៨៩៧ |
| ប្រាក់រៀល | ១៥.៦៤៨ | ៦៣.៩២២ | ២៧.៥៥២ | ១១៣.៤៣២ |
| | ៣៣៤.២៣៩ | ១.៣៦៥.៣៦៦ | ២៦៦.៧៧៩ | ១.០៩៨.៣២៩ |

### ៥. ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារកណ្តាល

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| *រយៈពេលខ្លី* | | | | |
| សរុបរយៈពេលខ្លី | ៩៨.០៩៣ | ៤០០.៧១០ | ៣០.០៤៦.២៨៥ | ១២៣.៧០០.៥៥៥ |

នេះគឺជាសាច់ប្រាក់ក្នុងគណនីចរន្ត ដែលផ្ញើនៅធនាគារជាតិ នៃ កម្ពុជា ដែលមិនមានការប្រាក់ទេ។

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៦. ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ

### ក. វិភាគតាមស្ថានភាពនិវាសនដ្ឋាន

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| *រយៈពេលខ្លី* | | | | |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្នុងប្រទេស | ៦.០៧៤.៥៥៦ | ២៤.៨១៤.៥៦១ | ១៧.៦៩១.០៣១ | ៧២.៨៣៣.៩៧៥ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារក្រៅប្រទេស | ៤១.៦៣០ | ១៧០.០៥៩ | ៦៧.៧៨៧ | ២៧៩.០៧៩ |
| | ៦.១១៦.១៨៦ | ២៤.៩៨៤.៦២០ | ១៧.៧៥៨.៨១៨ | ៧៣.១១៣.០៥៤ |
| *ដក៖* | | | | |
| សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក | (៤.៤១០) | (១៨.០១៥) | (៤២.៧៩២) | (១៧៦.១៧៥) |
| | ៦.១១១.៧៧៦ | ២៤.៩៦៦.៦០៥ | ១៧.៧១៦.០២៦ | ៧២.៩៣៦.៨៧៩ |

### ខ. វិភាគតាមប្រភេទគណនី

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| *រយៈពេលខ្លី* | | | | |
| គណនីចរន្ត | ៦.១១៥.៩៦២ | ២៤.៩៨៣.៧០៥ | ៦.៦១៧.៣៣៣ | ២៧.២៤៣.៥៦០ |
| គណនីសន្សំ | ២២៤ | ៩១៥ | ៤.១២៨.១៣៨ | ១៦.៩៩៥.៥៤៤ |
| ប្រាក់បញ្ញើមានកាលកំណត់ | - | - | ៧.០០០.០០០ | ២៨.៨១៩.០០០ |
| | ៦.១១៦.១៨៦ | ២៤.៩៨៤.៦២០ | ១៧.៧៤៥.៤៧១ | ៧៣.០៥៨.១០៤ |
| *បូក៖* | | | | |
| ការប្រាក់បង្គរត្រូវទទួល | - | - | ១៣.៣៤៧ | ៥៤.៩៥០ |
| *ដក៖* | | | | |
| សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក | (៤.៤១០) | (១៨.០១៥) | (៤២.៧៩២) | (១៧៦.១៧៥) |
| | ៦.១១១.៧៧៦ | ២៤.៩៦៦.៦០៥ | ១៧.៧១៦.០២៦ | ៧២.៩៣៦.៨៧៩ |

## ការផ្តល់ឥណទានរថយន្ត

ក្នុងកិច្ចសហការជាមួយដៃគូក្រុមហ៊ុនចែកចាយរថយន្ត និងដៃគូឈ្មួញកណ្តាលដែលមានអាជ្ញាប័ណ្ណនៅក្នុងប្រទេសកម្ពុជា និងបទពិសោធន៍ពិសេសរបស់យើង ធនាគារ KDSB ផ្តល់ដំណោះស្រាយការផ្តល់ឥណទានរថយន្តល្អផ្តាច់គេជូនដល់អតិថិជន និងបានផ្តល់ប្រាក់កម្ចីដល់អតិថិជនប្រកបដោយជោគជ័យដើម្បីអាចទិញរថយន្តក្នុងក្តីស្រមៃរបស់ពួកគេ។ទាំងកម្ចីរថយន្តថ្មី និងរថយន្តប្រើប្រាស់រួច អាចរកបាននៅធនាគារ KDSB។






### លក្ខណៈពិសេស និង អត្ថប្រយោជន៍

- ទំហំទឹកប្រាក់កម្ចី៖ រហូតដល់ ៨០% នៃតម្លៃរថយន្ត
- ទំហំប្រាក់ចូលរួមទាបបំផុត៖ ចាប់ពី ២០% នៃតម្លៃរថយន្ត
- អត្រាការប្រាក់ប្រកួតប្រជែង
- រយៈពេលកម្ចី៖ រហូតដល់ ០៨ឆ្នាំ
- រូបិយប័ណ្ណ៖ ប្រាក់ដុល្លារអាមេរិក ឬ ប្រាក់រៀល
- ធានារ៉ាប់រងរថយន្ត៖ មាន
- មិនតម្រូវឱ្យមានទ្រព្យធានា
- ផ្តល់ជូនឥណទានទិញរថយន្តដល់អតិថិជនទាំង២៥ខេត្តក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា
- អតិថិជនអាចទទួលបានរថយន្តក្នុងរយៈពេលត្រឹមតែមួយថ្ងៃក្រោយពីបានបញ្ជូនឯកសារគ្រប់គ្រាន់មកធនាគារ ដោយប្រើប្រាស់សេវា **អនុម័តរហ័ស**

### លក្ខខណ្ឌអតិថិជន

- មានអាយុចាប់ពី ១៨ឆ្នាំ រហូតដល់ ៦០ឆ្នាំ
- ជាជនជាតិខ្មែរ ឬជនបរទេសដែលកំពុងរស់នៅឬមានអាស័យដ្ឋានច្បាស់លាស់ក្នុងប្រទេសកម្ពុជា
- មានចំណូលទាបបំផុត ១០០ដុល្លារ ក្នុងមួយខែ

### ឯកសារតម្រូវ

- ឯកសារបញ្ជាក់អត្តសញ្ញាណ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ជនជាតិខ្មែរ) ឬ លិខិតឆ្លងដែន (ជនបរទេស) ដែលមានសុពលភាព
- ឯកសារបញ្ជាក់ទីលំនៅ៖ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ និង/ឬ ឯកសារពាក់ព័ន្ធផ្សេងៗ
- ឯកសារបញ្ជាក់ប្រាក់ចំណូល៖ លិខិតបញ្ជាក់ប្រាក់បៀវត្ស របាយការណ៍ប្រាក់ចំណូល របាយការណ៍ធនាគារ លិខិតបញ្ជាក់ការបំពេញការងារ វិក្កយបត្រលក់ និង/ឬ ឯកសារពាក់ព័ន្ធផ្សេងៗ
- កិច្ចព្រមព្រៀងទិញលក់រថយន្ត៖ សម្រង់តម្លៃ ក្រដាសពន្ធ និង/ឬ ឯកសារពាក់ព័ន្ធផ្សេងៗ
- ឯកសារពាក់ព័ន្ធផ្សេងៗទៀត

## កម្ចីទូទៅ

ដើម្បីផ្តល់ដំណោះស្រាយជួយសម្រេចសេចក្តីប្រាថ្នារបស់អតិថិជន ធនាគារ KDSB ផ្តល់ដំណោះស្រាយហិរញ្ញវត្ថុល្អបំផុត ជាមួយនឹងកម្ចីទូទៅ ដែលអតិថិជនអាចប្រើដើម្បីទិញផ្ទះ បើកអាជីវកម្ម/ពង្រីងអាជីវកម្ម ឬជួយក្រុមគ្រួសាររបស់ពួកគេនៅពេលណាក៏បានដែលអតិថិជនចង់ដាក់ពាក្យស្នើសុំកម្ចីដោយប្រើប័ណ្ណកម្មសិទ្ធិដែលមានតម្លៃសមស្របធ្វើជាវត្ថុធានា។





### លក្ខណៈពិសេស និង អត្ថប្រយោជន៍

- ទំហំទឹកប្រាក់កម្ចី៖ រហូតដល់ ៨០% នៃតម្លៃទ្រព្យធានា
- ទំហំប្រាក់ចូលរួមទាបបំផុត៖ ចាប់ពី ២០% នៃតម្លៃទ្រព្យធានា
- ទ្រព្យធានា៖ ដី ឬ ដីដែលមានសំណង់អគារ
- រយៈពេលកម្ចី៖ រហូតដល់ ២៥ឆ្នាំ
- រូបិយប័ណ្ណ៖ ប្រាក់ដុល្លារអាមេរិក ឬ ប្រាក់រៀល

### លក្ខខណ្ឌអតិថិជន

- មានអាយុចាប់ពី ១៨ឆ្នាំ រហូតដល់ ៦០ឆ្នាំ
- ជាជនជាតិខ្មែរ
- មានចំណូលទាបបំផុត ១០០ដុល្លារ ក្នុងមួយខែ

### ឯកសារតម្រូវ

- ឯកសារបញ្ជាក់អត្តសញ្ញាណ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានសុពលភាព
- ឯកសារបញ្ជាក់ទីលំនៅ៖ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ និង/ឬ ឯកសារពាក់ព័ន្ធផ្សេងៗ
- ឯកសារបញ្ជាក់ប្រាក់ចំណូល៖ លិខិតបញ្ជាក់ប្រាក់បៀវត្ស របាយការណ៍ប្រាក់ចំណូល របាយការណ៍ធនាគារ លិខិតបញ្ជាក់ការបំពេញការងារ វិក្កយបត្រលក់ និង/ឬ ឯកសារពាក់ព័ន្ធផ្សេងៗ
- ប័ណ្ណកម្មសិទ្ធិ
- ឯកសារពាក់ព័ន្ធផ្សេងៗទៀត

# កម្ចីគ្រឿងយន្តកសិកម្ម

KDSB ផ្តល់កម្ចីគ្រឿងយន្តកសិកម្មដើម្បីជួយអតិថិជនក្នុងការទទួលបានហិរញ្ញប្បទានដើម្បីទិញផលិតផលគ្រឿងយន្តកសិកម្មសម្រាប់គោលបំណងធ្វើកសិកម្ម ឬជួល។ បច្ចុប្បន្ននេះ យើងបានសហការជាមួយត្រាក់ទ័រ John Deere ដើម្បីផ្តល់ជូនអតិថិជននូវលក្ខខណ្ឌកម្ចីពិសេសដូចខាងក្រោម៖




## លក្ខណៈពិសេស និង អត្ថប្រយោជន៍

- ទំហំទឹកប្រាក់កម្ចី៖ រហូតដល់ ៧០% នៃតម្លៃគ្រឿងយន្តកសិកម្ម
- ទំហំប្រាក់ចូលរួមទាបបំផុត៖ ចាប់ពី ៣០% នៃតម្លៃគ្រឿងយន្តកសិកម្ម
- អត្រាការប្រាក់ទាបបំផុត៖ ១០% ក្នុងមួយឆ្នាំ
- រយៈពេលកម្ចី៖ រហូតដល់ ០៥ឆ្នាំ
- រូបិយប័ណ្ណ៖ ប្រាក់ដុល្លារអាមេរិក ឬ ប្រាក់រៀល
- ធានារ៉ាប់រង៖ មាន
- មានសេវាអនុម័តរហ័ស

## លក្ខខណ្ឌអតិថិជន

- មានអាយុចាប់ពី ១៨ឆ្នាំ រហូតដល់ ៦០ឆ្នាំ
- ជាជនជាតិខ្មែរ ឬជនបរទេសដែលកំពុងរស់នៅឬមានអាស័យដ្ឋានច្បាស់លាស់ក្នុងប្រទេសកម្ពុជា
- មានចំណូលទាបបំផុត ១០០ដុល្លារ ក្នុងមួយខែ

## ឯកសារតម្រូវ

- ឯកសារបញ្ជាក់អត្តសញ្ញាណ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ជនជាតិខ្មែរ) ឬ លិខិតឆ្លងដែន (ជនបរទេស) ដែលមានសុពលភាព
- ឯកសារបញ្ជាក់ទីលំនៅ៖ សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ និង/ឬ ឯកសារពាក់ព័ន្ធផ្សេងៗ
- ឯកសារបញ្ជាក់ប្រាក់ចំណូល៖ លិខិតបញ្ជាក់ប្រាក់បៀវត្ស របាយការណ៍ប្រាក់ចំណូល របាយការណ៍ធនាគារ លិខិតបញ្ជាក់ការបំពេញការងារ វិក្កយបត្រលក់ និង/ឬ ឯកសារពាក់ព័ន្ធផ្សេងៗ
- ឯកសារការងារកសិកម្ម៖ រួមបញ្ចូលអ្នកជំនួញប្រកបរបរជួលគ្រឿងយន្ត
- កិច្ចព្រមព្រៀងទិញលក់
- ច្បាប់ចម្លងក្រដាសពន្ធ
- កសិករ៖ ប័ណ្ណកម្មសិទ្ធិដីស្រែចំការ
- ម្ចាស់អាជីវកម្មជួល៖ ការចុះឈ្មោះអាជីវកម្មជួលគ្រឿងយន្តកសិកម្ម
- ឯកសារពាក់ព័ន្ធផ្សេងៗទៀត